ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនតាមមធ្យមសិក្សា
# បឋមភូមិនានានៅកម្ពុជា
# (ករណីសិក្សា៖ ភ្នំពេញ)

THE SITUATION OF TEACHERS UTILIZATION AT SECONDARY SCHOOLS IN CAMBODIA (CASE-STUDY IN PHNOM PENH)


ដោយ/By

**កើត មាឃលក្ខិណា** /KOEUT MEAKLEAKHENA


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ

ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី ៣

ឆ្នាំសិក្សា៖ ២០១៩-២០២០

ក្រសួងអប់រំយុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀនតាម

# មធ្យមសិក្សាបឋមភូមិនានានៅកម្ពុជា

# (ករណីសិក្សា៖ ភ្នំពេញ)

# THE SITUATION OF TEACHERS UTILIZATION AT SECONDARY SCHOOLS IN CAMBODIA (CASE-STUDY IN PHNOM PENH)

ដោយ/By

**កើត មាឃលក្ខិណា**/ KOEUT MEAKLEAKHENA

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ

ឯកទេស៖ វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣

ឆ្នាំសិក្សា ២០១៩-២០២០

គ្រូដឹកនាំ ៖ លោក ម៉ៅ សារឿន

# សេចក្តីអះអាងរបស់បេក្ខជន

នាងខ្ញុំឈ្មោះ **កើត មាឃលក្ខិណា** សូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**ស្ថានភាពនៃការប្រើប្រាស់គ្រូតាមមធ្យមសិក្សាបឋមភូមិនានានៅកម្ពុជា**" សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ គឺពិតជាស្នាដៃស្រាវជ្រាវរបស់នាងខ្ញុំទាំងស្រុង ។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយឡើយ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីក្នុងឯកសារយោងឡើយ។

និក្ខេបបទខាងលើនេះត្រូវបានស្រាវជ្រាវ និងចងក្រងដោយនាងខ្ញុំផ្ទាល់ពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០២០

**ហត្ថលេខា**

**កើត មាឃលក្ខិណា**

# លិខិតបញ្ជាក់

**ឈ្មោះ ៖ ម៉ៅ សារឿន** ជាគ្រូដឹកនាំ

## សូមបញ្ជាក់ និងទទួលស្គាល់ថា

នាងខ្ញុំ **កើត មាឃលក្ខិណា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ឯកទេស វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ស្ថានភាពនៃការប្រើប្រាស់គ្រូតាមមធ្យមសិក្សាបឋមភូមិនានានៅកម្ពុជា**» ពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំ ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០២០

.......................................................................

**លោក ម៉ៅ សារឿន**

ប្រធានដេប៉ាតឺម៉ង់អប់រំ

វិទ្យាស្ថានជាតិអប់រំ

# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

**វិទ្យាស្ថានជាតិអប់រំ**

លេខ:.................វជអ

## សូមបញ្ជាក់ និងទទួលស្គាល់

## នាយកវិទ្យាស្ថានជាតិអប់រំ

សូមបញ្ជាក់ និងទទួលស្គាល់ថា៖

នាងខ្ញុំ **កើត មាឃលក្ខិណា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ឯកទេស វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ពិតជាបានការពារគម្រោងស្រាវជ្រាវ និងសរសេរនិក្ខេបបទដែលមានប្រធានបទ «**ស្ថានភាពនៃការប្រើប្រាស់គ្រូតាមមធ្យមសិក្សាបឋមភូមិនានានៅកម្ពុជា**» ស្របតាមលក្ខខណ្ឌកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំ ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០២០

**ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា**

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ ៣៣៤ វជអ. ឥក

**លិខិតឧទ្ទេសនាម**

យោង៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ ជំនាន់ទី៣ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩។

បុគ្គលិកអប់រំនៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចូលរួមវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៅថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២០ ចាប់ពីម៉ោង៨៖០០នាទី ព្រឹកតទៅ នៅមជ្ឈមណ្ឌលវប្បធម៌ **សម្តេច ហ៊ុន សែន និងលោកជំទាវ៖**

I. **គណៈកម្មការវាយតម្លៃ**

**ក្រុមទី១**

| | | | |
|---|---|---|---|
| ១ | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | នាយកវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២ | លោកបណ្ឌិត នី វង្ឋា | ប្រធានការិយាល័យសិក្សា | អនុប្រធាន |
| ៣ | លោក ម៉ៅ សារឿន | ប្រធានដេប៉ាតឺម៉ង់អប់រំ | សមាជិក |
| ៤ | លោកបណ្ឌិត គួយ សុគាន | គ្រូឧទ្ទេស | សមាជិក |
| ៥ | ល.ស នូ ចន្ធី | គ្រូឧទ្ទេស | សមាជិក |
| ៦ | លោក សៀង វាសនា | គ្រូឧទ្ទេស | សមាជិក |

**ក្រុមទី២**

| | | | |
|---|---|---|---|
| ១ | លោកបណ្ឌិត នូវ រីរ៉ា | នាយករងវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២ | លោក ម៉ន មុនិន្ទ | ប្រធានដេប៉ាតឺម៉ង់ផែនការ | អនុប្រធាន |
| ៣ | លោក ប៉ូ ប៊ុន្នួន | អនុប្រធានការិយាល័យសិក្សា | សមាជិក |
| ៤ | លោកបណ្ឌិត ឈាង សង្វាត | គ្រូឧទ្ទេស | សមាជិក |
| ៥ | លោកបណ្ឌិត អាន វ៉ូប្រាវ | គ្រូឧទ្ទេស | សមាជិក |
| ៦ | ល.ស ខែក សំណាង | គ្រូឧទ្ទេស | សមាជិក |

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តមភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥-២៣) ២១៩/៨៨៤ គេហទំព័រ www.nie.edu.kh

II. **លេខាគត់ត្រា** (កត់ត្រាមតិយោបល់គណៈកម្មការវាយតម្លៃ បូកសរុបពិន្ទុ និងបញ្ចូលមធ្យមភាគក្នុងតារាងពិន្ទុ)

**ក្រុមទី១**

| | | | |
|---|---|---|---|
| ១ | លោក ចាប រតនា | អនុប្រធានដេប៉ាតឺម៉ង់ផែនការ | ប្រធាន |
| ២ | លោក លន លីណា | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |
| ៣ | ល.ស សុខ វណ្ណា | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |

**ក្រុមទី២**

| | | | |
|---|---|---|---|
| ១ | លោក ឡុច ចាន់ថន | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | ប្រធាន |
| ២ | លោក ចាន់ ធឿន | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |
| ៣ | លោក ម៉ែន សុខសុន្ទី | មន្ត្រីដេប៉ាតឺម៉ង់ផែនការ | សមាជិក |

III. **អ្នកសម្របសម្រួល** (រៀបចំលិខិតបទដ្ឋាន ដំណើរការកម្មវិធី និងបូកសរុបរបាយការណ៍)

| | | | |
|---|---|---|---|
| ១ | លោក លឹម វ៉ាន់ | អនុប្រធានដេប៉ាតឺម៉ង់ផែនការ | ប្រធាន |

ថ្ងៃពុធ ៤រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**កន្លែងទទួល៖**

-នាយក នាយករង នាយិការងវដអ "ដើម្បីជ្រាបជាព័ត៌មាន និងអនុវត្ត"
-ប្រធានដេប៉ាតឺម៉ង់-ការិយាល័យក្រោមឱវាទវដអ "ដើម្បីសហការ"
-សាមីជន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារ៖ ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការវដអ

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ **កើត មាយលក្ខិណា** មានចិត្តអំណរដ៏ជ្រាលជ្រៅដែលទទួលបានសមិទ្ធិផលក្នុងពេលនេះដោយមានការជ្រោមជ្រែងពីការរៀបចំគំនិតផ្តួចផ្តើមពីគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយវិទ្យាស្ថានអប់រំជាតិ បង្កើតការបណ្តុះបណ្តាលវគ្គវិជ្ជាជីវៈនាយកសាលា ដើម្បីពង្រឹងគុណភាពវិស័យអប់រំ ។ លទ្ធផលដែលបាន សម្រេចចេញជាផ្លែផ្កានេះ ក្រោមការចាត់ចែងពីនាយកដ្ឋានផែនការនៃវិទ្យាស្ថានជាតិអប់រំដែលបានខិតខំប្រឹងប្រែងរកគ្រូមានបទពិសោធន៍ និងចំណេះដឹងច្រើនក្នុងផ្ទេរមកឱ្យនាងខ្ញុំទាំងនេះហើយសូមទទួលការគោរពពីនាងខ្ញុំ នឹងដឹងគុណដែលមិនអាចបភ្លេចបានក្នុងឆាកជីវិតរស់នៅរបស់នាងខ្ញុំ។

ការទទួលបានលទ្ធផលជាផ្លែផ្កានេះ បើសិនជាគ្មានការជួយជ្រោមជ្រែងពីការបង្ហាត់បង្ហាញផ្លូវពីសំណាក់លោកគ្រូ **ម៉ៅ សារឿន** ដែលជាគ្រូដឹកនាំទេ ការសរសេរនិក្ខេបទនេះ មិនអាចធ្វើចេញបានឡើយនាងខ្ញុំសូមគោរពអរគុណដល់លោកគ្រូដឹកនាំដែលគាត់បានចំណាយពេលវេលាដ៏មានតម្លៃក្នុងការពន្យល់ណែនាំ និងផ្តល់យោបល់ល្អៗរហូតដល់ការសរសេរនិក្ខេបបទទួលបានជោគជ័យ។

លោកឪពុក **កើត សារុន** និងអ្នកម្តាយ **អ៊ុយ សារុម** បានផ្តល់អ្វីគ្រប់យ៉ាងដល់នាងខ្ញុំមានទាំងរូបកាយព្រលឹង ក្រោមការថែរក្សារបស់អ្នកទាំងពីរ និងការប្រឹងប្រែងយ៉ាងហត់នឿយរបស់ពួកគាត់ជិតអស់មួយជីវិតក្នុងការចិញ្ចឹមថែរក្សានាងខ្ញុំ និងផ្តល់ការគ្រាំទ្រលើកទឹកចិត្តដល់នាងខ្ញុំក្នុងការបំពេញការសិក្សា និងទទួលបានចំណេះដឹងពេញមួយជីវិត សូមព្រះរស់ទាំងពីរនាក់ទទួលការក្រាបថ្វាយបង្គំពីនាងខ្ញុំ។

នាងខ្ញុំអាចឈរមកត្រឹមនេះបានក៏មានការចូលរួមពីសំណាក់លោកគ្រូ-អ្នកគ្រូ ចាប់តាំងពីសាលាមត្តេយ្យរហូតដល់ពេលនេះព្រមទាំងមិត្តទាំងអស់របស់នាងខ្ញុំដែលក្នុងកំឡុងពេលសិក្សានេះ បានផ្តល់យោបល់ឱ្យនាងខ្ញុំសម្រាប់ការសិក្សាវគ្គវិជ្ជាជីវៈនាយកសាលារហូតបានបញ្ចប់។

នាងខ្ញុំសូមថ្លែងអំណគុណដល់មន្ទីរក្រសួង អប់រំ យុវជន និងកីឡា នៅភ្នំពេញ ការិយាល័យអប់រំក្រុងនិងខណ្ឌ លោកនាយក / លោកស្រីនាយិកា/ នាយករង/ នាយិការងសាលាទាំងអស់គ្នា និងលោកគ្រូ- អ្នកគ្រូ

នៅតាមសាលាគោដៅទាំងអស់ដែលបានអនុញ្ញាត និងចូលរួមសហការពេលដែលនាងខ្ញុំបានចុះទៅប្រមូលទិន្ន័យ ហើយធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់ នាងខ្ញុំសូមប្រសិទ្ធពរជ័យ ជូនចំពោះឯកឧត្តម លោក-លោកស្រីសាស្ត្រាចារ្យ លោក- លោកស្រី នាងកញ្ញា និងមិត្តរួមជំនាន់ទាំងអស់សូមទទួលបានសុខភាពល្អ កម្លាំងមាំមួន ប្រកបការងារទទួលបានជោគជ័យគ្រប់ភារកិច្ច ព្រមទាំងទទួលបាននូវពុទ្ធពរជ័យទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មូលន័យសង្ខេប

ការស្រាវជ្រាវនេះ ផ្តោតទៅលើស្ថានភាព នៃការប្រើប្រាស់គ្រូបង្រៀននៅតាមអនុវិទ្យាល័យនានា ក្នុងប្រទេសកម្ពុជា ក្នុងគោលបំណងរកឱ្យឃើញពីស្ថានភាព និងបញ្ហាប្រឈមនៃការបែងចែក និងប្រើប្រាស់គ្រូបង្រៀននាពេលបច្ចុប្បន្ន សំដៅលើកកម្ពស់ការប្រើប្រាស់ និងការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព។ ដើម្បីសម្រេចបាននូវគោលបំណងនេះ វិធីសាស្ត្រប្រមូលទិន្នន័យត្រូវបានធ្វើឡើងតាមបែបបរិមាណវិស័យ និងគុណវិស័យ។ ទិន្នន័យបរិមាណវិស័យ ត្រូវបានប្រមូលតាមរយៈកម្រងសំណួរបំពេញ និងស្ថិតិរបស់សាលា វិភាគតាមបែបកម្មវិធី Excel ។ រីឯ ទិន្នន័យគុណវិស័យត្រូវបានប្រមូលតាមរយៈការសម្ភាសផ្ទាល់មាត់ និងវិភាគតាមការធ្វើចំណាត់ថ្នាក់ជាក្រុមដោយផ្អែកទៅលើទស្សនៈ និងចម្លើយដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា រួចធ្វើការបរិយាយ និងពន្យល់តាមចំណាត់ថ្នាក់នៃក្រុមនីមួយៗ។ ការស្រាវជ្រាវនេះ បានបង្ហាញនូវលទ្ធផលដូចតទៅ៖ (១)ស្ថានភាព នៃការបែងចែក និងប្រើប្រាស់គ្រូបង្រៀននៅតាមអនុវិទ្យាល័យនានា នាពេលបច្ចុប្បន្នមិនទាន់មានប្រសិទ្ធភាពនៅឡើយ ពោលគឺនៅលើសគ្រូដែលមានកម្រិតគុណវុឌ្ឍិមូលដ្ឋានច្រើន (២)អនុវិទ្យាល័យខ្លះមានគ្រូឯកទេសលើសពីតម្រូវការ ហើយអនុវិទ្យាល័យខ្លះទៀតបែរជាមានគ្រូឯកទេសតិចជាងតម្រូវការទៅវិញ(៣)ចំនួនសិស្ស-ថ្នាក់មិនទាន់អនុវត្តបានតាមនិយាមដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា (៤)ការអនុវត្តម៉ោងបង្រៀនក្នុងមួយសប្តាហ៍មិនទាន់សមស្របតាមនិយាម (៥)ការប្រើប្រាស់គ្រូបង្រៀនខុសជំនាញឯកទេស ត្រូវបានអនុវត្តដើម្បីដោះស្រាយបញ្ហាប្រឈមនៃការលើសគ្រូបង្រៀនធ្វើឱ្យគុណភាពនៃការអប់រំនៅមានកម្រិត។

# មាតិកា

**សេចក្តីអះអាងរបស់បេក្ខជន** ........ i
**លិខិតបញ្ជាក់** ........ ii
**សូមបញ្ជាក់ និងទទួលស្គាល់** ........ iv
**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ** ........ IV
**សេចក្តីថ្លែងអំណរគុណ** ........ vi
**មូលន័យសង្ខេប** ........ viii
**មាតិកា** ........ ix
**ជំពូកទី១៖ សេចក្តីផ្តើម** ........ 1
**១.១ សាវតា** ........ 1
**១.២ .ចំណោទបញ្ហានៃការស្រាវជ្រាវ** ........ 3
**១.៣. គោលបំណងនៃការស្រាវជ្រាវ** ........ 3
**១.៤ .សំណួរនៃការស្រាវជ្រាវ** ........ 4
**១.៥. សារៈសំខាន់នៃការស្រាវជ្រាវ** ........ 4
**១.៦ .ដែនកំណត់ និងវិសាលភាពក្នុងការស្រាវជ្រាវ** ........ 4
**១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** ........ 5
**២.១ .ស្ថានភាពគ្រូបង្រៀននៅកម្ពុជា** ........ 6
**២.២. គោលនយោបាយស្តីពីគ្រូបង្រៀន** ........ 7
*២.២.១ ចក្ខុវិស័យ* ........ 7
*២.២.២ គោលបំណង* ........ 7
*២.២.៣ គោលដៅ* ........ 7
*២.២.៤ យុទ្ធសាស្ត្រ* ........ 8
*២.២.៥. និយមន័យពាក្យគន្លឹះ* ........ 11
**២.៣. ការប្រើប្រាស់គ្រូបង្រៀន** ........ 12

*២.៣.១ និយាមប្រើប្រាស់គ្រូ* ........ 12

**២.៤ .បញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀន** ........ 14

**២.៥ យុទ្ធសាស្ត្រក្នុងការដោះស្រាយ** ........ 15

*២.៥.១ ករណីសាលាខ្វះគ្រូ* ........ 16

**២.៦ ភាពជាអ្នកដឹកនាំរបស់គណៈនាយក** ........ 18

**២.៧ .ការដោះស្រាយបញ្ហានៅសាលារៀន** ........ 23

**ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ** ........ 26

**៣.១ គម្រោងវិភាគ** ........ 27

**៣.២ វិធីសាស្ត្រប្រមូលទិន្នន័យ** ........ 27

**៣.៣.ឧបករណ៍ស្រាវជ្រាវ** ........ 28

*៣.៣.១ កម្រិតចង្អុលបង្ហាញ* ........ 28

*៣.៣.២ កម្រងសំណួរ* ........ 29

**៣.៤ ការជ្រើសរើសភាគសំណាក** ........ 29

**៣.៥ ការវិភាគទិន្នន័យ** ........ 30

**៣.៦ ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ** ........ 30

**ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា** ........ 32

**៤.១ ភាកំណត់ពីតម្រូវការប្រើប្រាស់គ្រូនៅរាជធានីភ្នំពេញ** ........ 32

*៤.២.២ . ករណីលើស និងខ្វះគ្រូតាមឯកទេសមុខវិជ្ជា* ........ 33

**៤.២ ករណីសិក្សាខណ្ឌទាំងបី (ខណ្ឌមានជ័យ ពោធិ៍សែនជ័យ និងខណ្ឌព្រែកព្នៅ)** 35

*៤.២.១ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងជាក់ស្តែងនៅខណ្ឌទាំងបីនៃ រាជធានីភ្នំពេញ* ........ 35

*៤.២.២. ករណីលើស និងខ្វះគ្រូតាមឯកទេសមុខវិជ្ជា* ........ 36

*៤.២.៣ ការប្រឈមបញ្ហាក្នុងការប្រើប្រាស់គ្រូបង្រៀន* ........ 38

*៤.២.៤ ដំណោះស្រាយក្នុងការប្រឈមបញ្ហា* ........ 38

*៤.២.៥ អនុសាសន៍របស់ប្រធានការិយាល័យបុគ្គលិកនៃមន្ទីរអប់រំ យុវជន និង កីឡា* ........ 39

ករណីខ្វះគ្រូ ........ 74

**ជំពូក៥ ៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ........ 76

**៥.១. សេចក្តីសន្និដ្ឋាន** ........ 76

**៥.២ .សំណូមពរ** ........ 77

**ឧបសម្ព័ន្ធ** ........ 81

ឧបសម្ព័ន្ធ (ខ) ៖ លិខិតអនុញ្ញាតចុះប្រមូលទិន្នន័យ ........ 85

ឧបសម្ព័ន្ធ(គ)៖ លិខិតឧទ្ទេសនាមចាត់តាំងចុះប្រមូលទិន្នន័យ ........ 86

ឧបសម្ព័ន្ធ(ឃ)៖ លិខិតឧទ្ទេសនាមចាត់តាំងជាគ្រូដឹកនាំ ........ 888

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ ១៣៤ វជអ. ន៨

# លិខិតឧទ្ទេសនាម

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០។

និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្តីពីការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ នៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនាឆ្នាំ ២០២០តទៅ៖

| ល.រ | គោត្តនាម-នាម | ភេទ | រាជធានី ខេត្ត |
|---|---|---|---|
| 1 | សុខ ផល្លី | ស | កណ្តាល |
| 2 | ទុន វណ្ណៈ | ប | កណ្តាល |
| 3 | វង់ ប៊ុនថាន | ប | កែប |
| 4 | គុយ សេងលី | ប | កំពង់ចាម |
| 5 | សំរ៉េត ពេជ្រតា | ស | កំពង់ចាម |
| 6 | ឈាង សោភា | ប | កំពង់ធំ |
| 7 | ពេជ្រ ចំរុង | ប | កំពង់ធំ |
| 8 | ប៊ុត សមពីសិទ្ធ | ប | កំពង់ស្ពឺ |
| 9 | លាង លីលី | ប | កំពង់ស្ពឺ |
| 10 | ជិន សុធី | ប | តាកែវ |
| 11 | មាន់ ម៉ៅ | ប | តាកែវ |
| 12 | មៀង ង៉ុន | ប | ត្បូងឃ្មុំ |
| 13 | យាន ពិសិដ្ឋ | ប | ត្បូងឃ្មុំ |
| 14 | ឆាន ឆាត | ប | បន្ទាយមានជ័យ |

| | | | |
|---|---|---|---|
| 15 | ឌី សុផល | ប | បន្ទាយមានជ័យ |
| 16 | ជាច់ សន | ប | ប៉ៃលិន |
| 17 | សុត សំអូន | ប | ពោធិ៍សាត់ |
| 18 | ហួន ស៊ីថា | ប | ពោធិ៍សាត់ |
| 19 | ប៊ិន សុផាន់ណាក់ | ប | ព្រៃវែង |
| 20 | សេ សាយ៉ាន | ស | ព្រៃវែង |
| 21 | សូ ស៊ីណា | ប | ព្រះសីហនុ |
| 22 | កើត មាយលក្ខិណា | ស | ភ្នំពេញ |
| 23 | សុន នីណា | ស | ភ្នំពេញ |
| 24 | ម៉ោញ វង្ខា | ស | មណ្ឌលគិរី |
| 25 | កែវ សុខជា | ប | ស្ទឹងត្រែង |
| 26 | រួច រី | ប | សៀមរាប |
| 27✓ | ឌុ សុខា | ប | ស្វាយរៀង |
| 28 | អ៊ិក សម្ផស្ស | ស | ស្វាយរៀង |
| 29 | វៃន សុធី | ប | ឧត្តរមានជ័យ |

ថ្ងៃអង្គារ ៩កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត សៀង សុវណ្ណា

**កន្លែងទទួល៖**

- -ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- -អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អយក "ដើម្បីជាព័ត៌មាន"
- - មន្ទីរអយក រាជធានី ខេត្ត "ដើម្បីសហការ"
- - សាមីជន "ដើម្បីអនុវត្ត"
- -កាលប្បវត្តិ
- -ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

# ជំពូកទី១៖ សេចក្តីផ្តើម

## ១.១ សាវតា

ការរីកចម្រើនរបស់សង្គមខ្មែរ កាលពីសម័យមុនដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញរន្ទឺនៅអាស៊ីអាគ្នេយ៍ភាគខាងត្បូងជាអាណាចក្រខ្មែរ ដែលមានប្រទេសដទៃទៀតស្ថិតនៅក្រោមចំណុះការដឹកនាំរបស់ព្រះមហាក្សត្រខ្មែរ ដែលសម្បូរដោយសម្បត្តិធម្មជាតិ និងជាពិសេសធនធានមនុស្សពោរពេញដោយសមត្ថភាពបានធ្វើឲ្យសង្គមខ្មែរមានវប្បធម៌លូតលាស់ ហើយក្លាយទៅជាប្រទេសអច្ឆរិយៈនៅភូមិភាគអាស៊ី។ ប៉ុន្តែក្រោយមកទៀត សង្គ្រាមនៃការដណ្តើមអំណាចផ្ទៃក្នុង សង្គ្រាមសាសនា គ្រោះធម្មជាតិ សង្គ្រាមវាទទី ដែលធ្វើឱ្យមានការកៀសខ្លួនជនជាតិភាគតិចរបស់ចិនមានដូចជា សៀម ឡាវ និងវៀតណាមទាំងអស់នេះជាមូលហេតុនៃការធ្លាក់ចុះនៃអាណាចក្រខ្មែរ ចាប់តាំងពីឆ្នាំ១៤៣២ ហើយការផ្លាស់ប្តូររាជធានីមានជាញឹកញាប់រហូត ដល់ឆ្នាំ១៨៦៦ ។ មិនត្រឹមតែប៉ុណ្ណោះទេអាណាចក្រខ្មែរដែលធ្លាប់តែគ្រប់គ្រងប្រទេសដទៃទៀត ក្លាយទៅជាប្រទេសដែលត្រូវគេដាក់ចំណុះវិញដែលស្ថិតក្រោមការដឹកនាំ ម្តងសៀម ម្តងយួន ហើយទីបំផុតគឺស្ថិតនៅក្រោមនឹមអាណានិគមបារាំងនៅឆ្នាំ១៨៦៣ សង្គ្រាមមិនចេះចប់នៃប្រទេសកម្ពុជា ត្រូវបានបំផ្លាញយ៉ាងខ្ទេចខ្ទីរួមជាមួយធនធានមនុស្ស អ្វីដែលគួរឱ្យខ្លោចផ្សាជាងនេះទៅទៀតក្នុងចន្លោះឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩ គិតទៅបួនឆ្នាំប្រាំបីខែ ខ្មែរត្រូវបាត់បង់ប្រជាជនមួយភាគបួននៃប្រជាជន សរុប៨លាននាក់ ដោយសាតែរបបខ្មែរក្រហមក្រោយពីឆ្នាំ១៩៧៩ ។ ខ្មែរត្រូវក្រោកឈរទាំងបាតដៃទទេក្នុងការកសាងសង្គមខ្មែរជាថ្មី ដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស ក្នុងពេលនោះត្រូវប្រើពាក្យស្លោកថាអ្នកចេះច្រើនបង្រៀនអ្នកចេះតិច អ្នកចេះតិចបង្រៀនអ្នកមិនចេះសោះ រហូតដល់ឆ្នាំ១៩៩៨ ទើបខ្មែរទទួលបានសន្តិភាពពេញលេញហើយមកដល់ពេលនេះគ្រប់ទីកន្លែងមានឮពាក្យថា អរគុណសន្តិភាព។

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ទិសដៅថា ឆ្នាំ២០៣០ ដើម្បីឱ្យកម្ពុជាសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ដើម្បីសម្រេចទិសដៅនេះក្រសួងអប់រំ

យុវជន និងកីឡា(១)។ បានដាក់គោលនយោបាយក្នុងការពង្រឹងគុណភាពអប់រំ និងធ្វើកំណែទម្រង់ក្នុងការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកម្ពស់គុណភាពអប់រំដូចជា សិទ្ធិទទួលបានតម្លៃវិជ្ជាជីវៈ សិទ្ធិអភិវឌ្ឍន៍ខាងវិជ្ជាជីវៈ និងការបំពេញកាតព្វកិច្ចផ្សេងទៀត(២)។ ក្នុងគោលនយោបាយទាំងពីររបស់ក្រសួងអប់រំ យុវជន និងកីឡា មានគោលនយោបាយទី២ បានចែងថា ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ការផ្តល់សេវាអប់រំ និងផ្តល់ឱ្យប្រកបដោយប្រសិទ្ធភាព។ ការគ្រប់គ្រងដោយប្រសិទ្ធភាព និងវិជ្ជាជីវៈខ្ពស់ គឺត្រូវផ្តល់តម្លៃខ្ពស់បំផុតដល់ការតាមដាន និងការកែលម្អ (ផ្តោតលើលទ្ធផល)ទាន់ពេលវេលា។ រីឯគ្រូបង្រៀនត្រូវបណ្តុះបណ្តាលឱ្យមានមនសិការវិជ្ជាជីវៈ មានសមត្ថភាពខ្ពស់ក្នុងការបង្រៀននិងរៀនតាមមុខជំនាញឯកទេសនីមួយៗស្របតាមស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនពោលគឺ ស្តង់ដារចំណេះដឹងវិជ្ជាជីវៈ ស្តង់ដារប្រតិបត្តិវិជ្ជាជីវៈ ស្តង់ដារសិក្សាវិជ្ជាជីវៈ និងស្តង់ដារសីលធម៌ (៣)។

បច្ចុប្បន្ន នេះ ក្រសួងអប់រំ យុវជន និងកីឡា គ្រប់គ្រងមន្ត្រីរាជការជាង៦០ភាគរយនៃចំនួនមន្ត្រីរាជការស៊ីវិលក្នុងព្រះរាជណាចក្រកម្ពុជា។ ក្នុងឆ្នាំសិក្សា២០១៥ ដល់ឆ្នាំ ២០១៦ ក្រសួងមានបុគ្គលិកអប់រំទាំងអស់បង្រៀន និងមិនបង្រៀន សរុបចំនួន១១៥៣០៥ នាក់ស្រី ៥០១៤៥ នាក់ ក្នុងបុគ្គលិកបម្រើការអប់រំថ្នាក់ជាតិមានចំនួន៣០៥១នាក់ ស្រីមានចំនួន៨២៥ នាក់ ថ្នាក់ក្រោមជាតិមានចំនួន១១២២៥៤នាក់ ស្រីមានចំនួន៤៩៣២០នាក់ គ្រូមត្តេយ្យសិក្សាមានចំនួន៣៣៦៩នាក់ ស្រីមានចំនួន៣៣០១នាក់ គ្រូកម្រិតមូលដ្ឋានមានចំនួន៤១៤៦៤នាក់ ស្រីមានចំនួន១៦០០៥នាក់ អធិការបឋមសិក្សាអធិការមធ្យមសិក្សាមានចំនួន១១៩ នាក់ ស្រីមានចំនួន២៧នាក់ គ្រូបង្រៀនកម្រិតឧត្តមមានចំនួន១៣៧៥១នាក់ ស្រី៣៨៥៨ នាក់ នៅក្នុងឆ្នាំសិក្សា២០១៤ ដល់ឆ្នាំ២០១៥ ក្រសួងប្រើប្រាស់គ្រូបង្រៀនជាពីរវេន និងគ្រូបង្រៀនថ្នាក់គួប ចំនួន២០០៦៨ នាក់ ស្រី៨៥៣៤នាក់ គ្រូអក្ខរកម្មជាប់កិច្ចសន្យាចំនួន៤៤១៧នាក់ ស្រី១៥៦២នាក់ និងគ្រូបម្រើការងារនៅតំបន់ដាច់ត្រយាល និងតំបន់ជួបការលំបាកចំនួន៣៣៤១៧នាក់ ស្រី១៣០៣៧នាក់ (៤)។

## ១.២ .ចំណោទបញ្ហានៃការស្រាវជ្រាវ

ចាប់តាំងពីឆ្នាំ២០១៤ ក្រសួង អប់រំ យុវជន និងកីឡា បានចេញគោលនយោបាយជាច្រើនដើម្បីឈានទៅធ្វើការកំណែទម្រង់វិស័យអប់រំ ដើម្បីដោះស្រាយបញ្ហាដែលសាធារណៈជនរិះគន់ថាកំពុងធ្លាក់ចុះយ៉ាងគំហុក។ ក្រោមកំណែទម្រង់របស់វិស័យអប់រំ បានដាក់ចេញគោលនយោបាយដូចជាគោលនយោបាយអប់រំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤ ដល់ឆ្នាំ២០១៨ ធានាភាពស័ក្តសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ។ ក្រសួង អប់រំ យុវជន និងកីឡា បានដាក់ចេញសសរស្តម្ភទាំង៨ ដែលបានដាក់ចេញការអនុវត្តផែនការសកម្មភាពគោលនយោបាយ នឹងធានាឱ្យគ្រូបង្រៀនមនចំណេះដឹង ជំនាញ សីលធម៌ និងសមត្ថភាព អនុវត្តវិជ្ជាជីវៈតាមរយៈការបណ្តុះបណ្តាលមុនពេលបំពេញការងារ ការគ្រប់គ្រងគ្រូបង្រៀន ការពង្រាយគ្រូ និងយន្តការផ្ទេរគ្រូបង្រៀនរៀបចំមាគ៌ាអាជីពគ្រូ ដើម្បីឈានរកការអភិវឌ្ឍផ្នែកវិជ្ជាជីវៈ និងការបន្តការវិវត្តអជីពគ្រូ ធ្វើប្រតិភូកម្មការជ្រើសរើស និងការគ្រប់គ្រងគ្រូទៅក្រោមថ្នាក់ ។ អាទិភាពមួយក្នុងចំណោមអាទិភាពទាំង ១៥ នៃការកែទម្រង់ ក្រសួងអប់រំ យុវជន និងកីឡា គឺការពង្រាយគ្រូបង្រៀន មុននឹងអាចអនុវត្តបានការពង្រាយគ្រូនេះ មុនដំបូងគេត្រូវយល់ពីស្ថានភាពការប្រើប្រាស់គ្រូបង្រៀនតាមគ្រឹះស្ថានអប់រំនីមួយៗ ដើម្បីស្វែងរកឱ្យឃើញការបែងចែកភារកិច្ច និងម៉ោងបង្រៀនរបស់គ្រូបង្រៀនម្នាក់ៗត្រឹមត្រូវតាមឯកទេសស្របតាមនិយាមគរុគោសល្យ ដែលក្រសួង អប់រំ យុវជន និងកីឡា ចង់បានឬនៅ? ដោយសារមូលហេតុខាងលើនេះទើបនាងខ្ញុំបានលើកប្រធានបទមួយ ដែលបង្ហាញពីស្ថានភាព និងបញ្ហាប្រឈមនានាក្នុងការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យនានានៅរាជធានីភ្នំពេញ ។

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

១. សិក្សាពីស្ថានភាពនៃការប្រើប្រាស់គ្រូអនុវិទ្យាល័យនៅរាជធានីភ្នំពេញ

២. ស្វែងរកពីបញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀន

៣. ស្វែងរកដំណោះស្រាយក្នុងការប្រើប្រាស់គ្រូបង្រៀន

## ១.៤ .សំណួរនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះប្រធានបទនេះមាន៖

- តើការប្រើប្រាស់គ្រូអនុវិទ្យាល័យនៅរាជធានីភ្នំពេញមានស្ថានភាពដូចម្តេច ?
- តើជួបបញ្ហាប្រឈមអ្វីខ្លះក្នុងការប្រើប្រាស់គ្រូបង្រៀន?
- តើគណៈគ្រប់គ្រងសាលារៀន មានដំណោះស្រាយក្នុងការប្រើប្រាស់គ្រូបង្រៀនអនុវិទ្យាល័យយ៉ាងដូចម្តេច?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សានេះនឹងបង្ហាញពីស្ថានភាពនៃការប្រើប្រាស់គ្រូនៅអនុវិទ្យាល័យក្នុងរាជធានីភ្នំពេញ។ លទ្ធផលនៃការស្រាវជ្រាវនេះ នឹងក្លាយជាពត៌មានដ៏សំខាន់សម្រាប់ជាជំនួយដល់ ក្រសួង មន្ទីរ អប់រំ យុវជន និងកីឡា ក្នុងការពង្រឹងគោលការណ៍ទៅលើការពង្រាយ ការបែងចែង គ្រូបង្រៀនឱ្យកាន់តែមានប្រសិទ្ធភាពទៅតាមសាលានីមួយៗ នៅទូទាំងប្រទេសកម្ពុជា។ ម៉្យាងវិញទៀត ការសិក្សាស្រាវជ្រាវនេះក៏អាចជាផ្នែកមួយនៃការចែករំលែកនូវបទពិសោធន៍ និងព័ត៌មានល្អៗ សម្រាប់គណៈនាយក ក្នុងការប្រមើលមើលនូវរាល់ចំណុច អវិជ្ជមានផ្សេងៗដែលធ្វើឲ្យការអប់រំមិនទទួលបាននូវគុណភាព។ លើសពីនេះទៅទៀត ការស្រាវជ្រាវនេះក៏អាចជាទុនមួយសម្រាប់អ្នកសិក្សាជំនាន់ក្រោយអាចយកទៅសិក្សាកាន់តែស៊ីជម្រៅបន្ថែមទៀត។

## ១.៦ .ដែនកំណត់ និងវិសាលភាពក្នុងការស្រាវជ្រាវ

ប្រធានបទនៃការប្រើប្រាស់គ្រូនៅអនុវិទ្យាល័យធ្វើឡើងនៅអនុវិទ្យាល័យក្នុងខណ្ឌ៣ក្នុងខណ្ឌទាំង១៤នៃរាជធានីភ្នំពេញ និងស្រង់ទិន្ន័យថ្នាក់សិស្សពីថ្នាក់ទី៧ដល់ថ្នាក់ទី៩ ចំនួនគ្រូកម្រិតមូលដ្ឋាន ១២+២ ព្រមទាំង ចំនួនម៉ោងរបស់លោកគ្រូ អ្នកគ្រូនៅតាមអនុវិទ្យាល័យនានាៗនៅក្នុងរាជធានីភ្នំពេញ។

## ១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះត្រូវបានបែងចែកជា៥ជំពូកធំៗដូចខាងក្រោមនេះ៖

**ជំពូកទី១៖** សេចក្តីផ្តើម នៅក្នុងជំពូកទី១រួមមាន សាវតា លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី២៖** រំលឹកទ្រឹស្តី នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវបានប្រមូលយកទ្រឹស្តីផ្សេងៗពីអ្នកនិពន្ធមុនៗដែលពាក់ព័ន្ធទៅនឹងប្រធានបទសម្រាប់ធ្វើជាអំណះអំណាង និងជាគំនិតសម្រាប់ធ្វើការស្រាវជ្រាវ និងបង្កើតស្នាដៃថ្មីក្នុងប្រធានបទនេះ ។

**ជំពូកទី៣៖** វិធីសាស្ត្រស្រាវជ្រាវក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងបង្ហាញនូវ កម្រិតចង្អុលបង្ហាញ ឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីជ្រើសរើសសំណាក ព្រមទាំងវិធីសាស្ត្រវិភាគទិន្នន័យ ។

**ជំពូកទី៤៖** លទ្ធផលនៃការស្រាវជ្រាវនៅក្នុងជំពូកនេះមាន អ្នកស្រាវជ្រាវនឹងយកទិន្នន័យជាក់ស្តែងដែលប្រមូលបានពីវិភាគ និងបកស្រាយយ៉ាងលម្អិតដើម្បីរកឱ្យ ឃើញភាពអវិជ្ជមានបញ្ហាប្រឈមក្នុងការប្រើប្រាស់បុគ្គលិកកម្រិតមូលដ្ឋាន(អនុវិទ្យាល័យ)នានានៅក្នុងរាជធានីភ្នំពេញ។

**ជំពូកទី៥៖** សេចក្តីសន្និដ្ឋាន និងសំណូមពរ ជាផ្នែកមួយសំខាន់ណាស់ដែលអ្នកស្រាវជ្រាវ ត្រូវធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ទៅយកមកវិភាគ ព្រមទាំងសំណូមពរមួយចំនួនក្នុងគោលបំណងចូលរួមចំណែកធ្វើឱ្យការអនុវត្តបំណែងចែកភារកិច្ចបុគ្គលិកនីមួយៗ តាមអនុវិទ្យាល័យនានានៅក្នុងរាជធានីភ្នំពេញឱ្យកាន់តែល្អប្រសើរថែមទៀត និងដើម្បីបង្កើនសាមគ្គីភាព និងទំនាក់ទំនងល្អថែមទៀតរវាងគណៈគ្រប់គ្រង និងសាមាជិកក្នុងអង្គភាពខ្លួន។

# ជំពូកទី២៖ រំលឹកទ្រឹស្តី

## ២.១ .ស្ថានភាពគ្រូបង្រៀននៅកម្ពុជា

ការអប់រំនៅប្រទេសកម្ពុជាមានការរីកចម្រើនខាងបរិមាណ ជាពិសេសនៅបឋមសិក្សា ប៉ុន្តែនៅមធ្យមសិក្សាវិញ ទាំងបរិមាណ និង គុណភាព នៅតែមានបញ្ហា ដែលបណ្តាលមកពីកត្តាជាច្រើន ជាពិសេសកង្វះគ្រូបង្រៀន អ្នកគ្រប់គ្រងសាលារៀន ឯកទេសអប់រំនៅតាមតំបន់ដាច់ស្រយាលជួបការលំបាក។

កម្ពុជានៅតែប្រឈមនឹងការពង្រឹងគុណភាពគ្រូបង្រៀន រក្សាគ្រូបង្រៀននៅបម្រើការងារក្នុងមុខងារអប់រំបានយូរ ឬរហូតចូលនិវត្តន៍ ។ ក្រសួងអប់រំ យុវជន និងកីឡា បានបាត់បង់បុគ្គលិកអប់រំប្រមាណជាង ២០០០នាក់ក្នុងមួយឆ្នាំដែលក្នុងនោះអ្នកចូលនិវត្តន៍មានប្រមាណ១៥០០នាក់ លុបឈ្មោះចោលពីក្របខណ្ឌចំនួន៥០០នាក់ និង សុំទៅក្រសួងផ្សេង មានចំនួន ២០០នាក់ ទាំងនេះជាកត្តាបាត់បង់បុគ្គលិកអប់រំ។

ការស្រាវជ្រាវជាច្រើនបានពន្យល់ថា គ្រូបង្រៀនដែលមានសញ្ញាបត្រកាន់តែខ្ពស់ ការបង្រៀនកាន់តែមានគុណភាពខ្ពស់ ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ភាគច្រើនគ្រូបង្រៀនសញ្ញាបត្របរិញ្ញាបត្របូក២ ។ ចំណែកឯនៅកម្ពុជាវិញ គ្រូបង្រៀនភាគច្រើនមិនទាន់មានបរិញ្ញាបត្រនៅឡើយ ទោះបីជាការបណ្តុះបណ្តាលគ្រូបង្រៀនមានការការវិវត្តជាច្រើនក៏ដោយ ។ គ្រូបង្រៀនមួយចំនួនដែលក្នុងក្របខណ្ឌអប់រំកាលពីឆ្នាំ១៩៩២-១៩៩៥មានសញ្ញាបត្រ ៨ បូក១ (បង្រៀននៅថ្នាក់មត្តេយ្យ៨បូក២) (បង្រៀននៅកម្រិតបឋមសិក្សា ១១បូក២) (ថ្នាក់មធ្យមសិក្សាបឋមភូមិ ១០បូក៤) និងបរិញ្ញាបត្រ។

គ្រូង្រៀនប្រមាណ១៨០០០នាក់បានបញ្ចប់ការសិក្សាថ្នាក់មហាវិទ្យាល័យ។ គ្រូបង្រៀនមានកម្រិតសិក្សាថ្នាក់វិទ្យាល័យមានចំនួន៥១៨២០នាក់ គ្រូបង្រៀន១៦២៦៧នាក់ទៀត មានកម្រិតសិក្សាថ្នាក់អនុវិទ្យាល័យ ហើយគ្រូបង្រៀនចំនួន១៧៧៥នាក់ប៉ុណ្ណោះដែលបានសិក្សាត្រឹម បឋមសិក្សា( ស្ថិតិនិងសូចនាករអប់រំសាធារណៈ ឆ្នាំ២០១៦-២០១៧)។

រដ្ឋមន្ត្រី ក្រសួងអប់រំ លោក ហង់ ជួនណារ៉ុន បានមានប្រសាសន៍ថា ការជ្រើសរើសគ្រូបង្រៀននេះឱ្យបានគ្រប់គ្រាន់ ដើម្បីជៀសវាងបញ្ហាប្រឈមនិងកាត់បន្ថយហានិភ័យនៅប្រទេសកម្ពុជា ។

## ២.២. គោលនយោបាយស្តីពីគ្រូបង្រៀន

នយោបាយស្តីពីគ្រូបង្រៀនចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ថ្ងៃទី២៧ ខែឧសភា ឆ្នាំ ២០១៣ មានវិសាលភាពលើការអប់រំសាធារណៈ និងឯកជនចាប់ពីមត្តេយ្យសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។

### *២.២.១ ចក្ខុវិស័យ*

គោលនយោបាយនេះមានចក្ខុវិស័យ កសាងគ្រូបង្រៀនឱ្យមានចំណេះដឹង ជំនាញ សីលធម៌ និងមានសមត្ថភាពអនុវត្តវិជ្ជាជីវៈ ដោយមានការទទួលស្គាល់ពីសង្គម ។

### *២.២.២ គោលបំណង*

គោលនយោបាយស្តីពីគ្រូបង្រៀនមានគោលបំណងអភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាព សមត្ថភាព ស្មារតីទទួលខុសត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈ និងផ្តល់លក្ខខណ្ឌចាំបាច់ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ ។

### *២.២.៣ គោលដៅ*

- ទាក់ទាញនិងលើកទឹកចិត្តអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន ។
- ធានាការបណ្តុះបណ្តាលមុនពេលបម្រើការងារជាគ្រូបង្រៀន ។
- ធានាការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនពេលបម្រើការងារជាប់ជាប្រចាំ ។
- ធានាលក្ខខណ្ឌចាំបាច់ចំពោះគ្រូបង្រៀនក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ ។

### *២.២.៤ យុទ្ធសាស្ត្រ*

ដើម្បីសម្រេចគោលបំណង និងគោលដៅខាងលើ យុទ្ធសាស្ត្រសំខាន់ៗមានដូចខាងក្រោមៈ

- ការកសាងលិខិតបទដ្ឋានគតិយុត្តនិងយន្តការ
    - ពិនិត្យឡើងវិញ កែលម្អ និងកសាងលិខិតបទដ្ឋានគតិយុត្ត
    - កសាងយន្តការចាំបាច់សម្រាប់ផ្សព្វផ្សាយ អនុវត្ត គាំទ្រ ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ
    - កសាងផែនការសកម្មភាពជាក់លាក់ និងកម្មវិធីលម្អិតដើម្បីអនុវត្តគោលនយោបាយ ។
- ទាក់ទាញអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន
    - លើកកម្ពស់ជីវភាព តម្លៃវិជ្ជាជីវៈ សេចក្ដីថ្លៃថ្នូរ និងការយកចិត្តទុកដាក់ពីសង្គម
    - លើកកម្ពស់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន
    - កំណត់លក្ខណៈវិនិច្ឆ័យ និងលក្ខខណ្ឌតម្រូវខាងវិជ្ជាជីវៈសម្រាប់ការជ្រើសរើស
    - ធ្វើទំនើបកម្មស្តង់ដារកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់ជាតិ និងការប្រកួតប្រជែងក្នុងតំបន់ និងសកលលោក ។
- កំណត់ស្តង់ដារប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន
    - ធ្វើបច្ចុប្បន្នភាពប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន
    - បង្កើនប្រសិទ្ធភាពកម្មសិក្សាមុនពេលតាំងស៊ប់ក្នុងក្របខណ្ឌ
    - កំណត់ស្វ័យភាពរបស់គ្រូបង្រៀន
- អភិវឌ្ឍន៍គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ
    - អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន
    - ប្រែក្លាយសាលាគរុកោសល្យឱ្យទៅជាមជ្ឈមណ្ឌលអភិវឌ្ឍន៍គ្រូបង្រៀន

- បង្កើនគុណវុឌ្ឍិនិងបទពិសោធន៍បុគ្គលិកអប់រំនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍គ្រូបង្រៀន
- ពង្រឹងមុខងាររបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍គ្រូបង្រៀនដើម្បីបន្តអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀន

❖ ធ្វើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា

- ធ្វើទំនើបកម្មផែនការតម្រូវការនិងផ្គត់ផ្គង់គ្រូបង្រៀនសម្រាប់ការបណ្ដុះបណ្ដាលមុនពេលបម្រើការងារ
- ពង្រឹងប្រសិទ្ធភាពការប្រើប្រាស់គ្រូបង្រៀនតាមនិយាមប្រើប្រាស់ និងតាមគោលការណ៍
- លើកកម្ពស់ដំណើរការ និងនីតិវិធីនៃការជ្រើសរើស និងរក្សាទុកគ្រូបង្រៀនដែលមានស្នាដៃល្អសម្រាប់ធានានិរន្តរភាពគ្រឹះស្ថានសិក្សា
- ធ្វើប្រតិភូកម្មជ្រើសរើសនិងការគ្រប់គ្រងគ្រូបង្រៀនទៅថ្នាក់ក្រោមជាតិតាមគោលការណ៍កំណត់
- លើកកម្ពស់ការចូលរួមរបស់គណៈកម្មការទ្រទ្រង់សាលារៀន និងអ្នកពាក់ព័ន្ធក្នុងការបង្កើនសម្មិទ្ធផលសិក្សារបស់សិស្ស ។

❖ អភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារ

- បណ្ដុះវប្បធម៌រៀនពេញមួយជីវិតដោយចេះចែករំលែកចំណេះដឹងនិងបទពិសោធន៍ជាមួយបណ្ដាញក្រុមអ្នកអប់រំ
- រៀបចំយន្តការប្រេកបដោយប្រសិទ្ធភាពដើម្បីគាំទ្រគ្រូបង្រៀននៅនឹងកន្លែងធ្វើការ
- រៀបចំគោលការណ៍ណែនាំស្ដីពីតម្រូវការនិងផលប្រយោជន៍នៃការអភិវឌ្ឍវិជ្ជាជីវៈ ។

❖ លើកទឹកចិត្ត និងរក្សាទុកគ្រូបង្រៀន

- o លើកកម្ពស់លក្ខខណ្ឌធ្វើការងារនិងរស់នៅរបស់គ្រូបង្រៀនតាមរយៈការផ្តល់បៀវត្សរ៍ លាភការ សុខុមាលភាពសង្គម អត្ថប្រយោជន៍ទូទៅ និងអត្ថប្រយោជន៍ពេលចូលនិវត្តន៍ ជាពិសេសអ្នកគ្រូ និងគ្រូបង្រៀនបម្រើការងារនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក
- o ទទួលស្គាល់និងជូនរង្វាន់ដល់គ្រូបង្រៀនដែលមានស្នាដៃល្អ
- o លើកកម្ពស់ភាពរីកចម្រើននៃអាជីព ស្វ័យភាព និងការសម្រេចចិត្តក្នុងវិជ្ជាជីវៈរបស់គ្រូបង្រៀនដែលកំណត់ក្នុងច្បាប់សំដៅកែលម្អលទ្ធផលសិក្សារបស់សិស្ស ។

❖ ពង្រឹងប្រសិទ្ធភាពភាពជាអ្នកដឹកនាំសាលារៀន

- o ពង្រឹងយន្តការភាពជាអ្នកដឹកនាំសាលារៀនឱ្យមានប្រសិទ្ធភាព
- o ធានាសិទ្ធិរបស់គ្រូបង្រៀនស្របតាមច្បាប់ស្តីពីការអប់រំ
- o ធ្វើឱ្យប្រសើរឡើងលក្ខខណ្ឌតម្រូវខាងវិជ្ជាជីវៈសម្រាប់ជ្រើសរើស បណ្តុះបណ្តាល បំពេញការងារ និងផលប្រយោជន៍សម្រាប់គ្រូឧទ្ទេស និងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ
- o កំណត់ និងអនុវត្តវិធានការរដ្ឋបាលដល់គ្រូបង្រៀន គ្រូឧទ្ទេស និងគណៈគ្រប់គ្រងនៃគ្រឹះស្ថានសិក្សាសាធារណៈ សំដៅធានាការអនុវត្តគោលការណ៍និងបំពេញតាមលក្ខខណ្ឌតម្រូវនៃច្បាប់

❖ ពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃគ្រូបង្រៀន

- o បង្កើនប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងព័ត៌មានគ្រូបង្រៀន
- o បង្កើតនិងប្រើប្រាស់យន្តការពិនិត្យតាមដាន និងវាយតម្លៃដើម្បីកែលម្អលទ្ធផលបំពេញការងាររបស់គ្រូបង្រៀន
- o បង្កើនប្រសិទ្ធភាពការប្រើប្រាស់លទ្ធផលវាយតម្លៃការប្រតិបត្តិរបស់គ្រូបង្រៀនដើម្បីអភិវឌ្ឍសមិទ្ធិអប់រំ

- o កំណត់សិទ្ធិគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈក្នុងការធ្វើសេចក្ដីសម្រេចលើការគ្រប់គ្រងអភិវឌ្ឍអង្គភាព ។

### *២.២.៥. និយមន័យពាក្យគន្លឹះ*

ស្ថានភាព គឺទីតាំងស្ថិតនៅពិតប្រាកដ អាកប្បកិរិយា ហេតុភេទ ដំណើរទំនង បែបបទ ដើងការ ដំណើរការណ៍ដែលប្រព្រឹត្តទៅ (ជួន ណាត ១៩៦៧)។

**ការប្រើ**ប្រាស់ (Utilization) គឺជាការប្រើរបស់អ្វីមួយតាមរបៀបដែលមានប្រសិទ្ធភាព នេះបើយោងតាម CambridgeDictionary (https://dictionary.cambridge.org/dictionary/english/utilization) ។

**គ្រូ** គឺជាអ្នកដែលមានចិត្តធូន់ អ្នកដែលគួរគេគោរព គឺអ្នកបង្ហាត់បង្រៀនចំណេះវិជ្ជាសិល្បៈសាស្ត្រផ្សេងៗ ដល់សិស្ស (ជួន ណាត ១៩៦៧)។

**គ្រូបង្រៀន** សំដៅដល់បុគ្គលិកបង្រៀននៃបុគ្គលិកអប់រំនៅគ្រឹះស្ថានសាធារណៈ និងគ្រឹះស្ថានឯក-ជន ដែលមានអាជ្ញាប័ណ្ណអប់រំ នេះបើយោងតាមមាត្រាទី៤ នៃអនុក្រឹត្យលេខ ១២៦.អនក្រ.បក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ ២០០៨ ។ មាត្រា២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤១ ស្ដីពីលក្ខន្តិកៈដោយឡែកនៃគ្រូកម្រិតមូលដ្ឋានបានចែងថា ក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន ស្ថិតក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា ប្រមូលផ្ដុំគ្រប់មន្ត្រីបច្ចេកទេសខាងគរុកោសល្យ និងបច្ចេកទេសផ្សេងទៀត ដែលបានបណ្ដុះបណ្ដាល និងបម្រើការនៅតាមគ្រឹះស្ថានមត្តេយ្យសិក្ស បឋមសិក្សា មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាបឋមភូមិ បច្ចេកទេស និងអង្គភាពជំនាញថ្នាក់កណ្ដាល និងខេត្តក្រុងនៃក្រសួងអប់រំយុវជន និងកីឡា ។

## ២.៣. ការប្រើប្រាស់គ្រូបង្រៀន

ដើម្បីជំរុញប្រសិទ្ធភាពនៃការគ្រប់គ្រងគ្រូបង្រៀន នៅគ្រប់គ្រឹះស្ថានសិក្សាសាធារណៈ ទាំងគ្រូបង្រៀនក្របខណ្ឌ គ្រូបង្រៀនជាប់កិច្ចសន្យា គ្រូបង្រៀនពីរថ្នាក់ពីរពេល និងគ្រូបង្រៀនថ្នាក់គួប ចាប់ពីឆ្នាំសិក្សា ២០១៩-២០២០ ក្រសួងអប់រំ យុវជន និងកីឡាដាក់ចេញនូវវិធានការ តាមរយៈគ្រឹះស្ថានសិក្សាសាធារណៈត្រូវគ្រប់គ្រង និងបែងចែកភារកិច្ចជូនបុគ្គលិកអប់រំ តាមសេចក្តីណែនាំលេខ ២០ អយក.ស ណន ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ ស្តីពីនិយាមប្រើប្រាស់បុគ្គលោកអប់រំៈ

នាយកសាលាមានសេវាបង្រៀន ចំពោះសាលាតូច តិចជាង ឬស្មើ៣ថ្នាក់ ចំនួនបណ្ណារក្ស ត្រូវគិតតាមស្ថានភាពជាក់ស្តែងរបស់សាលារៀន មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវម្ចាស់ការត្រួតពិនិត្យនិងរៀបចំស្វ័យប្រកាសសាលារៀន ដែលមានតម្រូវការគ្រូបង្រៀនតាមប្រភេទក្របខណ្ឌ និងមុខវិជ្ជាជំនាញនឹងត្រូវសហការជាមួយនាយកដ្ឋានបុគ្គលិក ក្នុងការបែងចែកតួលេខក្របខណ្ឌ ឱ្យទៅដល់សាលារៀន ដែលកំពុងខ្វះគ្រូបង្រៀន។

គ្រូបង្រៀនចេញថ្មីគ្រប់ប្រភេទក្របខណ្ឌ ត្រូវបញ្ជូនទៅដល់សាលារៀនគោលដៅ ដែលសាមីខ្លួនបានជ្រើសរើស ដោយមិនអនុវត្តការផ្តល់អាទិភាពតាមចំណាត់ថ្នាក់ពិន្ទុប្រឡងចេញទៀតឡើយ។

ធ្វើបច្ចុប្បន្នភាពប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស ទាំងនៅថ្នាក់ជាតិ និងរាជធានី/ខេត្ត ចុះពិនិត្យការអនុវត្តនិយាម ធៀបជាមួយនឹងស្វ័យប្រកាសរបស់សាលារៀន។

### *២.៣.១ និយាមប្រើប្រាស់គ្រូ*

ដើម្បីធ្វើឱ្យប្រសើឡើងលើការគ្រប់គ្រង និងបែងចែកភារកិច្ច ជូនបុគ្គលិកអប់រំ ដែលកំពុងបម្រើការងារនៅតាមអង្គភាពរដ្ឋាភិបាល និងគ្រឹះស្ថានសិក្សាសាធារណៈ និងដើម្បីផ្តល់សេវាអប់រំ ប្រកបដោយគុណភាព ស្រប

ទៅនឹងបរិបទនៃការអប់រំបច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡា បានពិនិត្យកែសម្រួលឡើងវិញ សេចក្តីណែនាំស្តីពីនិយាមប្រើប្រាស់បុគ្គលិកអប់រំ និងដាក់ឱ្យអនុវត្តចាប់ពីឆ្នាំសិក្សា២០១៩-២០២០តទៅ៖

*តារាងទី 1៖ ការកំណត់ប្រភេទគ្រឹះស្ថានសិក្សា*

| គ្រឹះស្ថានសិក្សា | សាលាតូច | សាលាមធ្យម | សាលាធំ |
|---|---|---|---|
| មធ្យមសិក្សា | តិចជាងឬស្មើ ២០ ថ្នាក់ | ចាប់ពី ២១ ដល់ ៤០ ថ្នាក់ | ចាប់ពី៤១ ឡើងទៅ |

*តារាងទី 2៖ ការកំណត់ម៉ោងបំពេញការងារបុគ្គលិកអប់រំ*

| ប្រភេទគ្រឹះស្ថានសិក្សាសាធារណៈ | ចំនួនម៉ោងបង្រៀនក្នុង | ចំនួនម៉ោងដែលត្រូវបំពេញការងារគាំទ្រដល់ការបង្រៀនឱ្យគ្រប់៤០ម៉ោងក្នុង១សប្តាហ៍ |
|---|---|---|
| មធ្យមសិក្សាបឋមភូមិ | ១៨ ម៉ោង | ២២ ម៉ោង |

*តារាងទី 3៖ របាយមុខវិជ្ជាតាមម៉ោងសិក្សា*

| ល រ | មុខវិជ្ជា | ថ្នាក់ | | |
|---|---|---|---|---|
| | | ៧ | ៨ | ៩ |
| ១ | ភាសាខ្មែរ | 6 | 6 | 6 |
| ២ | ភាសាបរទេស | 4 | 4 | 4 |
| ៣ | គណិតវិទ្យាវិជ្ជា | 6 | 6 | 6 |
| ៤ | រូបវិទ្យា | ២ | ២ | ២ |
| ៥ | គីមីវិទ្យា | ១ | ១ | ១ |
| ៦ | ជីវវិទ្យា | ២ | ២ | ២ |
| ៧ | ភូមិវិទ្យា | ២ | ២ | ២ |

| | | | | |
|---|---|---|---|---|
| ៨ | ប្រវត្តិវិទ្យា | ១ | ១ | ១ |
| ៩ | សីលធម៌ ពលរដ្ឋ | ២ | ២ | ២ |
| ១០ | សេដ្ឋកិច្ច គេហកិច្ច | ១ | ១ | ១ |
| ១១ | កសិកម្ម | ១ | ១ | ១ |
| ១២ | ITC | ១ | ១ | ១ |
| ១៣ | អប់រំកាយនិងកីឡា | ២ | ២ | ២ |
| ១៤ | ផែនដី បរិស្ថាន | ១ | ១ | ១ |
| | **សរុប** | **៣២** | **៣២** | **៣២** |

## ២.៤ .បញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀន

នៅក្នុងការពង្រីកឱ្យឆាប់រហ័សនៃប្រព័ន្ធអប់រំនៅកម្ពុជា រាជរដ្ឋាភិបាលទើបបានជួបប្រទះការកើនឡើងបញ្ហាប្រឈមដែលទាក់ទងទៅនឹងការផ្គត់ផ្គង់គ្រូបង្រៀនឱ្យមានចំនួនគ្រប់គ្រាន់ ខណៈមានការធានាគុណភាពអប់រំនៅក្នុងករណីជាច្រើន ក្រសួងបានជ្រើសរើសយកគោលនយោបាយ និងយុទ្ធសាស្ត្រដាក់លាក់ដើម្បីឱ្យប្រាក់ខែគ្រូបង្រៀនដូចជា ការជួលគ្រូបង្រៀនគ្មានគុណវុឌ្ឍិ ឬគ្រូមានគុណវុឌ្ឍិមិនគ្រប់គ្រាន់ ឧទាហរណ៍ដូចជាការបង្កើតប្រភេទគ្រូថ្មីគ្រូបង្រៀន បណ្តោះអាសន្ន ឬគ្រូបង្រៀនជាប់កិច្ចសន្យាឬគ្រូបង្រៀនសហគមន៍ជាដើម ។ល។ ការប្រឈមទាក់ទងទៅនឹងការផ្គត់ផ្គង់ និងការបណ្តុះបណ្តាលគ្រូបង្រៀន និងការបណ្តុះបណ្តាលគ្នាយ៉ាងខ្លាំងជាមួយនឹងបរិបទអភិវឌ្ឍន៍ស្ទើរតែគ្រប់ប្រទេសទាំងអស់នៅក្នុងពិភពលោកនាពេលបច្ចុប្បន្ននេះ។ អ្វីដែលកំពុងប្រឈម គឺភាពមិនស្មើគ្នាក្នុងការកំណត់ចំនួនគ្រូតាមតំបន់ភូមិសាស្ត្រផ្សេងៗគ្នា ឬតាមប្រភេទសាលារៀន ព្រមទាំងអវត្តមានគ្រូ និងឬការវិចវិលគ្រូបង្រៀនបន្តិចម្តងៗ ការប្រើប្រាស់គ្រូបង្រៀននៅសាលារៀនពុំសូវមានប្រសិទ្ធភាព។ បញ្ហានៃការផ្គត់ផ្គង់គ្រូបង្រៀនមានភាពធ្ងន់ធ្ងរខ្លាំងនៅមធ្យមសិក្សា កង្វះខាតនៃមុខវិជ្ជាឯកទេសបង្រៀន និងការកំណត់ចំនួនបេក្ខជនដែលមានសក្តានុពល គឺជាបញ្ហាប្រឈមមួយនៃការ

ពង្រឹងការអប់រំនៅមធ្យមសិក្សា។ ទោះបីជាយ៉ាងណា ខណៈដែលគ្រូបង្រៀន គឺជាគន្លឹះយ៉ាងសំខាន់សម្រាប់បង្កើនគុណភាពអរប់រំ។ ក្រសួងអប់រំ យុវជន និងកីឡា នៅតែជួបប្រទះបញ្ហាកង្វះខាតគ្រូញឹកញាប់ ដោយសារការបែងចែកគ្រូបង្រៀនមិនមានសមភាពនៅក្នុងតំបន់ តំបន់ខ្លះលើស តំបន់ខ្លះខ្វះ លើសពីនេះទៅទៀតគុណភាពគ្រូបង្រៀនពុំសូវល្អឡើយ។ ថ្មីៗនេះទៀតសេចក្តីប្រកាសរបស់ទីក្រុង Incheon ដែលបានអនុម័តនៅ ខែឧសភា ឆ្នាំ២០១៥ នៅវេទិការអប់រំពិភពលោកក្នុងប្រទេសកូរ៉េខាងត្បូង បានគូសបញ្ជាក់អំពីតួនាទីយ៉ាងសំខាន់នៃការគ្រប់គ្រង និងចាត់ចែងបង្រៀននៅក្នុងការអប់រំប្រកបដោយគុណភាពតាមរបៀបវារៈអប់រំឆ្នាំ ២០៣០។ ដោយបានសង្កត់ធ្ងន់លើតម្រូវការគ្រូដែលមានការបណ្តុះបណ្តាលល្អមានគុណវុឌ្ឍិ និងគ្រូបង្រៀនដែលមានការលើកទឹកចិត្ត។ នៅកន្លែងខ្លះការផ្តត់ផ្គង់គ្រូតិច ប្រសិទ្ធភាពក្នុងការប្រើប្រាស់ម៉ោងធ្វើការរបស់គ្រូបង្រៀន គឺមានអាទិភាពណាស់ គ្រូបង្រៀនច្រើនម៉ោងធ្វើឱ្យធ្លាក់ចុះគុណភាពអប់រំ ។ នៅអនុវិទ្យាល័យ ការបង្រៀនតម្រូវឱ្យគ្រូមានមួយឯកទេស និងគ្រូមានពីរឯទេស សម្រាប់គ្រូមានបួនឯកទេស ត្រូវបង្រៀនលើសម៉ោង ក្នុងករណីខ្វះគ្រូ ដូចនេះ បើគ្រូបង្រៀនមិនមានការពេញចិត្តគឺធ្វើឱ្យការបង្រៀន មិនមានគុណភាព ។ បញ្ហាគ្រូបង្រៀនបានបង្រៀនមិនគ្រប់ម៉ោងរបស់ខ្លួន ដោយការប្រើប្រាស់ម៉ោងបង្រៀនជាក់ស្តែងមានកម្រិតទាបជាពិសេសជាមួយសាលារៀនដែលមានគ្រូបង្រៀនមានចំនួនលើស។

## ២.៥ យុទ្ធសាស្ត្រក្នុងការដោះស្រាយ

គុណភាពអប់រំនៅកម្ពុជានាពេលបច្ចុប្បន្ននេះវាស្រ័យទៅនឹងចំណេះដឹងរបស់លោកគ្រូ-អ្នកគ្រូដែលប្រកបដោយមនសិការវិជ្ជាជីវៈក្នុងការបង្រៀនប្រកបដោយឆន្ទះចង់ឱ្យសិស្ស/និស្សិត ក្លាយទៅជា កូនល្អ សិស្សពូកែ និងជាពលរដ្ឋប្រកបដោយសេចក្តីថ្លៃថ្នូរ ជាពិសេសត្រូវបានសង្គមជាតិនិងឆាកអន្តរជាតិទទួលស្គាល់ពីសមត្ថភាព និងចំណេះដឹង។ ដូចនេះហើយគ្រូបង្រៀនមានសារៈសំខាន់ណាស់សម្រាប់សង្គមជាតិក្នុងបណ្តុះបណ្តាលធនធានមនុស្សដែលធ្វើឱ្យសេដ្ឋកិច្ចជាតិរីកចម្រើន។ នាពេលបច្ចុប្បន្ននេះ វិស័យអប់រំនៅក្នុងប្រទេសកម្ពុជាបានធ្វើកំណែទម្រង់ជាច្រើនលើកដើម្បីលើកកម្ពស់គុណភាពវិស័យអប់រំនៅកម្ពុជា ក្នុងកំណែទម្រង់

ទាំង១៩នៃវិស័យអប់រំនេះមានមួយការពង្រាយគ្រូបង្រៀន ដោយសារតែបញ្ហាការលើសគ្រូនៅតំបន់ប្រជុំជន និង ខ្វះនៅតំបន់ជនបទ ក្នុងការពង្រាយគ្រូនេះ ក្រសួងអប់រំ យុវជន និងកីឡា បានចេញលិខិតណែនាំសម្រាប់គ្រឹះស្ថានអប់រំក្នុងការពង្រឹងការអនុវត្តសេចក្តីណែនាំលេខ ២៣ អយក.ស ណន ចុះថ្ងៃទី ៣ ខែកក្កដា ឆ្នាំ ២០១៧ ស្តីពីការបែងចែកប៉ុស្តិ៍បម្រើការងាររបស់គ្រូបង្រៀនចេញថ្មី (ប៉ុន្តែគួរមានការកែសម្រួលចំណុចមួយចំនួនដូចខាងក្រោម)៖

- ពង្រឹងដំណើរការរបស់គណៈកម្មការគ្រប់គ្រងបុគ្គលិករាជធានី/ខេត្ត គណៈកម្មការជ្រើសរើសប៉ុស្តិ៍
- គ្រូបង្រៀនចេញថ្មីដែលមានកិច្ចសន្យា ទៅបម្រើការនៅសាលារៀន ដែលបានជ្រើសរើស ត្រូវទៅបម្រើការនៅទីនោះ
- បញ្ឈប់ការប្តូរប៉ុស្តិ៍គ្នា បន្ទាប់ពីការជ្រើសរើសប៉ុស្តិ៍រួច
- គ្រូបង្រៀនចេញថ្មី ដែលមិនគោរពតាមលិខិតបង្គាប់ការ ឬលិខិតឧទ្ទេសនាម នឹងត្រូវស្នើផ្អាកបៀវត្សន៍ ឬស្នើលុបឈ្មោះចេញពីក្របខណ្ឌភ្លាម។

### *២.៥.១ ករណីសាលាខ្វះគ្រូ*

ក្រសួងអប់រំ យុវជន និងកីឡា បានណែនាំដល់គ្រប់ភាគីទាំងអស់ ក្នុងការយកគ្រូថ្មីដែលមានគុណវុឌ្ឍិ មុនដំបូងត្រូវធ្វើការពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីរកលទ្ធភាពបង្កើនប្រាក់ឧបត្ថម្ភម្តងគត់សម្រាប់ការពង្រាយគ្រូបង្រៀនឆ្លងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ក្នុងករណីមិនមានត្រូវដោះស្រាយជាបន្ទាន់ដោយមាន៖

ការប្រឡងជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា ត្រូវរៀបចំដោយមានលក្ខណៈទន់ភ្លន់ និងដោយផ្តល់អាទិភាពពិន្ទុចំពោះបេក្ខជនដែលស្ម័គ្រចិត្ត ទៅបម្រើការនៅតាមតំបន់ដាច់ស្រ យាល និងជួបការលំបាក ពង្រឹងការអនុវត្តគោលការណ៍ណែនាំស្តីពីការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យាដោយត្រូវជ្រើសរើសគ្រូបង្រៀន ជាប់កិច្ចសន្យា តាមការចាំបាច់ជាក់ស្តែងក្នុងឆ្នាំនីមួយៗសម្រាប់សាលារៀនដែលខ្វះគ្រូ ការស្នើបញ្ចូលក្របខណ្ឌ (ទាំង

គ្រូក្របខណ្ឌនិងគ្រូបង្រៀនជាប់កិច្ចសន្យា) ត្រូវធ្វើឡើងដោយផ្អែកលើផែនការគ្រប់ជ្រុងជ្រោយ ច្បាស់លាស់ និងស្របតាមគោលការណ៍កំណត់ ដោយចៀសវាងនូវការស្នើសុំបន្ថែមក្នុងឆ្នាំ ដែលធ្វើឱ្យកិច្ចការនេះប្រព្រឹត្តទៅដោយមិនមានតម្លាភាព និងប្រសិទ្ធភាព។ គ្រូបង្រៀនជាប់កិច្ចសន្យាអាចប្រឡងចូលក្របខណ្ឌរដ្ឋដែលបានកំណត់នៅក្នុងលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌគ្រូបង្រៀន ។ ការស្នើសុំចូលក្របខណ្ឌជាស្វ័យប្រវត្តិរបស់គ្រូបង្រៀនជាប់កិច្ចសន្យាមិនត្រូវបានអនុញ្ញាតឡើយ។ ផ្តល់សិទ្ធិឱ្យនាយកសាលាដែលមានតម្រូវការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យាដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។ សាលាគរុកោសល្យខេត្តនីមួយៗត្រូវមានផែនការបំប៉នគ្រូបង្រៀនជាប់កិច្ចសន្យាដែលជ្រើសរើសថ្មីពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយក្នុងការធ្វើផែនការប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យា ដើម្បីជៀសវាងការស្នើសុំបន្ថែមដូចនេះត្រូវមានការពិនិត្យឡើងវិញគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ សុំគោលការណ៍ជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា១ឆ្នាំមុនដោយមិនមានការដោះដូរ និងបន្តដោយស្វ័យប្រវត្តិតាមរយៈ៖

- ការសិក្សា និងវាយតម្លៃសេវាបង្រៀនរបស់គ្រូបង្រៀនជាប់កិច្ចសន្យា
- ការធ្វើតេស្ត/ប្រឡង
- ការបណ្តុះបណ្តាល និងចាត់ឱ្យបង្រៀននៅចំទីតាំង

ត្រូវរៀនជ្រើសរើសគ្រូកិច្ចសន្យា និងត្រូវសុំទិន្នាការពីក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសាលាមុខងារសាធារណៈ ដើម្បីធានាគុណភាព កំណត់ចំនួនជ្រើសរើសគ្រូបង្រៀនកិច្ចសន្យាមិនឱ្យលើសពី ១០០០០នាក់ក្នុង១ឆ្នាំ ។ ស្នើសុំក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីផ្ទេរប្រាក់ឧបត្ថម្ភទៅកាន់គណនីរបស់សាលាផ្ទាល់ ប្រការនេះនឹងធានាការបើកទៀងទាត់ និងទាន់ពេលចំពោះគ្រូបង្រៀនជាប់កិច្ចសន្យា បើមិនអាចកាត់បន្ថយបាន ក៏មិនគួរឱ្យកើនថែមទៀតទេ។ បើចាំបាច់ខ្លាំង ការជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យា គួរផ្តល់អាទិភាពដល់គ្រូចូលនិវត្តន៍ដែលមានសមត្ថភាព និងស្ម័គ្រចិត្តបន្តបង្រៀន (ក្រៅពីជ្រើសរើសសិស្ស/និស្សិតដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឡើងទ) ស្នើសុំគោលការណ៍អនុញ្ញាតឱ្យមន្ទីរ

អប់រំ យុវជន និងកីឡា និងមន្ទីរមុខងារសាធារណៈ រាជធាន/ ខេត្ត មានសិទ្ធិសម្រេចលើករណី ជ្រើសរើសគ្រូបង្រៀនជាប់កិច្ចសន្យាដើម្បីជំនួស គ្រូបង្រៀនជាប់កិច្ចសន្យា មរណៈភាព និង លំហែមាតុភាព និងមានគោលការណ៍បន្តផ្តល់ប្រាក់ឧបត្ថម្ភក្នុងពេលវិស្សមកាលដល់គ្រូបង្រៀនជាក់កិច្ចសន្យាដែលជ្រើសរើសចេញពីគ្រូបង្រៀនចូលនិវត្តន៍ និងនិស្សិតដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រឡើង។

### *២.៥.២ ករណីសាលាលើសគ្រូ*

អនុវត្តសាកល្បងនៅរាជធានីភ្នំពេញដោយមានការពិនិត្យឱ្យបានហ្មត់ចត់តួលេខគ្រូបង្រៀនដែលមានសេវាបង្រៀនមិនគ្រប់តាមនិយាមកំណត់ និងអាសយដ្ឋានបច្ចុប្បន្នរបស់គ្រូបង្រៀនទាំងអស់នោះ ដើម្បីស្នើពង្រាយទៅសាលារៀនដែលកំពុងខ្វះគ្រូបង្រៀន នៅជិតលំនៅដ្ឋានរបស់ពួកគាត់។

**ករណីខេត្តផ្សេងទៀត**

- បន្តទប់ស្កាត់ការផ្លាស់គ្រូបង្រៀនចូលសាលារៀនដែលលើសគ្រូ
- ស្នើសុំគោលការណ៍បង្កើនប្រាក់ឧបត្ថម្ភម្តងគត់ដល់គ្រូបង្រៀន ដែលស្ម័គ្រចិត្តពង្រាយទៅសាលារៀនដែលកំពុងខ្វះគ្រូ
- សុំគោលការណ៍ផ្តល់ប្រាក់បំណាច់មុខងារពិសេស ដល់គ្រូបង្រៀនដែលកំពុងបង្រៀននៅតំបន់ជួបការលំបាកខ្លាំង។

ការអនុវត្តនូវវិធានការខាងរបស់ក្រសួងអប់រំ យុវជន និងកីឡា ហាក់បីដូចជាមិនមានការផ្លាស់ប្តូរពីគ្រូនៅសាលាលើសអោយមកបម្រើការនៅសាលាដែលខ្វះគ្រូទេ ក៏គ្មានអ្នកគ្រូ-លោកគ្រូណាស្មគ្រចិត្តមកបង្រៀនសាលាខ្វះគ្រូនៅជនបទទេ ទោះជាមានការលើកទឹកចិត្តដោយផ្តល់ប្រាក់បន្ថែមលើប្រាក់ខែក៏ដោយ ។

## ២.៦ ភាពជាអ្នកដឹកនាំរបស់គណៈនាយក

ភាពជាអ្នកដឹកនាំលើការគ្រប់គ្រងរដ្ឋបាលសាលារៀន៖

- ការចាត់ចែងការប្រើប្រាស់ធនធាននានាអោយមានប្រសិទ្ធភាព និងចំគោលដៅ

- ការរៀបចំរចនាសម្ព័ន្ធបែងចែងតួនាទីនិងភារកិច្ចដល់បុគ្គលិកតាមជំនាញប្រកបដោយប្រសិទ្ធភាព
- ការស្វែងយល់ពីសុខទុក្ខរបស់គ្រូ និងបុគ្គលិកក្នុងសាលាដោយសិក្សាពីស្ថានភាពជីវភាពរបស់គ្រូ ព័ត៌មាននានាពាក់ព័ន្ធនឹងគ្រូបង្រៀន (ប្រវត្តិ ទីកន្លែងស្នាក់នៅ ឈ្មោះ លេខទូរស័ព្ទ ចំណង់ចំណូលចិត្ត និងថ្ងៃខែឆ្នាំចូលនិវត្តន៍)
- ការលើកទឹកចិត្តអ្នកដែលមានស្នាដៃល្អ ដោយស្នើដំឡើងថ្នាក់ ឋានន្តរស័ក្តិ ផ្តល់បណ្ណសរសើរ
- ការណែនាំដល់គ្រូបង្រៀនអោយចេះថែទាំសុខភាព អនាម័យ ការស្លៀកពាក់ ឥរិយាបថក្នុងការរស់នៅ និងធ្វើការងារ
- ការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀនប្រកបដោយតម្លាភាព
- ការបង្កលក្ខណៈងាយស្រួលដល់គ្រូបង្រៀន និងបុគ្គលិកអប់រំទាំងអស់នៅក្នុងសាលាឱ្យទទួលបានការសិក្សាជំរុញឱ្យធ្វើការស្រាវជ្រាវដើម្បីពង្រីកចំណេះដឹងលើមុខវិជ្ជាបង្រៀន និងគរុកោសល្យ
- ការលើកទឹកចិត្តឱ្យមានយេនឌ័រក្នុងការចូលរួមគ្រប់សកម្មភាព
- ការលើកកម្ពស់តម្លៃវិជ្ជាជីវៈគ្រូបង្រៀន និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន

ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀន និងរៀន៖

- ការជំរុញ និងលើកទឹកចិត្តគ្រូ ប្រើចិត្តគរុកោសល្យច្បាស់លាស់ក្នុងការសម្របសម្រួលឱ្យសិស្សចេះរៀន
- ការរៀបចំធ្វើគម្រោងផែនការអធិការកិច្ចដើម្បីជួយគ្រូ និងអនុវត្តផែនការនេះឱ្យបានទៀងទាត់
- ការជំរុញគ្រូធ្វើផែនការបង្រៀន និងអនុវត្តផែនការនោះបានត្រឹមត្រូវជាប្រចាំ
- ការសង្កេតការបង្រៀនរបស់គ្រូ និងផ្តល់ពត៌មានត្រឡប់ប្រកបដោយការលើកទឹកចិត្ត
- ការលើកទឹកចិត្តគ្រូឱ្យបង្រៀនដល់សិស្សគ្រប់ប្រភេទដោយមិនរើសអើង
- ការជម្រុញគ្រូបង្រៀនផ្តល់ការបង្រៀនអោយចប់កម្មវិធីសិក្សា និងស្របតាមតម្រូវការរបស់សិស្ស
- ការជំរុញ គ្រូបង្រៀនឱ្យលើកទឹកចិត្តសិស្សក្នុងការស្វ័យសិក្សាជាប្រចាំ

- ការបង្កបរិយាកាសរៀនសូត្រល្អប្រសើរ ប្រកបដោយភាពរីករាយ ស្និទ្ធស្នាល និងជំនឿជាក់។

ប្រព័ន្ធគ្រប់គ្រង និងចាត់ចែងបង្រៀនៈ

- លាភការមានប្រអប់បញ្ចូលគ្រប់គ្រាន់សម្រាប់គ្រូបង្រៀន បើកប្រាក់ខែ និងប្រាក់ឧបត្ថម្ភឱ្យបានត្រឹមត្រូវ និងទាន់ពេលវេល
- ផ្ដល់រង្វាន់ចំពោះអ្នកអនុវត្តបានល្អ
- ការផ្ដល់ឱកាសសម្រាប់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងការវិវត្តអាជីពដោយជានាបានការគាំទ្រជាអាជីពពីអ្នកផ្ដល់ប្រឹក្សាយោបល់ មជ្ឈមណ្ឌលគ្រូបង្រៀន និងវិធីផ្សេងៗទៀត
- ការតែងតាំងគ្រូដែលបង្រៀនបានយ៉ាងល្អ ការលើកទឹកចិត្តប្រធានបច្ចេកទេស និងបុគ្គលិកដែលបានដំឡើងឋានៈអោយក្លាយជាអ្នកដឹកនាំវិជ្ជាជីវៈផ្ដល់អំណាច និងលទ្ធភាពដល់អ្នកគ្រប់គ្រងរដ្ឋបាលក្នុងការដោះស្រាយបញ្ហាផ្ទាល់ខ្លួន និងការអាក់អន់ចិត្តជាបន្ទាន់ ( លោកHalliday,1989)

ចំណែកឯនៅក្នុងគោលនយោបាយស្ដីពីគ្រូបង្រៀនក៏បានចែងថាៈ

❖ ការលើកទឹកចិត្ត និងការរក្សាទុកគ្រូបង្រៀនគឺជាការៈ

- លើកកម្ពស់លក្ខខណ្ឌធ្វើការងារ និងរស់នៅរបស់គ្រូបង្រៀនតាមរយៈការផ្ដល់បៀវត្ស លាភការសុខុមាភាពសង្គម អត្ថប្រយោជន៍ទូទៅ និងអត្ថប្រយោជន៍ពេលចូលនិវត្តន៍ជាពិសេសអ្នកគ្រូ និងគ្រូបង្រៀនបម្រើការងារនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក
- ទទួលស្គាល់ និងជូនរង្វាន់ដល់គ្រូបង្រៀនដែលមានស្នាដៃល្អ ។ ទន្ទឹមនឹងនេះលោក Handy,1999 បានបង្ហាញថាការលើកទឹកចិត្តរបស់បុគ្គលិកគឺជាតួនាទីមួយទៀតរបស់អ្នកគ្រប់គ្រងធនធានមនុស្ស។ នេះអាចធ្វើបានតាមរយៈរង្វាន់ជាពិសេសដល់អ្នកដែលគាត់ធ្វើបានល្អ នាយកដ្ឋានធនធានមនុស្សត្រូវធ្វើការវាយតម្លៃលើការអនុវត្តការងាររបស់បុគ្គលិក។ បុគ្គលិកទាំងនោះដែលត្រូវបានគេរកឃើញថាមានលើសពីការរំពឹងទុកគួរតែត្រូវបានផ្ដល់សំណាងសម្រាប់សកម្មភាពរបស់ពួកគេ។ សំណាងខ្លះអាច

ជាការផ្ដល់ជូនថ្ងៃឈប់សម្រាក ប្រាក់រង្វាន់ចុងឆ្នាំ ប្រាក់រង្វាន់ ការដំឡើងប្រាក់ខែជាដើម។ល។ ប្រសិនបើអ្នកគ្រប់គ្រងរក្សាការលើកទឹកចិត្តបែបនេះនឹងមានភាពប្រសើរឡើងនៃការពេញចិត្តរបស់បុគ្គលិក ចំណុចនេះក៏រួមចំណែកដល់អត្រារក្សាទុកបុគ្គលិកល្អផងដែរ។ រីឯលោក Whawo, 2003 មានទស្សនៈថាការអភិវឌ្ឍបុគ្គលិកក៏ជាមធ្យោបាយមួយក្នុងការបង្កើនការលើកទឹកចិត្តដល់បុគ្គលិក និងជាកត្តាជម្រុញថាមពលអោយពួកគេក្នុងការបំពេញការងារឱ្យបានកាន់តែប្រសើរ។

- លើកកម្ពស់ភាពរីកចម្រើននៃអាជីព ស្វ័យភាព និងការសម្រេចចិត្តក្នុងវិជ្ជាជីវៈរបស់គ្រូបង្រៀនដែលកំណត់ក្នុងច្បាប់សំដៅកែលម្អលទ្ធផលសិក្សារបស់សិស្ស គោលនយោបាយស្ដីពីគ្រូបង្រៀន), ឧសភា ២០១៣, ទំព័រ ៣។ ដូចគ្នាផងដែ លោកPeretomode, 2001 យល់ឃើញថា បុគ្គលិកអាចក្លាយជាមនុស្សដែលលែងប្រើបាន ប្រសិនបើពួកគេមិនបានអភិវឌ្ឍន៍ខ្លួនឯងជាមួយនឹងជំនាញថ្មី ការងារថ្មី វិធីសាស្ត្រថ្មី ការស្វែងយល់ឱ្យកាន់តែជ្រៅពីការងារ អង្គភាព និងបរិស្ថានដែលខ្លួនរស់នៅ។ អង្គភាពមួយអាចនឹងមានភាពច្របូកច្រប់ដែរប្រសិនបើវាខ្វះប្រព័ន្ធនៃការពិនិត្យមើល និងការអភិវឌ្ឍសមត្ថភាពរបស់អង្គភាព។ ការអភិវឌ្ឍជួយរក្សាបុគ្គលិកឱ្យមានភាពស្មើគ្នាជាមួយនឹងការផ្លាស់ប្ដូរបច្ចេកវិទ្យា វិទ្យាសាស្ត្រ វប្បធម៌សង្គម និងសេដ្ឋកិច្ចជាប្រចាំនៅក្នុងបរិស្ថាន។

❖ ភាពទាក់ទាញអ្នកមានសមត្ថភាពអោយប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន

  - លើកកម្ពស់ជីវភាព តម្លៃវិជ្ជាជីវៈ សេចក្ដីថ្លៃថ្នូរ និងការយកចិត្តទុកដាក់ពីសង្គម
  - លើកកម្ពស់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន
  - កំណត់លក្ខណៈវិនិច្ឆ័យ និងលក្ខខណ្ឌតម្រូវខាងវិជ្ជាជីវៈសម្រាប់ការជ្រើសរើស
  - ធ្វើទំនើបកម្មស្ដង់ដារកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់ជាតិ និងការប្រកួតប្រជែងក្នុងតំបន់ និងសកលលោក។

❖ អភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារ

- បណ្តុះវប្បធម៌រៀនពេញមួយជីវិតដោយចេះចែករំលែកចំណេះដឹង និងបទពិសោធន៍ជាមួយបណ្តាញក្រុមអ្នកអប់រំ
- រៀបចំយន្តការប្រកបដោយប្រសិទ្ធភាពដើម្បីគាំទ្រគ្រូបង្រៀននៅនឹងកន្លែងធ្វើការ
- រៀបចំគោលការណ៍ណែនាំស្តីពីតម្រូវការ និងផលប្រយោជន៍នៃការអភិវឌ្ឍវិជ្ជាជីវៈ។ គោលនយោបាយស្តីពីគ្រូបង្រៀន, ឧសភា ២០១៣ ការគ្រប់គ្រង និងចាត់ចែងគ្រូបង្រៀនប្រកបដោយសុវត្ថិភាព៖

ការគ្រប់គ្រងធនធានមនុស្ស "ល្អ" មានន័យថាការបែងចែកការគ្រប់គ្រង ចូលរួមធ្វើឱ្យមានមុខងារនៃប្រព័ន្ធអប់រំប្រកបដោយប្រសិទ្ធិភាព និងការបំពេញចិត្តបុគ្គលិក ដែលភាគច្រើនគឺអាស្រ័យលើកត្តា៖

- ការធ្វើផែនការបុគ្គលិកបានត្រឹមត្រូវ(គ្រូបង្រៀន)មិនមានផែនការអប់រំសម្រាប់ទាំងអស់គ្នា ឬផែនការអប់រំផ្សេងទៀតអាចអនុវត្តជោគជ័យ ដោយគ្មានការវាយតម្លៃយ៉ាងប្រុងប្រយ័ត្ននៃតម្រូវការបុគ្គលិកដើម្បីទទួលបានគោលដៅជាក់លាក់នោះទេ។ ទោះជាយ៉ាងណាក៏ដោយ ការធ្វើផែនការសម្រាប់តម្រូវការពិតប្រាកដរបស់បុគ្គលិកបង្រៀន ឬមិនបង្រៀនជាញឹកញាប់មានការលំបាក ដោយសារតែការវិចវិលបន្តិចៗម្តង ភាពអាចរកបាន និងការប្រើប្រាស់បុគ្គលិក ជាពិសេសគ្រូបង្រៀនជាញឹកញាប់មិនសូវបានព័ត៌មានច្បាស់លាស់ទេ ដោយសារចំណុចខ្សោយក្នុងប្រព័ន្ធព័ត៌មានដែលមានស្រាប់ និងឥរិយាបថនៃការគ្រប់គ្រង។
- គោលនយោបាយក្នុងការជ្រើសរើស ការផ្តល់ប្រាក់ខែ ការបែងចែកបុគ្គលិក និងអាជីពប្រកបដោយនិរន្តរភាព អ្នកធ្វើការសម្រេចចិត្តនៅក្នុងប្រព័ន្ធអប់រំទាំងអស់ ត្រូវប្រឈមការជ្រើសរើសយ៉ាងលំបាក។ ម្ខាងពួកគេត្រូវដោះស្រាយតម្រូវការបុគ្គលិកបន្ថែម ឬអាចបង្កើនការលើកទឹកចិត្តបុគ្គលិកបន្ថែមដែលកត្តាទាំងពីរអាចមានផលប៉ះពាល់វិជ្ជមានលើគុណភាពនៃប្រព័ន្ធ។ ម្ខាងទៀតពួកគេត្រូវយកចិត្តទុកដាក់លើហិរញ្ញវត្ថុពេលខ្វះធនធានមនុស្ស។ គោលការណ៍នយោបាយកំណត់បុគ្គលិក និងការអនុ

វត្តដ៏មានប្រសិទ្ធិភាព និងប្រព័ន្ធអាជីពគ្រប់គ្រាន់អាចជួយរួមចំណែកក្នុងការគ្រប់គ្រងធនធានមនុស្ស ដោយមានចំណាយប្រកបដោយប្រសិទ្ធិភាពបន្ថែមទៀត និងបានធ្វើឱ្យ ប្រសើរឡើងនូវការពេញចិត្ត ចំពោះបុគ្គលិកដែលពាក់ព័ន្ធ។

- ប្រព័ន្ធព័ត៌មាន និងប្រព័ន្ធពិនិត្យតាមដានសម្រាប់ការគ្រប់គ្រងបុគ្គលិកសមស្រប មានកំហុសយ៉ាងធ្ងន់ធ្ងរនៅក្នុងការត្រួតពិនិត្យតាមដាន និងប្រព័ន្ធព័ត៌មានពាក់ព័ន្ធបុគ្គលិកវិស័យអប់រំជាច្រើនចំពោះគ្រូបង្រៀនមានលក្ខណៈពិសេស និងកន្លែងបម្រើការងាររបស់ពួកគេ រឿងនេះប្រែក្លាយជាមានបញ្ហាលើការធ្វើផែនការ និងការកំណត់ចំនួនបុគ្គលិកក៏ដូចជាផលលំបាកនៃការសម្រេចចិត្តគ្រប់គ្រងឱ្យមានតម្លាភាព និងគ្រប់គ្រាន់ផងដែរ
- មានរចនាសម្ព័ន្ធ និងច្បាប់សមស្រប អវត្តមាន ឬភាពមិនសមស្របនៃបទបញ្ញត្តិ សេចក្តីណែនាំ ការធ្វើសេចក្តីសម្រេចចិត្តបែបវិមជ្ឈការជ្រុលនិយម នីតិវិធីដែលមានតម្លាភាពជាញឹកញាប់នាំឱ្យយឺតយ៉ាវក្នុងការសម្រេចចិត្តការគ្រប់គ្រង ការខកចិត្ត និងបញ្ហាផ្សេងទៀតនៅក្នុងការគ្រប់គ្រងបុគ្គលិក ឬត្រូវដាក់ផ្ទុយមកវិញ ការធ្វើឱ្យមានទំនាក់ទំនងគ្នាទាន់សម័យ និងបទបញ្ញត្តិ និងនីតិវិធីល្អដូចជាក្រមសីលធម៌វិជ្ជាជីវៈអាចជួយសម្រួលដល់ការសម្រេចចិត្តគ្រប់គ្រងបុគ្គលិកដោយសមហេតុផល និងអាចទទួលយកបាន ។ (សេចក្តីផ្តើមស្តីពីការគ្រប់គ្រង និងបែងចែកធនធានអប់រំ)។

## ២.៧ .ការដោះស្រាយបញ្ហានៅសាលារៀន

ការដោះស្រាយត្រូវរំលើងឫសគល់នៃបញ្ហាទាំងនោះជាមុនសិន ដើម្បីឱ្យសេវានៅក្នុងសាលារៀនមានគ្រប់ហើយដំណើរការ សេវានៅក្នុងសាលារៀនឆ្លើយតបនឹងតម្រូវការ មានការវាយតម្លៃ និងកែលម្អសេវា ដែលជាឫសគល់ នាយកសាលា គណៈគ្រប់គ្រងសាលាមធ្យមសិក្សា ត្រូវអនុវត្តតាមយុទ្ធសាស្រ្ត ដែលជាគោលការណ៍អភិបាលកិច្ចល្អសាលារៀនរួមមាន៖

**១. ការចូលរួម៖** សម្រេចចិត្តធ្វើអ្វីមួយ ត្រូវមានការចូលរួមពីភាគីពាក់ព័ន្ធជាមុនសិន។ គ្រប់សកម្មភាព និងគ្រប់សេវាទាំងអស់ក្នុងសាលារៀននាយកសាលាត្រូវគៀងគរ បញ្ចុះបញ្ចូល លើកទឹកចិត្ត។

**២. ការគោរពច្បាប់៖** គ្រប់ការសម្រេចចិត្តធ្វើសកម្មភាពដើម្បីផ្តល់សេវាអប់រំ នាយកសាលាត្រូវពិនិត្យមើលទៅលើគោលការណ៍ច្បាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងបច្ចេកទេសគ្រប់គ្រងបុគ្គលិក គ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ គ្រប់គ្រងសិស្ស។ លើសពីនេះការសម្រេចចិត្តក៏ត្រូវពិនិត្យ និពិចារណាមើលគោលនយោបាយអប់រំ ដែលជាផែនទីបង្ហាញផ្លូវ សម្រាប់អនុវត្តលើការងារអប់រំ។

**៣.តម្លាភាព៖** នាយកសាលា គណៈគ្រប់គ្រង ត្រូវធ្វើការបិទផ្សាយ ចែកផ្សាយ និងផ្សព្វផ្សាយរាល់ការសម្រេចចិត្តក្នុងការអនុវត្តសកម្មភាពណាមួយ ដែលគាំទ្រសេវាតម្រូវការរបស់សិស្ស។ លើសពីនេះទៀតនាយកសាលាត្រូវបែងចែកការងារ និងធ្វើការជាក្រុមសម្រាប់អភិវឌ្ឍន៍សាលារៀន។

**៤. ការព្រមព្រៀង ការឯកភាព៖** លទ្ធផលនៃការសម្រេចចិត្តត្រូវមានការព្រមព្រៀង និងឯកភាពតាមបែបប្រជាធិបតេយ្យ ដោយអនុវត្តតាមមតិភាគច្រើន ដោយស្របតាមគោលការណ៍ច្បាប់ និងក្របខណ្ឌ គោលនយោបាយ។

**៥. គណនេយ្យភាព៖** គឺជាបិតានៃការទទួលខុសត្រូវ នាយកសាលា គណៈគ្រប់គ្រង ត្រូវបែងចែកឱ្យមានការទទួលខុសត្រូវតាមលំដាប់ថ្នាក់ប្រជុំត្រួតពិនិត្យតាមដានរាល់គ្រប់សកម្មភាពការងារដែលបានចាត់ចែង ហើយនាយកត្រូវមានខ្សែគណនេយ្យភាពចំពោះការិយាល័យអប់រំ យុវជននិងកីឡាក្រុង ស្រុក ខណ្ឌ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងក្រសួងអប់រំ យុវជន និងកីឡា និងមានខ្សែគណនេយ្យភាពចំពោះថ្នាក់ក្រោម និងប្រជាពលរដ្ឋ។

**៦. ប្រសិទ្ធភាពនិងភាពសក្តិសិទ្ធ៖** គ្រប់ការបែងចែក ការចាត់ចែងទាំងអស់ ត្រូវធ្វើ ហើយធ្វើឱ្យត្រូវធ្វើឱ្យលឿន ធ្វើឱ្យអស់ថវិកាតិច។

**៧. ភាពឆ្លើយតប៖** គ្រប់សេវាទាំងអស់ ត្រូវរៀបចំឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស គ្រូបង្រៀន និងអ្នកពាក់ព័ន្ធ។ តែព័ត៌មានអប់រំ ត្រូវតែឆ្លើយតបទៅនឹងតម្រូវការរបស់ឱពុកម្ដាយ ឬអ្នកអាណាព្យាបាល។

**៨. បរិយាបន្ន៖** គ្រប់សេវានៅក្នុងសាលារៀន ត្រូវដាក់បញ្ចូលសកម្មភាពប្រកបដោយសមធម៌។

សរុបសេចក្ដីមក ដើម្បីដោះស្រាយបញ្ហា ត្រូវដោះតាមយុទ្ធសាស្ត្រ៨ចំណុចខាងលើ ដែលជាគោលការណ៍អភិបាលកិច្ចល្អក្នុងសាលារៀន។ ជាពិសេសការដោះស្រាយ ត្រូវផ្អែកតាមគោលនយោបាយ និងច្បាប់។

# ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ

ការស្រាវជ្រាវនេះ នឹងធ្វើការស្វែងយល់ពីស្ថានភាពនៃការប្រើប្រាស់គ្រូបង្រៀននៅតាមអនុវិទ្យាល័យនានាក្នុងប្រទេសកម្ពុជា។ ទិន្នន័យដែលប្រមូលនេះមានពីរប្រភេទ (១)តាមបែបបរិមាណវិស័យ(Quantitative data) ដែលជាទិន្នន័យបានមកពីការសិក្សាលើការអានឯកសារផ្សេងៗដោយធ្វើការសំយោគនិងបំពេញកម្រងសំណួរ (បិទ) ត្រូវបានប្រមូលតាមរយៈការប្រមូលស្ថិតិនៅមន្ទីរអប់រំ យុវជន និង កីឡា និង (២)ទិន្នន័យជាប្រភេទគុណវិស័យ(Qualitative data)ទាំងនេះបានមកពីការបំពេញកម្រងសំណួរដោយសម្ភាសន៍ផ្ទាល់ជាមួយក្រុមគោលដៅ(បើក)។ ទិន្នន័យទាំងពីរប្រភេទត្រូវបានប្រមូលពីអនុវិទ្យាល័យសិក្សាចំនួន០៩ ដែលចែកចេញជាបីកម្រិត៖ សាលាតូច សាលាមធ្យម និងសាលាធំ ហើយទាំងអស់នោះស្ថិតនៅ ក្នុងកណ្តាលទីក្រុង និងតំបន់ជាយក្រុងក្នុងចំណោមអនុវិទ្យាល័យចំនួន៦៧ អនុវិទ្យាល័យនៅរាជធានីភ្នំពេញ។ សំណាកត្រូវបានជ្រើសរើសចំនួនប្រាំនាក់ពីអនុវិទ្យាល័យនីមួយៗក្នុងនោះមានប្រធានការិយាល័យបុគ្គលិកនៃមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ នាយក/នាយករង នាយិកា/នាយករង ព្រមទាំងលោកគ្រូ-អ្នកគ្រូ ប្រធានក្រុមបច្ចេកទេសនៃវិទ្យាសាស្ត្រពិត ឬវិទ្យាសាស្ត្រសង្គម។ ដោយឡែកកម្រងសំណួរត្រូវបានបែងចែកជាបីផ្នែកសម្រាប់នាយកសាលាបំពេញ គឺ (១)ព័ត៌មានទូទៅ (២)ទស្សនៈរបស់នាយកចំពោះការកំណត់គ្រូបង្រៀន និង(៣)យោបល់បន្ថែមរបស់គណៈនាយកទាក់ទងនឹងការប្រើប្រាស់គ្រូ។ ទិន្នន័យដែលត្រូវយកមកប្រើសម្រាប់វិភាគបែបបរិមាណវិស័យជាស្ថិតិគ្រូ សិស្ស ថ្នាក់និងគ្រូតាមមុខវិជ្ជានីមួយៗ។ រីឯការបំពេញកម្រងសំណួរបើកសម្រាប់ការធ្វើការវិភាគបែបគុណវិស័យអាចឆ្លុះបញ្ចាំងពីគំនិត ទស្សនៈរបស់នាយកក្នុងការប្រើប្រាស់គ្រូ និងវិធីសាស្ត្រដោះស្រាយបញ្ហាប្រឈមនានា ជាមួយអនុសាសន៍ពួកគាត់។

ចំពោះការវិភាគទិន្នន័យបែបបរិមាណវិស័យគឺ វិភាគតាមក្រាហ្វ និងតារាង ដោយប្រើប្រាស់កម្មវិធីExcel។ ដោយឡែកការវិភាគតាមរយៈការចាត់ថ្នាក់ជាក្រុម និងដាក់ចំណងជើងដោយផ្អែកលើទស្សនៈ និងអត្ថន័យនៃ

ប្រយោគដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា រួចធ្វើការបរិយាយ និងពន្យល់តាមចំណាត់ថ្នាក់នៃក្រុមនីមួយៗ។

## ៣.១ គម្រោងវិភាគ

ការសិក្សាស្រាវជ្រាវនេះ យើងបានកំណត់ទីតាំងសម្រាប់ប្រមូលទិន្នន័យគណៈនាយកទាំងអស់និងលោកគ្រូអ្នកគ្រូដែលបម្រើការងារជាមន្ត្រីបុគ្គលិកអប់រំនៅសាលារៀនអនុវិទ្យាល័យ៩ដែលយកចេញពីខណ្ឌបីដែលមានខណ្ឌធំ ខណ្ឌមធ្យម ខណ្ឌតូច ក្នុងចំណោមខណ្ឌនីមួយៗ យកអនុវិទ្យាល័យឬវិទ្យាល័យ បីទៀត ដែលសាលារៀនជាសាលារៀនធំ សាលារៀនមធ្យម និង សាលារៀនតូចនៅភ្នំពេញ ។តាមបញ្ជីខណ្ឌរដ្ឋបាលភ្នំពេញក្នុងចំណោមខណ្ឌទាំង១៤ ខណ្ឌនៃរាជធានីភ្នំពេញ ខណ្ឌដែលមានចំនួន ប្រជាជនច្រើនជាងគេមានខណ្ឌមានជ័យ មានចំនួនប្រជាជន៣២៧.៨ ពាន់នាក់ក្នុងចំណោមខណ្ឌទាំង១៤ បន្ទាប់មកទៀត មធ្យមគឺខណ្ឌ ពោធិ៍សែនជ័យ មានចំនួនប្រជាជន ២៣៣.៨ នាក់ ហើយខណ្ឌដែលទូចជាងគេគឺខណ្ឌព្រែកព្នៅ មានចំនួនប្រជាជន៤៦.១ពាន់នាក់ ។ ក្នុងខណ្ឌនីមួយៗ អ្នកស្រាវជ្រាវជ្រើសយកសាលាបី គឺជាសាលារៀនមានកម្រិតជាសាលារៀនធំ សាលារៀនមធ្យម និង សាលារៀនតូច។

## ៣.២ វិធីសាស្ត្រប្រមូលទិន្នន័យ

ដោយយោងតាមលិខិតឧទ្ទេសនាមលេខ ១៣៥ វជអ.ជក ចុះថ្ងៃពុធ ៩កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ បានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្ដីពីការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ នៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០ ។ អ្នកស្រាវជ្រាវបានចុះធ្វើការប្រមូលពត៌មានពីវិទ្យាល័យឬអនុវិទ្យាល័យចំនួន៩នៅក្នុងខណ្ឌទាំង៣នៅក្នុងរាជធានីភ្នំពេញ ។

ក្រោយពីទទួលបានលិខិតអនុញ្ញាតចុះប្រមូលទិន្នន័យ ព្រមទាំងបានឆ្លងយោបល់ក្នុងក្របខណ្ឌបច្ចេកទេសជាមួយលោកគ្រូដឹកនាំរួចមកអ្នកសិក្សាបានរៀបចំកម្រងសំណួរដើម្បីចុះប្រមូលទិន្នន័យ។ ក្នុងពេលចុះប្រមូលទិន្នន័យ អ្នកសិក្សាស្រាវជ្រាវបានធ្វើការសហការជាមួយគណៈគ្រប់គ្រង ការិយាល័យរដ្ឋបាល ដើម្បីស្នើសុំការចុះជួបផ្ទាល់ដោយបានបង្ហាញជូននូវស្នើសុំនិងលិខិតអនុញ្ញាតជូនដល់គណៈគ្រប់គ្រងសាលា និងធ្វើការបញ្ជាក់ពីគោលបំណងរបស់អ្នកស្រាវជ្រាវដល់គណៈគ្រប់គ្រងលោកបានយល់ និងជួយសហការក្នុងការឆ្លើយនូវសំណួរបានគ្រប់ជ្រុងជ្រោយហើយពិតប្រាកដអាចយកវិភាគបាន។ ក្នុងការប្រមូលទិន្នន័យនេះ គឺត្រូវប្រើប្រាស់ពេលវេលាសរុបចំនួន៣០ថ្ងៃ ដែលបានទទួលការអនុញ្ញាតពីមន្ទីរអប់រំ យុវជន និង កីឡា នៅរាជធានីភ្នំពេញ។ ក្នុងការប្រមូលទិន្នន័យ គឺប្រើប្រាស់តាមរយៈអនឡាញ ដោយប្រើ(Google Form) និងប្រើកម្រងសំណួរសម្ភាសន៍ផ្ទាល់នៃអនុវិទ្យាល័យចំនួន៦៧ និងជ្រើសរើសយកសាលាចំនួន០៩នៅក្នុងរាជធានីភ្នំពេញដើម្បីយកមកវិភាគទិន្នន័យ។

## ៣.៣.ឧបករណ៍ស្រាវជ្រាវ

ការសិក្សាស្រាជ្រាវនេះត្រូវបានប្រើប្រាស់កម្រងសំណួរដែលមានលក្ខណៈជាទម្រង់បិទ និងជាទម្រង់បើកសម្រាប់ក្រុមគោលដៅជួយបំពេញ និងឆ្លើយសំណួរទៅតាមទស្សនៈយល់ឃើញរបស់ពួកគេ។ កម្រងសំណួរទាំងនោះមានជា៣ផ្នែកគឺៈ ផ្នែកទី (១)ព័ត៌មានទូទៅដែលទាក់ទងស្ថានភាពសាលារៀននៃចំនួន សិស្ស ថ្នាក់ គ្រូ និង ម៉ោងគ្រូតាមមុខវិជ្ជា ផ្នែកទី(២)ផ្តោតទៅលើទស្សនៈរបស់នាយកសាលាលើការកំណត់គ្រូបង្រៀនដែលផ្តោតទៅលើការប្រើប្រាស់គ្រូ បញ្ហាប្រឈម និងដំណោះស្រាយនៃការប្រើប្រាស់គ្រូ និងផ្នែកទី(៣)មតិយោបល់បន្ថែមទាក់ទងនឹងការប្រើប្រាស់គ្រូបង្រៀន។

### *៣.៣.១ កម្រិតចង្អុលបង្ហាញ*

កម្រិតចង្អុលបង្ហាញដែលបានប្រើប្រាស់ក្នុងទម្រង់កម្រងសំណួរដើម្បីចុះប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធទៅតាមការឆ្លើយតបក្នុងកម្រិតជាក់លាក់។ កម្រិតចង្អុលបង្ហាញនេះ គឺប្រើដើម្បីវាស់វែងសូចនាករវាយតម្លៃលើ

កម្រិតនៃការអនុវត្ត និងការប្រើប្រាស់គ្រូ របស់គណៈគ្រប់គ្រង (នាយក នាយករង នាយិការង) ប្រធាន/អនុប្រធានក្រុមបច្ចេកទេសវិទ្យាសាស្ត្រពិត និងសង្គម លោកគ្រូ-អ្នកគ្រូ ដែលកំពុងទទួលខុសត្រូវលើការគ្រប់គ្រង និងដឹកនាំសាលានិងចូលរួមសហការក្នុងការគ្រប់គ្រង សាលារៀននៅអនុវិទ្យាល័យនានាក្នុងរាជធានីភ្នំពេញ។

### *៣.៣.២ កម្រងសំណួរ*

គោលបំណងនៃកម្រងសំណួរនេះដើម្បី(១)សិក្សាស្វែងយល់ពីស្ថានភាពនៃការប្រើប្រាស់គ្រូអនុវិទ្យាល័យនៅរាជធានីភ្នំពេញ (២)ស្វែងរកពីបញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀន (៣)ស្វែងរកដំណោះស្រាយក្នុងការប្រើប្រាស់គ្រូបង្រៀន ។ ទិន្នន័យប្រមូលបានពីកម្រងសំណួរនេះមានគោលបំណងយកទៅប្រើប្រាស់ដើម្បីវិភាគកែលម្អដើម្បីឱ្យកាន់តែទទួលបានប្រសិទ្ធភាពក្នុងការអនុវត្តនៃការប្រើប្រាស់គ្រូបង្រៀននៅតាមអនុវិទ្យាល័យក្នុងរាជធានីភ្នំពេញ។

កម្រងសំណួរដែលត្រូវបានប្រើប្រាស់ចែកជា៣ផ្នែកធំៗគឺ៖

ផ្នែកទី១៖ (១)ព័ត៌មានទូទៅដែលទាក់ទងស្ថានភាពសាលារៀននៃចំនួន សិស្ស ថ្នាក់ គ្រូ និង ម៉ោងគ្រូតាមមុខវិជ្ជា ។

ផ្នែកទី២៖ ផ្តោតទៅលើទស្សនៈរបស់នាយកសាលាលើការកំណត់គ្រូបង្រៀន ដែលផ្តោតទៅលើការប្រើប្រាស់គ្រូ បញ្ហាប្រឈម និងដំណោះស្រាយនៃការប្រើប្រាស់គ្រូ ។

ផ្នែកទី៣៖ មតិយោបល់បន្ថែមទាក់ទងនឹងការប្រើប្រាស់គ្រូបង្រៀន។

## ៣.៤ ការជ្រើសរើសគំរូសំណាក

ការសិក្សាស្រាវជ្រាវនេះ ធ្វើការជ្រើសរើសនូវសំណាក៦៧សាលាដែលស្ថិតនៅក្នុងខណ្ឌ០៣ដែលមានខណ្ឌធំ ខណ្ឌមធ្យម និងខណ្ឌតូច ក្នុងនោះរួមមាន នាយក/នាយិកា នាយករង/នាយិការរង ប្រធានក្រុមបច្ចេកទេសវិទ្យាសាស្ត្រពិត និងសង្គម និងលោកគ្រូ-អ្នកគ្រូ សរុបចំនួន៤៦នាក់ ដែលកំពុងទទួលខុសត្រូវលើការគ្រប់គ្រង និងដឹកនាំសាលា និងចូលរួមសហការក្នុងការគ្រប់គ្រង សាលារៀន ដែលអ្នកសិក្សាស្រាវជ្រាវនឹងធ្វើការសួរ

សំណួរដើម្បីប្រមូលព័ត៌មានដោយធ្វើការកំណត់យកចំនួន៥នាក់ក្នុងសាលានីមួយៗ។ សំណាកទាំងអស់នេះ អ្នកស្រាវជ្រាវត្រូវធ្វើការពិនិត្យឱ្យបានច្បាស់លាស់ដើម្បីទទួលបាននូវ ព័ត៌មានប្រកបដោយគុណភាព និង ប្រសិទ្ធភាពខ្ពស់ក្នុងគោលបំណងសម្រេចបាននូវវត្ថុបំណងនៃការស្រាវជ្រាវ និងអាចឆ្លើយតបទៅនឹងសំណួរ ស្រាវជ្រាវដែលបានចោទសួរទៅលើនាយក/នាយករង នាយិកា/នាយិការង ប្រធានក្រុមបច្ចេកទេស និងលោក គ្រូ-អ្នកគ្រូបង្រៀនផ្ទាល់ ។

## ៣.៥ ការវិភាគទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះប្រើទិន្នន័យតាមបែបបរិមាណវិស័យ និងគុណវិស័យ។ ទិន្នន័យតាមបែបបរិមាណវិស័យត្រូវបានប្រមូលដោយយកស្ថិតិគ្រូ-សិស្សមកពីការិយាល័យមធ្យមសិក្សានៃមន្ទីររាជធានីភ្នំពេញ រីឯទិន្នន័យតាមបែបគុណវិស័យត្រូវបានប្រមូលតាមរយៈការសម្ភាសផ្ទាល់ជាមួយក្រុមគោលដៅ។ ស្ថិតិគ្រូ-សិស្សត្រូវបានអ្នកស្រាវជ្រាវយកប្រើសម្រាប់ធ្វើការវិភាគទៅលើការប្រើប្រាស់គ្រូ ដោយឡែកការបំពេញកម្រងបើក គឺដើម្បីស្វែងយល់ពីការប្រើប្រាស់ បញ្ហាប្រឈម និងដំណោះស្រាយ។ ចំពោះការវិភាគទិន្នន័យបែបបរិមាណវិស័យគឺដោយប្រើប្រាស់កម្មវិធី Excel សម្រាប់គណនារកម្រិតភាគរយ។ ការចាត់ថ្នាក់ជាក្រុម និងដាក់ចំណងជើងដោយផ្អែកលើទស្សនៈ និងអត្ថន័យនៃប្រយោគដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាដើម្បីធ្វើការពន្យល់និងបកស្រាយតាមចំណាត់ថ្នាក់នៃក្រុមនីមួយៗ ត្រូវប្រើសម្រាប់ការវិភាគទិន្នន័យបែបគុណវិស័យ។

## ៣.៦ ក្រមសីលធម៌នៃការសិក្សាស្រាវជ្រាវ

អ្នកស្រាវជ្រាវតែងយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើក្រមសីលធម៌ក្នុងកាចុះស្រាវជ្រាវពីព្រោះវាមានសារៈសំខាន់ណាស់ក្នុងការធានានូវប្រសិទ្ធភាពនៃការស្រាវជ្រាវក៏ដូចជាការបង្កើនទំនុកចិត្ត និងភាពជឿជាក់ដល់អ្នកចូលរួមផ្តល់ចម្លើយសម្រាប់ប្រើប្រាស់នៅក្នុងកិច្ចការស្រាវជ្រាវនេះ។ មុនពេលចុះប្រមូលទិន្នន័យនៅសាលាគោលដៅចំនួន៦៧សាលាក្នុងរាជធានីភ្នំពេញ អ្នកសិក្សាស្រាវជ្រាវបានយកលិខិតអនុញ្ញាតពីថ្នាក់ដឹកនាំវិទ្យាស្ថានជាតិអប់រំ លិខិតអនុញ្ញាតរបស់មន្ទីរអប់រំ យុវជន រាជធានីភ្នំពេញ ដែលកំពុងសិក្សាយកទៅប្រគល់ជូន

នាយកដែលជាក្រុមគោលដៅទាំងអស់ ដើម្បីសុំការអនុញ្ញាតឱ្យជួយសម្រួល និងសុំកិច្ចសហការពីពួកគាត់មុនចុះធ្វើការប្រមូលទិន្នន័យ ដោយឱ្យសំណាកបំពេញកម្រងសំណួរ និងផ្តល់បទសម្ភាសន៍ក្នុងចុះសិក្សាស្រាវជ្រាវនេះ។ ការធ្វើបែបនេះបានធ្វើឱ្យអ្នកសិក្សាស្រាវជ្រាវមានទំនុកចិត្តក្នុងការប្រមូលទិន្នន័យរស់ខ្លួនដោយស្របច្បាប់និងពេញចិត្ត។ ពេលចុះប្រមូលទិន្នន័យអ្នកស្រាវជ្រាវតែងតែបានធ្វើការណែនាំខ្លួនជាមុន និងប្រាប់ពីគោលបំណងនៃការស្រាវជ្រាវរយៈពេលសុំសម្ភាសន៍ ការសន្យាលើលក្ខខណ្ឌមួយចំនួនដូចជារក្សាការសម្ងាត់ជូនពួកគាត់ ហើយព័ត៌មានដែលទទួលបាននឹងមិនយកទៅប្រើប្រាស់ក្នុងគោលបំណងផ្សេងទៀតឡើយ ពេលនោះអ្នកផ្តល់ចម្លើយក៏បានយល់នូវគោលបំណងរបស់អ្នកសិក្សាស្រាវជ្រាវ ហើយអ្នកស្រាវជ្រាវក៏រំពឹងដែរថានឹងទទួលបាននូវចម្លើយ ឬព័ត៌មានដែលពិតពីអ្នកចូលរួមផងដែរ។

## ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

ក្នុងជំពូកនេះអ្នកស្រាវជ្រាវបានធ្វើកាបកស្រាយបួនចំណុចធំៗគឺ ការកំណត់ពីតម្រូវការ ការដោះស្រាយលើការប្រើប្រាស់ ការប្រឈមបញ្ហាក្នុងកាប្រើប្រាស់គ្រូ និងអនុសាសន៍ ។

### ៤.១ ភាកំណត់ពីតម្រូវការប្រើប្រាស់គ្រូនៅរាជធានីភ្នំពេញ

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងទី១ បានបង្ហាញពីស្ថិតិសិស្សសរុបក្នុងសំណាក់ដែលបានជ្រើសរើសចេញពីរាជធានីភ្នំពេញដែលមានចំនួនសិស្ស ៥២៥៣០នាក់ ។ដោយតាមនិយាមសិស្សនៅក្នុងថ្នាក់មានចំនួន៤០នាក់ ដែលកំណត់ដោយច្បាប់ក្នុងនោះចំនួនថ្នាក់នៅក្នុងរាជធានីភ្នំពេញទាំងមូលមានចំនួនសរុប១៣៣៨ថ្នាក់(៥១៣៧៨ចែក៤)។ តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវមាន៣២ម៉ោងក្នុងមួយសប្តាហ៍ ដូចនេះម៉ោងសរុបគឺ៤២៨១៦ម៉ោង(១២៨៤គុណ៣២)។ ហើយត្រូវប្រើប្រាស់គ្រូកម្រិតមូលដ្ឋាន១២+២ចំនួន២៣៧៩នាក់ (៤១០៨៨ចែក១៨) សម្រាប់គ្រប់មុខឯកទេសទាំងអស់ (និយាយគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោងក្នុងមួយសប្តាហ៍។

ប៉ុន្តែតាមទិន្ន័យជាក់ស្តែង ដែលបានមកពីការស្រាវជ្រាវក្នុងរាជធានីភ្នំពេញមានចំនួនសរុបត្រឹមតែ១១៦២ថ្នាក់ប៉ុណ្ណោះ គឺតិចជាងចំនួនថ្នាក់គិតតាមនិយាមមាន១៣៣៨ថ្នាក់ ។

នេះបានបញ្ជាក់អោយឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់រាជធានីភ្នំពេញ មិនទាន់គោរពនៅនិយាមសិស្សថ្នាក់ ដែលកំណត់ដោយក្រសួងអប់រំ យុវជន និង កីឡា នៅឡើយ ។ ឯចំនួនគ្រូដែលមានគុណវុឌ្ឍិ១២+២ ហើយកំពុងបម្រើការងារនៅក្នុងរាជធានីភ្នំពេញនោះវិញ មានចំនួន២៩២៩នាក់ច្រើនជាងតម្រូវការតាមនិយាម៥៤៩នាក់(២៩២៩នាក់ដកនឹង២៣៧៨នាក់)មានន័យថាលើសគ្រូកម្រិតមូលដ្ឋាន១២+២ចំនួន២៩២៩នាក់ បើអនុវត្តតាមនិយាមដែលកំណត់ដោយច្បាប់ និងច្រើនជាងតម្រូវការជាក់ស្តែងដែលកំពុងអនុវត្តជាក់ស្តែងចំនួន៥៥០នាក់។ ដើម្បីដោះស្រាយបញ្ហាខាងលើនេះអនុវិទ្យាល័យនីមួយៗនៅក្នុងរាជធានីភ្នំពេញត្រូវមានវិធីច្រើនដូចជា(១)ប្រើគ្រូខុសកម្រិតឯកទេសមកជួយបង្រៀន (២)ជំរុញដែលត្រូវឯកទេស

បង្រៀនតាមនិយាម ឬបន្ថែមម៉ោងបង្រៀន(៣)បន្ថយចំនួនសិស្សក្នុងថ្នាក់មិនត្រូវនិយាមដើម្បីងាយស្រួលគ្រូបង្រៀនបានទាំងអស់គ្នា។

*តារាងទី 4 ៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង (៣២ម៉ោង)*

| ចំនួន | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្ស | ៥៣៥២០នាក់ | |
| ថ្នាក់ | ១១៦២ថ្នាក់ | ១៣៣៨ថ្នាក់ |
| ម៉ោង | ៣៧១៨៤ម៉ោង | ៤២៨១៦ម៉ោង |
| គ្រូ | ២៩២៩នាក់ | ២៣៧៨នាក់ |
| គ្រូដែលមានគុណវុឌ្ឍិ១២+២ | ២៩២៩នាក់ | |

### *៤.២ .២. ករណីលើស និងខ្វះគ្រូតាមឯកទេសមុខវិជ្ជា*

ប៉ុន្តែបើពិនិត្យឱ្យកាន់តែស៊ីជម្រៅ ទោះបីជាមានការលើសគ្រូ ដែលមានកម្រិតគុណវុឌ្ឍិ១២+២យ៉ាងច្រើនដូចនេះក៏ដោយក៏មិនបញ្ជាក់ថា លើសគ្រូគ្រប់មុខវិជ្ជានោះដែរ ព្រោះចំនួនគ្រូដែលគិតតាមនិយាម និងចំនួនគ្រូដែលកំពុងមានជាក់ស្តែង គឺមានមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ និងមុខវិជ្ជាខ្លះលើសទៅវិញ។ តួយ៉ាងដូចមានបង្ហាញក្នុងក្រាបទី១ រាជធានីទាំងអស់អនុវិទ្យាល័យនេះគិតតាមនិយាមត្រូវមាន២៣៧៩នាក់។ ប៉ុន្តែចំនួនគ្រូដែលមានគុណវុឌ្ឍិ១២+២ ហើយកំពុងបម្រើការក្នុងនោះមានចំនួនតែ២៩២៩នាក់ប៉ុណ្ណោះគឺជាចំនួនដែលលើសពីរការត្រូវការ។

ក្រាហ្វទី១ខាងក្រោមបានបង្ហាញពីតម្រូវការគ្រូតាមនិយាម និងចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២លើមុខវិជ្ជាចំនួន១៣ រួមមានគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដី ភូមិវិទ្យា ប្រវត្តិវិទ្យា និងសីលធម៌ពលរដ្ឋ គេហវិទ្យា ព័ត៌មានវិទ្យា សេដ្ឋកិច្ច កសិកម្ម។ តាមរយៈក្រាបនេះបង្ហាញឱ្យឃើញថា មុខវិជ្ជាកីឡា សេដ្ឋកិច្ច និង កសិកម្ម ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២ខ្វះពីតម្រូវការតាមនិយាម។ ដោយឡែកមុខវិជ្ជាគណិតវិទ្យា អក្សរសាស្ត្រខ្មែរ គណិត ប្រវត្តិវិទ្យា និងសីលធម៌ពលរដ្ឋមានចំនួនគ្រូដែលមានគុណ

វុឌ្ឍិកម្រិត១២+២ច្រើនជាងតម្រូវការ។ នេះស្តែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងរាជធានីភ្នំពេញនេះនៅមានកម្រិត។




*ក្រាហ្វទី 1 ៖ គុណវុឌ្ឍិគ្រូបង្រៀន១២+២តាមមុខវិជ្ជាគិតតាមនិយាម និងតាមការជាក់ស្តែង*

ក្នុងករណីយើងយកបាយម៉ោងសិក្សានៃមុខវិទ្យាឯកទេស៤០ម៉ោងក្នុងមួយសប្តាហ៍យើងនឹងឃើញការប្រែប្រួលតម្រូវការគ្រូបង្រៀនតាមនិយាម យើងទទួលបាន២៥៨២នាក់ ដោយតារាងខាងលើយើងយកបាយនៃមុខវិទ្យាឯកទេស៣២ម៉ោងក្នុងមួយសប្តាហ៍ យើងឃើញថា២៩៧៣នាក់ បើធៀបគ្រូជាក់ស្តែងមាន២៩២៩នាក់ យើងនៅតែមានគ្រូលើសពីតម្រូវការចំនួន៤៤នាក់។

*តារាងទី 5 ៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង (៤០ម៉ោង)*

| ចំនួន | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្ស | ៥៣៥២០ | |
| ថ្នាក់ | ១១៦២ថ្នាក់ | ១៣៣៨ថ្នាក់ |
| ម៉ោង | ៤៦៤៨០ម៉ោង | ៥៣៥២០ម៉ោង |
| គ្រូ | ២៩២៩នាក់ | ២៩៧៣នាក់ |
| គ្រូដែលមានគុណវុឌ្ឍិ(១២បូក២) | ២៩២៩នាក់ | |

## ៤.២ ករណីសិក្សាខណ្ឌទាំងបី (ខណ្ឌមានជ័យ ពោធិ៍សែនជ័យ និងខណ្ឌព្រែកព្នៅ)

### *៤.២.១ ស្ថិតិសិស្ស ថ្នាក់ ម៉ោង និងគ្រូសរុបតាមនិយាម និងជាក់ស្តែងនៅខណ្ឌទាំងបីនៃ រាជធានីភ្នំពេញ*

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងនេះបានបង្ហាញពីស្ថិតិសិស្សសរុបក្នុងសំណាក់ដែលបានជ្រើសរើសចេញពីខណ្ឌបីនៃរាជធានីភ្នំពេញដែលមានចំនួនសិស្ស៩២៥២នាក់។ ដោយតាមនិយាមសិស្សនៅក្នុងថ្នាក់មានចំនួន៤០នាក់ ដែលកំណត់ដោយច្បាប់ក្នុងនោះចំនួនថ្នាក់នៅក្នុងរាជធានីភ្នំពេញទាំងមូលមានចំនួនសរុប២៣១ថ្នាក់(៩២៥២ចែក៤០នាក់)។ តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវមាន៣២ម៉ោងក្នុងមួយសប្តាហ៍ ដូចនេះម៉ោងសរុបគឺ៧៣៩២ម៉ោង(២៣១គុណ៣២)ហើយត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន១២+២ ចំនួន៤១១នាក់(៧៣៩២ចែក១៨)សម្រាប់មុខវិជ្ជាឯកទេសទាំងអស់(និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ ១៨ម៉ោងក្នុងមួយសប្តាហ៍)។

ប៉ុន្តែតាមទន្ន័យជាក់ស្តែង ដែលបានមកពីការស្រាវជ្រាវក្នុងខណ្ឌទាំងបីនៃរាជធានីភ្នំពេញមានចំនួនសរុបត្រឹមតែ១៨៩ថ្នាក់ប៉ុណ្ណោះ គឺតិចជាងចំនួនថ្នាក់គិតតាមនិយាម៤២ថ្នាក់(២៣១ថ្នាក់ដកនឹង១៨៩ថ្នាក់)នេះបានបញ្ជាក់អោយឃើញថា ការប្រើប្រាស់និយាមសិស្សថ្នាក់របស់រាជធានីភ្នំពេញនៃខណ្ឌទាំងបី មិនទាន់គោរព

នៅនិយាមសិស្សថ្នាក់ ដែលកំណត់ដោយក្រសួងអប់រំ យុវជន និង កីឡា នៅឡើយ ។ ឯចំនួនគ្រូដែលមានគុណវុឌ្ឍិ១២+២ ហើយកំពុងបម្រើការងារនៅតាមអនុវិទ្យាល័យទាំង០៩ក្នុងខណ្ឌទាំងបីក្នុងរាជធានីភ្នំពេញមានចំនួន៤៥១នាក់ច្រើនជាងតម្រូវការតាមនិយាម៤១៣នាក់(៤៥១នាក់ដកនឹង៤១៣នាក់)មានន័យថាលើសគ្រូកម្រិតមូលដ្ឋាន១២+២ចំនួន៣៨នាក់ បើអនុវត្តតាមនិយាមដែលកំណត់ដោយច្បាប់ និងច្រើនជាងតម្រូវការជាក់ស្តែងដែលមានកំពុងអនុវត្តជាក់ស្តែងចំនួន៤៥១នាក់ (១៨៩គុណ៣២ចែក១៨)ដើម្បីដោះស្រាយបញ្ហាខាងលើនេះអនុវិទ្យាយនីមួយៗនៅក្នុងរាជធានីភ្នំពេញត្រូវមានវិធីច្រើនដូចជា(១)ប្រើគ្រូខុសកម្រិតឯកទេសជួយបង្រៀន (២)ជំរុញគ្រូត្រូវឯកទេសបង្រៀនតាមនិយាម ឬបន្ថែមម៉ោង(៣)បន្ថយចំនួនសិស្សក្នុងថ្នាក់មិនត្រូវនិយាមដើម្បីគ្រូអាចបង្រៀនបានទាំងអស់គ្នាតែមិនត្រូវនិយាមម៉ោងការងារ។

*តារាងទី 6 ៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង*

| ចំនួន | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្ស | ៩២៥២នាក់ | |
| ថ្នាក់ | ១៨៩ថ្នាក់ | ២៣១ថ្នាក់ |
| ម៉ោង | ៦០៤៨ម៉ោង | ៧៣៩២ម៉ោង |
| គ្រូ | ៤៥១នាក់ | ៤១៣នាក់ |
| គ្រូដែលមានគុណវុឌ្ឍិ១២+២ | ៤៥១នាក់ | |

## *៤.២.២. ករណីលើស និងខ្វះគ្រូតាមឯកទេសមុខវិជ្ជា*

ប៉ុន្តែបើពិនិត្យឱ្យកាន់តែស៊ីជម្រៅ ទោះបីជាមានការលើសគ្រូ ដែលមានកម្រិតគុណវុឌ្ឍិ១២+២យ៉ាងច្រើនដូចនេះក៏ដោយក៏មិនបញ្ជាក់ថា លើសគ្រូគ្រប់មុខវិជ្ជានោះដែរ ព្រោះចំនួនគ្រូដែលគិតតាមនិយាម និងចំនួនគ្រូដែលកំពុងមានជាក់ស្តែង គឺមានមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ និងមុខវិជ្ជាខ្លះលើសទៅវិញ។ តួយ៉ាងដូចមានបង្ហាញក្នុងក្រាហ្វទី១ ចំនួនគ្រូភាសាខ្មែរដែលត្រូវការសម្រាប់អនុវិទ្យាល័យខណ្ឌទាំងបី នៃរាជធានីទាំង៩អនុ

វិទ្យាល័យនេះគិតតាមនិយាមត្រូវមាន៨៩នាក់ ប៉ុន្តែចំនួនគ្រូដែលមានគុណវុឌ្ឍិ១២+២ ហើយកំពុងបម្រើការក្នុងនោះមានចំនួនតែ៧៧នាក់ប៉ុណ្ណោះវាលើសពីការត្រូវការ។




*ក្រាហ្វទី 2៖ គុណវុឌ្ឍិគ្រូបង្រៀន១២+២តាមមុខវិជ្ជាគិតតាមនិយាម និងតាមការជាក់ស្តែង*

ក្រាហ្វខាងលើបង្ហាញពី តម្រូវការគ្រូតាម និយាមនិងចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២លើ មុខវិជ្ជាចំនួន១៣ រួមមានគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដី ភូមិវិទ្យា ប្រវត្តិវិទ្យា និងសីលធម៌ពលរដ្ឋ គេហវិទ្យា ព័ត៌មានវិទ្យា សេដ្ឋកិច្ច កសិកម្ម។ តាមរយៈក្រាហ្វនេះបង្ហាញឱ្យឃើញថា មុខវិជ្ជាភាសាបរទេស ផែនដីវិទ្យា គេហវិទ្យា ភូមិវិទ្យា សេដ្ឋកិច្ច និង កសិកម្ម ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត ១២+២ ខ្វះពីតម្រូវការតាមនិយាម។ ដោយឡែកមុខវិជ្ជាគណិតវិទ្យា អក្សរសាស្ត្រខ្មែរ គណិត ប្រវត្តិវិទ្យា និង

សីលធម៌ពលរដ្ឋមានចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២ច្រើនជាងតម្រូវការ។ នេះស្តែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងរាជធានីភ្នំពេញនេះនៅមានកម្រិត។

### *៤.២.៣ ការប្រឈមបញ្ហាក្នុងការប្រើប្រាស់គ្រូបង្រៀន*

ក្រាហ្វនៃបញ្ហាប្រឈមឃើញចំនួនគ្រូខ្វះច្រើននៅមុខវិជ្ជាឯកទេសបរទេស និង សេដ្ឋកិច្ច ហើយលើសច្រើនមានខ្មែរ ជីវ សីស ព័ត៌មានវិទ្យា។




*ក្រាហ្វទី 3៖ ទិន្នន័យខណ្ឌទាំងបី*

### *៤.២.៤ ដំណោះស្រាយក្នុងការប្រឈមបញ្ហា*

ការដោះស្រាយលើបញ្ហាការលើស ខ្វះគ្រូតាមសាលារៀននីមួយនៅក្នុងខណ្ឌទាំងបីនេះគឺ យកគ្រូលើសទៅជួយគ្រូដែលខ្វះ តែមិនអាចយកគ្រូក្នុងមុខវិជ្ជាវិទ្យាសាស្ត្រពិតទៅជួយគ្រូមុខវិជ្ជាសាស្ត្រសង្គមបានទេ។ ក្រោយពីបានជួបលោកប្រធានការិយាល័យបុគ្គលិកនៅមន្ទីរអប់រំ យុវជន និងកីឡា និងទទួលបានការអនុញ្ញាតក្នុងការធ្វើបទសម្ភាសន៍ទាក់ទិននឹងការប្រើប្រាស់គ្រូបង្រៀននៅកម្រិតមូលដ្ឋាន១២បូក២ នៅអនុវិទ្យាល័យនានា

នៅក្នុងក្រុងភ្នំពេញ គាត់មានប្រសាសន៏ថាជារួមចំនួនគ្រូបង្រៀននៅក្នុងក្រុងភ្នំពេញមានលើសគ្រូច្រើន ធ្វើអោយការចំណាយលុយច្រើនតែមិនបានទទួលបានលទ្ធផលល្អទេ គ្រូធ្វើការតិចម៉ោង ប្រើគ្រូមិនបានអស់លទ្ធភាព ការកំណត់គ្រូត្រូវបានផ្អាក់ការជ្រើសរើសគ្រូថ្មី ។

### *៤.២.៥ អនុសាសន៍របស់ប្រធានការិយាល័យបុគ្គលិកនៃមន្ទីរអប់រំ យុវជន និង កីឡា*

ដើម្បីដោះស្រាយបញ្ហាលើសគ្រូនៅទីប្រជុំជន គាត់សូមអោយក្រសួងធ្វើការសិក្សានៅតាមសាលារៀននីមួយនៅគ្រូដែលមានផ្ទះឆ្ងាយពីសាលារៀនគាត់ស្រាប់ ប្រើគោលការណ៍ស្មគ្រ័ចិត្តដោយផ្តល់កញ្ចប់ថវិកាចំនួនមួយលើ១០លានរៀលម្តងឬ គិតអោយគាត់ចំនួនទឹកប្រាក់១២ខែនៃប្រាក់ខែគាត់ម្តង សម្រាប់គាត់សុខចិត្តពង្រាយទៅសាលារៀនជួបការខ្វះគ្រូ និង អនុវត្តគ្រូដែលបានអសកម្មក្នុងការងារត្រូវបង្ខំអោយពង្រាយ ជាកាពិន័យ ។

## ១.ករណីសិក្សាក្នុងខណ្ឌមានជ័យ

### *១.១ កំណត់តម្រូវការប្រើប្រាស់គ្រូក្នុងខណ្ឌមានជ័យ*

លទ្ធផលនៃការស្រាវជ្រាវ ដូចមានក្នុងតារាងខាងក្រោមនេះបានបង្ហាញពីស្ថិតិសិស្សសរុបក្នុងសំណាក់ដែលបានជ្រើសរើសចេញពីខណ្ឌមានជ័យនៃរាជធានីភ្នំពេញដែលមានចំនួនសិស្ស ២៥៨៣នាក់ដោយតាមនិយាមសិស្សនៅក្នុងថ្នាក់មានចំនួន៤០នាក់ ដែលកំណត់ដោយច្បាប់ក្នុងនោះចំនួនថ្នាក់នៅទាំងមូលមានចំនួនសរុប៦៤ថ្នាក់(២៥៨៣ចែក៤០នាក់)។ តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវមាន៣២ម៉ោងក្នុងមួយសប្តាហ៍ ដូចនេះម៉ោងសរុប គឺ២០៤៨ម៉ោង ហើយត្រូវប្រើប្រាស់គ្រូ (៦៤គុណ៣២) គ្រូបង្រៀនកម្រិតមូលដ្ឋាន១២+២ចំនួន១១៣នាក់(២០៤៨ចែក១៨) សម្រាប់គ្រប់មុខវិជ្ជាឯកទេសទាំងអស់(និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោងក្នុងមួយសប្តាហ៍)។

*តារាងទី 7៖ ស្ថិតិសិស្ស ថ្នាក់ គ្រូ និងម៉ោង សរុបតាមជាក់ស្តែងនិងនិយាម*

| | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|

| | | |
|---|---|---|
| សិស្សសរុប | ២៥៣៨នាក់ | |
| ថ្នាក់សរុប | ៦០ | ៦៤ |
| គ្រូសរុប | ១៥៧ | ១១៣ |
| ម៉ោង | ១៩២០ | ២០៤៨ |

### *១.២. ការលើស និងខ្វះតាមមុខវិជ្ជាឯកទេស*

តាមលទ្ធផលនៃការស្រាវជ្រាវក្នុងខណ្ឌមានជ័យក្នុងតារាងខាងក្រោម បានបង្ហាញឱ្យឃើញពីគ្រូសរុបរបស់អនុវិទ្យាល័យទាំងបី ដែលនាងខ្ញុំបានស្រាវជ្រាវមានស្ថិតិចំនួនគ្រូ១៥៧នាក់ ស្មើ៥% និងលើសគ្រូពីតម្រូវការ៤៤នាក់ស្មើ២៣%




*ក្រាហ្វទី 4 ៖ ស្ថិតិគ្រូនៃខណ្ឌមានជ័យ*

ប៉ុន្តែបើពិនិត្យឱ្យកាន់តែស៊ីជម្រៅ ទោះបីជាមានការលើសគ្រូ ដែលមានកម្រិតគុណវុឌ្ឍិ១២+២យ៉ាងច្រើនដូចនេះក៏ដោយក៏មិនបញ្ជាក់ថា លើសគ្រូគ្រប់មុខវិជ្ជានោះដែរ ព្រោះចំនួនគ្រូដែលគិតតាមនិយាម និងចំនួនគ្រូ

ដែលកំពុងមានជាក់ស្តែង គឺមានមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ និងមុខវិជ្ជាខ្លះលើសទៅវិញ។ តួយ៉ាងដូចមានបង្ហាញក្នុងក្រាហ្វនេះ ចំនួនគ្រូភាសាខ្មែរដែលត្រូវការសម្រាប់អនុវិទ្យាល័យខណ្ឌទី១ នៃរាជធានីទាំង៣អនុវិទ្យាល័យនេះគិតតាមនិយាមត្រូវមាន១៥៧ នាក់ ប៉ុន្តែចំនួនគ្រូដែលមានគុណវុឌ្ឍិ១២+២ ហើយកំពុងបម្រើការក្នុង មានចំនួនតែ១១៣នាក់ប៉ុណ្ណោះវាលើសពីការត្រូវការ។

### *១.៣ ការប្រឈមបញ្ហាក្នុងការប្រើប្រាស់គ្រូ*

ក្រាហ្វខាងក្រោមបង្ហាញពី តម្រូវការគ្រូតាម និយាមនិងចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២លើ មុខវិជ្ជាចំនួន១៣ រួមមានគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដី ភូមិវិទ្យា ប្រវត្តិវិទ្យា និងសីលធម៌ពលរដ្ឋ គេហវិទ្យា ព័ត៌មានវិទ្យា សេដ្ឋកិច្ច កសិកម្ម។ តាមរយៈក្រាបនេះបង្ហាញឱ្យឃើញថា មុខវិជ្ជា សេដ្ឋកិច្ច និង កសិកម្ម ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២ ខ្វះពីតម្រូវការតាមនិយាមច្រើនជាងគេ។ ដោយឡែកមុខវិជ្ជាគណិតវិទ្យា អក្សរសាស្ត្រខ្មែរ ជីវវិទ្យា ព័ត៌មានវិទ្យា មានចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២ លើសច្រើនជាងតម្រូវការ។ នេះស្តែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងខណ្ឌទី១នេះនៅមានកម្រិត ។




*ក្រាហ្វទី 5៖ ស្ថិតិសាលាទាំងបី*

### ១.៤. ដំណោះស្រាយបញ្ហាប្រឈម

យកគ្រូនៃមុខវិជ្ជាឯកទេសលើសគ្រូខ្មែរ ជីវវិទ្យា ព័ត៌មានវិទ្យា ទៅជំនួសគ្រូខ្វះមានគ្រូផែនដី គ្រូភូមិ គ្រូកសិកម្ម ចំណែកគ្រូឯកទេសគណិតវិទ្យាអាចជំនួសក្នុងឯកទេសវិទ្យាសាស្ត្រពិត វិទ្យាសាស្ត្រពិតលើសច្រើន ដើម្បីឱ្យគ្រូធ្វើការបង្រៀនបានទាំងអស់គ្នា ដូចនេះម្នាក់បង្រៀន មិនគ្រប់និយាមម៉ោងគ្រូបង្រៀន គឺ១៨ម៉ោងក្នុងមួយសប្តាហ៍។

**ករណីសាលារៀនទី១**

### ១. ការកំណត់តម្រូវការប្រើប្រាស់គ្រូ

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងទី២បានបង្ហាញពីស្ថិតិសិស្សសរុបក្នុងសំណាក់ដែលបានជ្រើសរើសចេញពីខណ្ឌមានជ័យនៃរាជធានីភ្នំពេញនៃសាលារៀនទី១ ដែលមានចំនួនសិស្ស៥៨២នាក់ ដោយតាម

និយាមសិស្សនៅក្នុងថ្នាក់មានចំនួន៤០នាក់ ដែលកំណត់ដោយច្បាប់ក្នុងនោះចំនួនថ្នាក់នៅក្នុងវិទ្យាល័យចំរើនផលទាំងមូលមានចំនួនសរុប១៥ថ្នាក់(៥៨២ចែក៤០នាក់)។ តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវមាន៣២ម៉ោងក្នុងមួយសប្ដាហ៍ ដូចនេះម៉ោងសរុប គឺ៤៨០ម៉ោង(១៥គុណ៣២) ហើយត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន១២+២ ចំនួន២៦នាក់(៤៨០ចែក១៨) សម្រាប់គ្រប់មុខវិជ្ជាឯកទេសទាំងអស់ (និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោងក្នុងមួយសប្ដាហ៍)។

*តារាងទី ៨ ៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្ដែង*

| | តាមជាក់ស្ដែង | តាមនិយាម |
|---|---|---|
| សិស្សសរុប | ៥៨២នាក់ | |
| ថ្នាក់សរុប | ១៦ | ១៥ |
| គ្រូសរុប | ៤០ | ២៦ |
| ម៉ោង | ៥១២ | ៤៨០ |

### *១.១. ការលើស និង ខ្វះតាមមុខវិជ្ជាឯកទេស*

ប៉ុន្តែបើពិនិត្យឱ្យកាន់តែស៊ីជម្រៅ ទោះបីជាមានការលើសគ្រូ ដែលមានកម្រិតគុណវុឌ្ឍិ១២+២យ៉ាងច្រើនដូចនេះក៏ដោយក៏មិនបញ្ជាក់ថា លើសគ្រូគ្រប់មុខវិជ្ជានោះដែរ ព្រោះចំនួនគ្រូដែលគិតតាមនិយាម និងចំនួនគ្រូដែលកំពុងមានជាក់ស្ដែង គឺមានមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ និងមុខវិជ្ជាខ្លះលើសទៅវិញ។ តួយ៉ាងដូចមានបង្ហាញក្នុងក្រាហ្វទី១ ចំនួនគ្រូភាសាខ្មែរដែលត្រូវការសម្រាប់អនុវិទ្យាល័យខណ្ឌទាំងបីនៃរាជធានីទាំង០៩អនុវិទ្យាល័យនេះគិតតាមនិយាមត្រូវមាន១០៤នាក់ ប៉ុន្តែចំនួនគ្រូដែលមានគុណវុឌ្ឍិ១២+២ ហើយកំពុងបម្រើការក្នុង មានចំនួនតែ១១៤នាក់ប៉ុណ្ណោះវាលើសពីការត្រូវការ។

ក្រាហ្វខាងក្រោមបង្ហាញពី តម្រូវការគ្រូតាម និយាមនិងចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២ លើមុខវិជ្ជាចំនួន១៣ រួមមានគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដី ភូមិវិទ្យា ប្រវត្តិវិទ្យា និងសីលធម៌ពលរដ្ឋ គេហវិទ្យា ព័ត៌មានវិទ្យា សេដ្ឋកិច្ច កសិកម្ម។ តាមរយៈក្រាហ្វនេះបង្ហាញឱ្យឃើញថា មុខវិជ្ជាភាសាបរទេស ផែនដី ប្រវត្តិ គីមី សេដ្ឋកិច្ច និង កសិកម្ម ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២ ខ្វះពីតម្រូវការតាមនិយាម។ ដោយឡែកមុខវិជ្ជាគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា ជីវវិទ្យា គេហវិទ្យា ព័ត៌មានវិទ្យា និងសីលធម៌ពលរដ្ឋមានចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២ ច្រើនជាងតម្រូវការ។ នេះស្តែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងសាលារៀនទី១នេះនៅមានកម្រិត។




*ក្រាហ្វទី 6៖ ចំនួនម៉ោងជាក់ស្តែងតាមនិយាម*

## ២. ការបញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូ

ក្នុងការប្រឈមទៅលើការលើសគ្រូច្រើន ទៅលើគ្រូ គណិតវិទ្យា និង ជីវវិទ្យាខ្វះគ្រូ ភាសាបរទេស គីមី សេដ្ឋកិច្ច កសិកម្ម។




*ក្រាហ្វទី 7៖ ការប្រេឈមលើសគ្រូ និងខ្វះគ្រូ*

### ៣. ដំណោះស្រាយលើការប្រេឈម

មុខវិជ្ជាគណិតវិទ្យា អាចជំនួសគីមីវិទ្យា មុខវិជ្ជាភាសាខ្មែរ ជីវវិទ្យា គេហៈវិទ្យា សីលធម៌ អាចជំនួស ផែនដី សេដ្ឋ កសិកម្ម មិនតែដូច្នេះគ្រូបង្រៀនមិនគ្រប់ម៉ោងតាមនិយាម។

**ករណីសាលារៀនទី២**

### ១. កំណត់តម្រូវការគ្រូបង្រៀន

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងទី២បានបង្ហាញពីស្ថិតិសិស្សសរុបក្នុងសំណាក់ដែលបានជ្រើសរើសចេញពីខណ្ឌមានជ័យនៃរាជធានីភ្នំពេញនៃសាលារៀនទី២ដែលមានចំនួនសិស្ស ១៤៦៣នាក់ដោយតាមនិយាមសិស្សនៅក្នុងថ្នាក់មានចំនួន៤០នាក់ដែលកំណត់ដោយច្បាប់ក្នុងនោះចំនួនថ្នាក់នៅក្នុងវិទ្យាល័យទាំងមូលមានចំនួនសរុប៣៧ថ្នាក់(១៤៦៣ចែក៤០នាក់)។តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវមាន៣២ម៉ោងក្នុងមួយសប្តាហ៍ ដូចនេះម៉ោងសរុប គឺ១១៨៤ម៉ោងហើយ (៣៧គុណ៣២)ត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន ១២+២ ចំនួន៦៦នាក់(១១៨៤ចែក១៨)សម្រាប់មុខវិជ្ជាឯកទេសទាំងអស់ (និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោងក្នុងមួយសប្តាហ៍)។

*តារាងទី ១៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្ដែង*

| ស្ថិតិសិស្ស ថ្នាក់ គ្រូ និង ម៉ោងនៅវិទ្យាល័យទី២ | | |
|---|---|---|
| | តាមជាក់ស្ដែង | តាមនិយាម |
| សិស្សសរុប | ១៤៦៣នាក់ | |
| ថ្នាក់សរុប | ៣២ | ៣៧ |
| គ្រូសរុប | ៧០ | ៦៦ |
| ម៉ោង | ១០២៤ | ១១៨៤ |

## *១.២ ការលើស និងការខ្វះគ្រូ*

ប៉ុន្តែបើពិនិត្យឱ្យកាន់តែស៊ីជម្រៅ ទោះបីជាមានការលើសគ្រូ ដែលមានកម្រិតគុណវុឌ្ឍិ១២+២យ៉ាងច្រើនដូចនេះក៏ដោយក៏មិនបញ្ជាក់ថា លើសគ្រូគ្រប់មុខវិជ្ជានោះដែរ ព្រោះចំនួនគ្រូដែលគិតតាមនិយាម និងចំនួនគ្រូដែលកំពុងមានជាក់ស្ដែង គឺមានមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ និងមុខវិជ្ជាខ្លះលើសទៅវិញ។ តួយ៉ាងដូចមានបង្ហាញក្នុងក្រាហ្វទី១ ចំនួនគ្រូភាសាខ្មែរដែលត្រូវការសម្រាប់វិទ្យាល័យទៅនៃខណ្ឌមានជ័យរាជធានីគិតតាមនិយាមត្រូវមាន៦៦នាក់ ប៉ុន្តែចំនួនគ្រូដែលមានគុណវុឌ្ឍិ១២+២ ហើយកំពុងបម្រើការក្នុង មានចំនួន៧០នាក់ ប៉ុណ្ណោះវាលើសពីការត្រូវការ។

ក្រាហ្វខាងក្រោមបង្ហាញពី តម្រូវការគ្រូតាម និយាមនិងចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២លើ មុខវិជ្ជាចំនួន១៣ រួមមានគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដី ភូមិវិទ្យា ប្រវត្តិវិទ្យា និងសីលធម៌ពលរដ្ឋ គេហវិទ្យា ព័ត៌មានវិទ្យា សេដ្ឋកិច្ច កសិកម្ម។ តាមរយៈក្រាហ្វនេះបង្ហាញឱ្យឃើញថា មុខវិជ្ជាផែនដី ភូមិ គីមី សេដ្ឋកិច្ច និង កសិកម្ម ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២ ខ្វះពីតម្រូវការតាមនិយាម។ ដោយឡែកមុខវិជ្ជាគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា ជីវវិទ្យា គេហវិទ្យា ព័ត៌មានវិទ្យា និងសីលធម៌-ពលរដ្ឋ

មានចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២ ច្រើនជាងតម្រូវការ។ នេះស្តែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងសាលារៀនទី១នេះនៅមានកម្រិត។




*ក្រាហ្វទី ៩៖ គុណវុឌ្ឍិគ្រូបង្រៀន១២+២តាមមុខវិជ្ជាគិតតាមនិយាម និងតាមការជាក់ស្តែង*

## ២. បញ្ហាប្រឈមក្នុងប្រើប្រាស់គ្រូបង្រៀន

ការខ្វះគ្រូច្រើនដែលមានចំនួន១៨នាក់ លើសគ្រូ ១១នាក់




*ក្រាហ្វទី ៩៖ ការប្រឈមក្នុងការខ្វះគ្រូ*

### ៣. ដំណោះស្រាយបញ្ហាប្រឈម

យកមុខវិជ្ជាឯកទេសខ្មែរ សីល មកជំនួស ភូមិវិទ្យា កសិកម្ម ផែនដី ចំណែកឯគណិតវិទ្យា គីមីវិទ្យា មកជំនួស រូបវិទ្យា ក្នុងសាលារៀននេះមាន គ្រូបង្រៀនខ្លះបង្រៀនលើសម៉ោងនិយាម។

## ករណីសាលារៀនទី៣

### ១. ការកំណត់តម្រូវការគ្រូ

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងនេះ បានបង្ហាញពីស្ថិតិសិស្សសរុបក្នុងសំណាកដែលបានជ្រើសរើសចេញពីខណ្ឌមានជ័យនៃរាជធានីភ្នំពេញនៃសាលារៀនទី៣ ដែលមានចំនួនសិស្ស៤៩៣នាក់ ដោយតាមនិយាមសិស្សនៅក្នុងថ្នាក់មានចំនួន៤០នាក់ ដែលកំណត់ដោយច្បាប់ក្នុងនោះចំនួនថ្នាក់នៅក្នុងវិទ្យាល័យទាំងមូលមានចំនួនសរុប១២ថ្នាក់៤៩៣ចែក៤០នាក់)។ តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវមាន៣២ម៉ោងក្នុងមួយសប្តាហ៍ ដូចនេះម៉ោងសរុប គឺ៣៨៤ម៉ោង( ១២គុណ៣២ )។ ហើយត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិត

មូលដ្ឋាន១២+២ចំនួន២១នាក់(៣៨៤ចែក១៨)សម្រាប់គ្រប់មុខវិជ្ជាឯកទេសទាំងអស់(និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោងក្នុងមួយសប្តាហ៍)។

*តារាងទី 10៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង*

| | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្សសរុប | ៤៩៣នាក់ | |
| ថ្នាក់សរុប | ១២ | ១២ |
| គ្រូសរុប | ៥៨ | ២១ |
| ម៉ោង | ៣៨៤ | ៣៨៤ |

**១. ការលើស និងការខ្វះគ្រូតាមមុខវិជ្ជាឯកទេស**

ប៉ុន្តែបើពិនិត្យឱ្យកាន់តែស៊ីជម្រៅ ទោះបីជាមានការលើសគ្រូ ដែលមានកម្រិតគុណវុឌ្ឍិ១២+២យ៉ាងច្រើនដូចនេះក៏ដោយក៏មិនបញ្ជាក់ថា លើសគ្រូគ្រប់មុខវិជ្ជានោះដែរ ព្រោះចំនួនគ្រូដែលគិតតាមនិយាម និងចំនួនគ្រូដែលកំពុងមានជាក់ស្តែង គឺមានមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ និងមុខវិជ្ជាខ្លះលើសទៅវិញ។ តួយ៉ាងដូចមានបង្ហាញក្នុងក្រាហ្វខាងក្រោមនេះចំនួនគ្រូភាសាខ្មែរដែលត្រូវការសម្រាប់វិទ្យាល័យ នៃខណ្ឌមានជ័យ រាជធានីភ្នំពេញ គិតតាមនិយាមត្រូវមាន២១នាក់ ប៉ុន្តែចំនួនគ្រូដែលមានគុណវុឌ្ឍិ១២+២ ហើយកំពុងបម្រើការក្នុងមានចំនួន៥៨នាក់ប៉ុណ្ណោះវាលើសពីការត្រូវការ។

ក្រាហ្វទី១ខាងក្រោមបង្ហាញពី តម្រូវការគ្រូតាម និយាមនិងចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២លើ មុខវិជ្ជាចំនួន១៣ រួមមានគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដី ភូមិវិទ្យា ប្រវត្តិវិទ្យា និងសីលធម៌ពលរដ្ឋ គេហវិទ្យា ព័ត៌មានវិទ្យា សេដ្ឋកិច្ច កសិកម្ម។ តាមរយៈក្រាហ្វនេះបង្ហាញឱ្យឃើញថា មុខវិជ្ជា សេដ្ឋកិច្ច ព័ត៌មានវិទ្យា និង កសិកម្ម ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២ ខ្វះពីតម្រូវការតាម

និយាម។ ដោយឡែកមុខវិជ្ជាគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា គេហវិទ្យា  និងសីលធម៌ពលរដ្ឋមានចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២ច្រើនជាងតម្រូវការ។  នេះស្តែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងសាលារៀនទី១នេះនៅមានកម្រិត។




*ក្រាហ្វទី 10៖ គុណវុឌ្ឍិគ្រូបង្រៀន១២+២តាមមុខវិជ្ជាគិតតាមនិយាម និងតាមការជាក់ស្តែង*

## ២. បញ្ហាប្រឈមនៃការប្រើប្រាស់គ្រូបង្រៀន

ការលើសគ្រូច្រើន២៧នាក់ និងខ្វះគ្រូ៤ នាក់




*ក្រាហ្វទី 11៖ ការលើសគ្រូ*

៣. ដំណោះស្រាយបញ្ហាប្រឈម

ការយកមុខវិជ្ជាភាសាខ្មែរ ជីវវិទ្យា ផែនដី ប្រវត្តិវិទ្យា ភូមិវិទ្យា យកជំនួស សីលធម៌ពលរដ្ឋ សេដ្ឋកិច្ច កសិកម្ម នៅសល់គ្រូច្រើន ។

## ២ .ករណីសិក្សាក្នុងខណ្ឌពោធិ៍សែនជ័យ

### *២.១ ការកំណត់តម្រូវការប្រើប្រាស់គ្រូ*

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងទី២ បានបង្ហាញពីស្ថិតិសិស្សសរុបក្នុងសំណាក់ដែលបានជ្រើសរើសចេញពីខណ្ឌមានជ័យនៃរាជធានីភ្នំពេញដែលមានចំនួនសិស្ស៥០៧៨នាក់ដោយតាមនិយាមសិស្សនៅក្នុងថ្នាក់មានចំនួន៤០នាក់ ដែលកំណត់ដោយច្បាប់ក្នុងនោះចំនួនថ្នាក់នៅទាំងមូលមានចំនួនសរុបថ្នាក់ ១២៧ថ្នាក់ (៥០៧៨នាក់ចែក៤០នាក់)។ តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវមាន៣២ម៉ោងក្នុងមួយសប្ដាហ៍ ដូចនេះម៉ោងសរុបគឺ៤០៦០ម៉ោង(១២៧គុណ៣២)ហើយត្រូវប្រើប្រាស់គ្រូកម្រិតមូលដ្ឋាន១២+២ចំនួន

២២៧នាក់(៤០៦០ចែក១៨)សម្រាប់មុខវិជ្ជាឯកទេសទាំងអស់(និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោងក្នុងមួយសប្តាហ៍)។

*តារាងទី 11៖ សិស្ស ថ្នាក់ ម៉ោង និង គ្រូសរុបនៃខណ្ឌទី២*

| | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្សសរុប | ៥០៧៨នាក់ | |
| ថ្នាក់សរុប | ៩៥ | ១២៧ |
| គ្រូសរុប | ២០០ | ២២៧ |
| ម៉ោង | ៣០៤០ | ៤០៦០ |

## *២ ២.ការខ្វះគ្រូបង្រៀន និងលើសគ្រូបង្រៀន*

តាមលទ្ធផលនៃការស្រាវជ្រាវក្នុងខណ្ឌពោធិ៍សែនជ័យក្នុងតារាងខាងក្រោម បានបង្ហាញឱ្យឃើញពីគ្រូសរុបរបស់អនុវិទ្យាល័យទាំងបីដែលនាងខ្ញុំបានស្រាវជ្រាវមានស្ថិតិចំនួនគ្រូ២០០នាក់ ស្មើ៦% និងខ្វះគ្រូពីតម្រូវការ២៧នាក់។




*ក្រាហ្វទី 12៖ ការខ្វះគ្រូ*

ប៉ុន្តែបើពិនិត្យឱ្យកាន់តែស៊ីជម្រៅ ទោះបីជាមានការខ្វះគ្រូ ដែលមានកម្រិតគុណវុឌ្ឍិ១២+២យ៉ាងច្រើនដូចនេះក៏ដោយក៏មិនបញ្ជាក់ថា លើសគ្រូគ្រប់មុខវិជ្ជានោះដែរ ព្រោះចំនួនគ្រូដែលគិតតាមនិយាម និងចំនួនគ្រូដែលកំពុងមានជាក់ស្តែង គឺមានមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ និងមុខវិជ្ជាខ្លះលើសទៅវិញ។ តួយ៉ាងដូចមានបង្ហាញក្នុងក្រាហ្វទី១ ចំនួនគ្រូភាសាខ្មែរដែលត្រូវការសម្រាប់អនុវិទ្យាល័យខណ្ឌទី២ នៃរាជធានីទាំង៣អនុវិទ្យាល័យនេះគិតតាមនិយាមត្រូវមាន២២៧ នាក់ ប៉ុន្តែចំនួនគ្រូដែលមានគុណវុឌ្ឍិ១២+២ ហើយកំពុងបម្រើការក្នុងមានចំនួនតែ២០០នាក់ប៉ុណ្ណោះវាលើសពីរការត្រូវការ។

ក្រាហ្វខាងក្រោមនេះបង្ហាញពី តម្រូវការគ្រូតាម និយាមនិងចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២លើ មុខវិជ្ជាចំនួន១៣ រួមមានគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា ភូមិវិទ្យា ប្រវត្តិវិទ្យា និងសីលធម៌ពលរដ្ឋ គេហវិទ្យា ព័ត៌មានវិទ្យា សេដ្ឋកិច្ច កសិកម្ម។ តាមរយៈក្រាហ្វនេះបង្ហាញឱ្យឃើញថា មុខវិជ្ជា គណិតវិទ្យា និង ភាសាបរទេស ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២ ខ្វះពីតម្រូវការតាមនិយាមច្រើនជាងគេ។ ដោយឡែកមុខវិជ្ជា អក្សរសាស្ត្រខ្មែរ ជីវវិទ្យា មានចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២លើសច្រើនជាងតម្រូវការ។ នេះស្តែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងខណ្ឌទី១នេះនៅមានកម្រិត។

### *២.៣ បញ្ហាប្រឈមនៃការខ្វះគ្រូតាមមុខវិជ្ជាឯកទេស*

ការខ្វះគ្រូឯកទេសមុខវិជ្ជា គណិតវិទ្យា ភាសាបរទេស សេដ្ឋកិច្ច ច្រើន




*ក្រាហ្វទី 12៖ លើសគ្រូនិងខ្វះគ្រូឯកទេស*

## *២.៤ ដំណោះស្រាយបញ្ហា*

គ្រូបង្រៀនលើសនិយាម  ហើយមានខ្លះមិនត្រូវឯកទេស តែយកគ្រូបង្រៀនពីរឯកទេស ទៅបង្រៀនឯកទេស ដែលខ្វះ ។

## ករណីសាលារៀនទី១

### ១. ការកំណត់តម្រូវការគ្រូ

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងនេះបានបង្ហាញពីស្ថិតិសិស្សសរុបក្នុងសំណាក់ដែលបានជ្រើសរើសចេញពីខណ្ឌពោធិ៍សែនជ័យនៃរាជធានីភ្នំពេញនៃសាលារៀនទី១ ដែលមានចំនួនសិស្ស៣០៧៥នាក់ ដោយតាមនិយាមសិស្សនៅក្នុងថ្នាក់មានចំនួន៤០នាក់ដែលកំណត់ដោយច្បាប់ក្នុងនោះចំនួនថ្នាក់នៅក្នុងវិទ្យាល័យទាំងមូលមានចំនួនសរុប៧៧ថ្នាក់(៣០៧៥ចែក៤០នាក់)។ តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវមាន៣២ម៉ោងក្នុងមួយសប្តាហ៍ ដូចនេះម៉ោងសរុបគឺ២៤៦០ម៉ោង (៧៧គុណ៣២) ហើយត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន១២+២ ចំនួន១៣៧នាក់(២៤៦០ចែក១៨)សម្រាប់គ្រប់មុខវិជ្ជាឯកទេសទាំងអស់ (និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោងក្នុងមួយសប្តាហ៍)។

*តារាងទី 12៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង*

| | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្សសរុប | ៣០៧៥នាក់ | |
| ថ្នាក់សរុប | ៥៨ | ៧៧ |
| គ្រូសរុប | ១១៦ | ១៣៧ |
| ម៉ោង | ១៨៥៦ | ២៤៦០ |

### *១.១ ការលើស និងខ្វះគ្រូតាមមុខវិជ្ជាឯកទេស*

ប៉ុន្តែបើពិនិត្យឱ្យកាន់តែស៊ីជម្រៅ ទោះបីជាមានការលើសគ្រូ ដែលមានកម្រិតគុណវុឌ្ឍិ១២+២ យ៉ាងច្រើនដូចនេះក៏ដោយក៏មិនបញ្ជាក់ថា លើសគ្រូគ្រប់មុខវិជ្ជានោះដែរ ព្រោះចំនួនគ្រូដែលគិតតាមនិយាម និងចំនួនគ្រូដែលកំពុងមានជាក់ស្តែង គឺមានមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ និងមុខវិជ្ជាខ្លះលើសទៅវិញ។ តួយ៉ាងដូចមាន

បង្ហាញក្នុងក្រាហ្វខាងក្រោមនេះបានបង្ហាញចំនួនគ្រូភាសាខ្មែរដែលត្រូវការសម្រាប់វិទ្យាល័យទៅនៃខណ្ឌមានជ័យរាជធានីគិតតាមនិយាមត្រូវមាន១១៦នាក់ ប៉ុន្តែចំនួនគ្រូដែលមានគុណវុឌ្ឍិ១២+២ ហើយកំពុងបម្រើការក្នុង មានចំនួន១៣៧នាក់ប៉ុណ្ណោះវាលើសពីរការត្រូវការ។

ក្រាហ្វទី១ខាងក្រោមបង្ហាញពី តម្រូវការគ្រូតាម និយាមនិងចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២លើ មុខវិជ្ជាចំនួន១៣ រួមមានគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីវិទ្យា ភូមិវិទ្យា ប្រវត្តិវិទ្យា និងសីលធម៌ពលរដ្ឋ គេហវិទ្យា ព័ត៌មានវិទ្យា សេដ្ឋកិច្ច កសិកម្ម។ តាមរយៈក្រាហ្វនេះបង្ហាញឱ្យឃើញថា មុខវិជ្ជា គីមីវិទ្យា ផែនដីវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា សេដ្ឋកិច្ច និង កសិកម្ម ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២ ខ្វះពីតម្រូវការតាមនិយាម។ ដោយឡែកមុខវិជ្ជាគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា បរទេស ពត៌មានវិទ្យា ជីវវិទ្យា គេហវិទ្យា និងសីលធម៌ពលរដ្ឋ មានចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២ ច្រើនជាងតម្រូវការ។ នេះស្តែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងសាលារៀនទី១នេះនៅមានកម្រិត។




*ក្រាហ្វទី 13៖ គុណវុឌ្ឍិគ្រូបង្រៀន១២+២តាមមុខវិជ្ជាគិតតាមនិយាម និងតាមការជាក់ស្តែង*

## ២. បញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀន

ការខ្វះគ្រូមុខវិជ្ជាឯកទេសច្រើន៣៧នាក់ ភាគច្រើនមុខវិជ្ជាគណិតវិទ្យា




*ក្រាហ្វទី 14៖ ការខ្វះគ្រូ*

## ៣. ដំណោះស្រាយបញ្ហាប្រឈម

បង្កើននិយាមម៉ោងបង្រៀន ហើយគ្រូបង្រៀនមិនត្រូវមុខវិជ្ជាឯកទេស។

## ករណីសាលារៀនទី២

## ១. ការកំណត់តម្រូវការគ្រូបង្រៀន

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងទី២បានបង្ហាញពីស្ថិតិសិស្សសរុបក្នុងសំណាក់ដែលបានជ្រើសរើសចេញពីខណ្ឌពោធិ៍សែនជ័យនៃរាជធានីភ្នំពេញនៃសាលារៀនទី២ ដែលមានចំនួនសិស្ស៨២២នាក់ដោយតាមនិយាមសិស្សនៅក្នុងថ្នាក់មានចំនួន៤០នាក់ ដែលកំណត់ដោយច្បាប់ក្នុងនោះចំនួនថ្នាក់នៅក្នុងវិទ្យាល័យ

ទាំងមូលមានចំនួនសរុប២០ថ្នាក់(៨២២ចែក៤០នាក់)។ តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវមាន៣២ម៉ោងក្នុងមួយសប្តាហ៍ ដូចនេះម៉ោងសរុបគឺ៦៤០ម៉ោង (២០គុណ៣២) ហើយត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន១២+២ ចំនួន៣៦នាក់(៦៤០ចែក១៨) សម្រាប់មុខវិជ្ជាឯកទេសទាំងអស់ (និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោងក្នុងមួយសប្តាហ៍)។

*តារាងទី 13៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង*

| | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្សសរុប | ៨២២នាក់ | |
| ថ្នាក់សរុប | ១៣ | ២០ |
| គ្រូសរុប | ៣៣ | ៣៦ |
| ម៉ោង | ៤១៦ | ៦៤០ |

### *១.១ ការលើស និងខ្វះគ្រូបង្រៀនតាមមុខវិជ្ជាឯកទេស*

ប៉ុន្តែបើពិនិត្យឱ្យកាន់តែស៊ីជម្រៅ ទោះបីជាមានការខ្វះគ្រូ ដែលមានកម្រិតគុណវុឌ្ឍិ១២+២ដូចនេះក៏ដោយក៏មិនបញ្ជាក់ថា មានលើសគ្រូគ្រប់មុខវិជ្ជានោះដែរ ព្រោះចំនួនគ្រូដែលគិតតាមនិយាម និងចំនួនគ្រូដែលកំពុងមានជាក់ស្តែង គឺមានមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ និងមុខវិជ្ជាខ្លះលើសទៅវិញ។ តួយ៉ាងដូចមានបង្ហាញក្នុងក្រាហ្វទី១ ដែលត្រូវការសម្រាប់វិទ្យាល័យទៅ នៃខណ្ឌមានជ័យរាជធានីគិតតាមនិយាមត្រូវមាន៣៦នាក់។ ប៉ុន្តែចំនួនគ្រូដែលមានគុណវុឌ្ឍិ១២+២ ហើយកំពុងបម្រើការក្នុង មានចំនួន៣៣នាក់ប៉ុណ្ណោះ ដែលទាំងនេះខ្វះពីការត្រូវការ។

ក្រាហ្វខាងក្រោមនេះបង្ហាញពី តម្រូវការគ្រូតាម និយាមនិងចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២លើ មុខវិជ្ជាចំនួន១៣ រួមមានគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដី ភូមិវិទ្យា ប្រវត្តិវិទ្យា និង

សីលធម៌ពលរដ្ឋ គេហវិទ្យា ព័ត៌មានវិទ្យា សេដ្ឋកិច្ច កសិកម្ម។ តាមរយៈក្រាហ្វនេះបង្ហាញឱ្យឃើញថា មុខវិជ្ជា សេដ្ឋកិច្ច ព័ត៌មានវិទ្យា និង កសិកម្ម ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២ ខ្វះពីតម្រូវការតាមនិយាម។ ដោយឡែកមុខវិជ្ជាគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា គេហវិទ្យា និងសីលធម៌ពលរដ្ឋ មានចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២ ច្រើនជាងតម្រូវការ។ នេះស្តែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងសាលារៀនទី១នេះនៅមានកម្រិត។

ក្រាហ្វខាងក្រោមនេះបានបង្ហាញពី តម្រូវការគ្រូតាម និយាមនិងចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២លើមុខវិជ្ជាចំនួន១៣ រួមមានគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដី ភូមិវិទ្យា ប្រវត្តិវិទ្យា និង សីលធម៌ពលរដ្ឋ គេហវិទ្យា ព័ត៌មានវិទ្យា សេដ្ឋកិច្ច កសិកម្ម។ តាមរយៈក្រាហ្វនេះបង្ហាញឱ្យឃើញថា មុខវិជ្ជាខ្មែរ គណិត បរទេស កីឡា ភូមិវិទ្យា សីលធម៌ ព័ត៌មាន និង កសិកម្ម ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត ១២+២ ខ្វះពីតម្រូវការតាមនិយាម។ ដោយឡែកមុខវិជ្ជារូបវិទ្យា ជីវវិទ្យា ផែនដីវិទ្យា ប្រវត្តវិទ្យា គេហវិទ្យា មានចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២មានគ្រប់ចំនួន និងមុខវិជ្ជាភូមិវិទ្យា សីលធម៌ពលរដ្ឋ ព័ត៌មានវិទ្យា កសិកម្មមានចំនួនលើស។ នេះស្តែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងសាលារៀនទី១នេះនៅមានកម្រិត។




*ក្រាហ្វទី 15៖ គុណវុឌ្ឍិគ្រូបង្រៀន១២+២តាមមុខវិជ្ជាគិតតាមនិយាម និងតាមការជាក់ស្តែង*

## ២. បញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀន

ខ្ទះគ្រូមុខវិជ្ជាឯកទេសគណិតវិទ្យា ៣ នាក់




*ក្រាហ្វទី 16៖ ការលើស និងការខ្វះគ្រូ*

### ៣. ដំណោះស្រាយលើបញ្ហាប្រឈមនៃការប្រើប្រាស់គ្រូបង្រៀន

ប្រើគ្រូគណិតវិទ្យា ភាសាខ្មែរ  ភាសាបរទេស  ប្រើខុសនិយាមម៉ោង លើសពី១៨ ម៉ោងក្នុងមួយសប្តាហ៍ ។

## ករណីសាលារៀនទី៣

### ១. ការកំណត់តម្រូវការគ្រូបង្រៀន

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងទី២បានបង្ហាញពីស្ថិតិសិស្សសរុបក្នុងសំណាក់ដែលបានជ្រើសរើសចេញពីខណ្ឌពោធិ៍សែនជ័យនៃរាជធានីភ្នំពេញ នៃសាលារៀនទី៣ដែលមានចំនួនសិស្ស១១៨១នាក់

ដោយតាមនិយាមសិស្សនៅក្នុងថ្នាក់មានចំនួន៤០នាក់ដែលកំណត់ដោយច្បាប់ក្នុងនោះចំនួនថ្នាក់នៅក្នុងវិទ្យាល័យទាំងមូលមានចំនួនសរុប៣០ថ្នាក់( ១១៨១ចែក៤០នាក់ )។ តាមនិយាមសិស្សក្នុងថ្នាក់ត្រូវមាន ៣២ម៉ោងក្នុងមួយសប្តាហ៍ ដូចនេះម៉ោងសរុបគឺ៩៦០ម៉ោង( ៣០គុណ៣២ )ហើយត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន១២+២ចំនួន៥៤នាក់( ៩៦០ចែក១៨ )សម្រាប់គ្រប់មុខវិជ្ជាឯកទេសទាំងអស់( និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោងក្នុងមួយសប្តាហ៍ )។

*តារាងទី 14៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង*

| | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្សសរុប | ១១៨១ | |
| ថ្នាក់សរុប | ២៤ | ៣០ |
| គ្រូសរុប | ៥១ | ៥៤ |
| ម៉ោង | ៧៦៨ | ៩៦០ |

### *១.១ ការលើសគ្រូ និងខ្វះគ្រូតាមមុខវិជ្ជាឯកទេស*

ប៉ុន្តែបើពិនិត្យឱ្យកាន់តែស៊ីជម្រៅ ទោះបីជាមានការលើសគ្រូ ដែលមានកម្រិតគុណវុឌ្ឍិ១២+២យ៉ាងច្រើនដូចនេះក៏ដោយក៏មិនបញ្ជាក់ថា លើសគ្រូគ្រប់មុខវិជ្ជានោះដែរ ព្រោះចំនួនគ្រូដែលគិតតាមនិយាម និងចំនួនគ្រូដែលកំពុងមានជាក់ស្តែង គឺមានមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ និងមុខវិជ្ជាខ្លះលើសទៅវិញ។ តួយ៉ាងដូចមានបង្ហាញក្នុងក្រាហ្វ ដែលត្រូវការសម្រាប់វិទ្យាល័យទៅនៃខណ្ឌពោធិ៍សែនជ័យរាជធានីគិតតាមនិយាមត្រូវមាន ៥៤នាក់ ប៉ុន្តែចំនួនគ្រូដែលមានគុណវុឌ្ឍិ១២+២ ហើយកំពុងបម្រើការក្នុង មានចំនួន៥១នាក់ប៉ុណ្ណោះវាលើសពីរការត្រូវការ។

ក្រាហ្វខាងក្រោមនេះបានបង្ហាញពី តម្រូវការគ្រូតាម និយាមនិងចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២លើមុខវិជ្ជាចំនួន១៣ រួមមានគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដី ភូមិវិទ្យា ប្រវត្តិវិទ្យា និង សីលធម៌ពលរដ្ឋ គេហវិទ្យា ព័ត៌មានវិទ្យា សេដ្ឋកិច្ច កសិកម្ម។ តាមរយៈក្រាបនេះបង្ហាញឱ្យឃើញថា មុខវិជ្ជាភាសាបរទេស កីឡា គេហវិទ្យា សេដ្ឋកិច្ច និង ព័ត៌មានវិទ្យា ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២ខ្វះពីតម្រូវការតាមនិយាម។ ដោយឡែកមុខវិជ្ជាគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា ជីវវិទ្យា កសិកម្ម និងសីលធម៌ពលរដ្ឋមានចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២មានចំនួនគ្រប់តម្រូវការ រីឯចំពោះមុខវិជ្ជាផែនដី ប្រវត្ត ភូមិវិទ្យា មានចំនួនលើសពីតម្រូវការ។ នេះស្តែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងសាលារៀនទី១នេះនៅមានកម្រិត។



*ក្រាហ្វទី 17៖ គុណវុឌ្ឍិគ្រូបង្រៀន១២+២តាមមុខវិជ្ជាគិតតាមនិយាមនិងតាមការជាក់ស្តែង*

## ២. បញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀន

ការខ្វះគ្រូមុខវិជ្ជាឯកទេស និងមុខវិជ្ជាភាសាបរទេសច្រើន




*ក្រាហ្វទី 18៖ ការលើស និងការខ្វះគ្រូ*

## ៣ .ដំណោះស្រាយបញ្ហាប្រឈម

គ្រូមុខវិជ្ជាបរទេស បង្រៀនលើសនិយាម ឯគ្រូបង្រៀនតិចជាងនិយាម ក្នុងឯកទេសមុខវិជ្ជាអាចជំនួសបាន។ លើកគោលការណ៍ស្ម័គ្រចិត្ត ដោយផ្តល់ប្រាក់លើកទឹកចិត្តសម្រាប់អ្នកព្រមទៅបង្រៀនសាលារៀនខ្វះគ្រូ ឬ ឡើងកាំប្រាក់ សម្រាប់គ្រូបង្រៀនអសកម្មត្រូវពង្រាយតាមការចាត់តាំង។

## ៣ .ករណីសិក្សានៅខណ្ឌព្រែកព្នៅ

### *៣.១ កំណត់តម្រូវការគ្រូបង្រៀន*

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងទី២បានបង្ហាញពីស្ថិតិសិស្សសរុបក្នុងសំណាក់ដែលបានជ្រើសរើសចេញពីខណ្ឌព្រែកព្នៅ នៃរាជធានីភ្នំពេញដែលមានចំនួនសិស្ស១៦៣៦នាក់ ដោយតាមនិយាមសិស្សនៅក្នុងថ្នាក់មានចំនួន៤០នាក់ ដែលកំណត់ដោយច្បាប់ក្នុងនោះចំនួនថ្នាក់នៅទាំងមូលមានចំនួនសរុបថ្នាក់៤០ថ្នាក់១៦៣៦នាក់ចែក៤០នាក់)។ តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវមាន៣២ម៉ោងក្នុងមួយសប្ដាហ៍ ដូចនេះម៉ោងសរុប គឺ១២៨០ម៉ោង(១២៨គុណ៣២) ហើយត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន១២+២ចំនួន៧៤នាក់(១២៨០ចែក១៨)សម្រាប់គ្រប់មុខវិជ្ជាឯកទេសទាំងអស់ (និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោងក្នុងមួយសប្ដាហ៍)។

*តារាងទី 16៖ ម៉ោងជាក់ស្ដែង និងតាមនិយាម*

| | តាមជាក់ស្ដែង | តាមនិយាម |
|---|---|---|
| សិស្សសរុប | ១៦៣៦នាក់ | |
| ថ្នាក់សរុប | ៣៤ | ៤០ |
| គ្រូសរុប | ៩៧ | ៧៤ |
| ម៉ោង | ១០៨៨ | ១២៨០ |

### *៣.២ ការលើសគ្រូបង្រៀន និងខ្វះគ្រូបង្រៀនតាមមុខវិជ្ជាឯកទេស*

តាមរយៈក្រាហ្វខាងក្រោមនេះបង្ហាញឱ្យឃើញថាគ្រូមានជាក់ស្ដែង៩៧នាក់ មានគ្រូលើសពីតម្រូវការ២៣នាក់ហើយដែលមានមុខវិជ្ជាឯកទេស ភាសាខ្មែរ គណិតវិទ្យា ភាសាបរទេស និង ព័ត៌មានវិទ្យា មានចំនួនច្រើន។




*ក្រាហ្វទី 19៖ ម៉ោងដាក់ស្តែង និង តាមនិយាម*

### ៣.២ បញ្ហាប្រឈមក្នុងការដោះស្រាយគ្រូលើស

តាមរយៈក្រាហ្វខាងក្រោមនេះមានលើសគ្រូច្រើន គ្រាន់តែគ្រូមិនបានធ្វើការគ្រប់និយាមដែលច្បាប់បានកំណត់មក។ ខ្វះគ្រូមុខវិជ្ជាឯកទេសសេដ្ឋកិច្ច ២ នាក់ ។




*ក្រាហ្វទី 20៖ ការលើស និងខ្វះគ្រូ*

### ៣.៤ ដំណោះស្រាយក្នុងការដោះស្រាយគ្រូលើស

បន្ថយចំនួនម៉ោងនិយាមគ្រូ ដោយបង្រៀនមិនដល់១៨ ម៉ោងក្នុងមួយសប្តាហ៍ ។

**ករណីសាលារៀនទី១**

**១. កំណត់តម្រូវការគ្រូបង្រៀន**

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងបានបង្ហាញពីស្ថិតិសិស្សសរុបក្នុងសំណាក់ដែលបានជ្រើសរើសចេញពីសាលារៀនទី១ខណ្ឌព្រែកព្នៅដែលមានចំនួនសិស្ស៨៣០នាក់ដោយតាមនិយាមសិស្សនៅក្នុងថ្នាក់មានចំនួន៤០នាក់ដែលកំណត់ដោយច្បាប់ក្នុងនោះចំនួនថ្នាក់នៅក្នុងវិទ្យាល័យទាំងមូលមានចំនួនសរុប២០ថ្នាក់(៨៣០ចែក៤០នាក់)។ តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវមាន៣២ម៉ោងក្នុងមួយសប្តាហ៍ ដូចនេះម៉ោងសរុបគឺ៦៤០ម៉ោងហើយ (២០គុណ៣២)ត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន ១២+២ ចំនួន៣៦នាក់(៦៤០ចែក១៨)សម្រាប់គ្រប់មុខវិជ្ជាឯកទេសទាំងអស់(និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោងក្នុងមួយសប្តាហ៍)។

*តារាងទី 17៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង*

| | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្សសរុប | ៨៣០នាក់ | |
| ថ្នាក់សរុប | ១៧ | ២០ |
| គ្រូសរុប | ៥៥ | ៣៦ |

***១.១ ការលើស និងខ្វះគ្រូបង្រៀន***

ប៉ុន្តែបើពិនិត្យឱ្យកាន់តែស៊ីជម្រៅ ទោះបីជាមានការលើសគ្រូ ដែលមានកម្រិតគុណវុឌ្ឍិ១២+២យ៉ាងច្រើនដូចនេះក៏ដោយក៏មិនបញ្ជាក់ថា លើសគ្រូគ្រប់មុខវិជ្ជានោះដែរ ព្រោះចំនួនគ្រូដែលគិតតាមនិយាម និងចំនួនគ្រូដែលកំពុងមានជាក់ស្តែង គឺមានមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ និងមុខវិជ្ជាខ្លះលើសទៅវិញ។ តួយ៉ាងដូចមាន

បង្ហាញក្នុងក្រាហ្វទី១ ដែលត្រូវការសម្រាប់វិទ្យាល័យទៅគិតតាមនិយាមត្រូវមាន៣៦នាក់ ប៉ុន្តែចំនួនគ្រូដែលមានគុណវុឌ្ឍិ១២+២ ហើយកំពុងបម្រើការក្នុង មានចំនួន៥៥នាក់ប៉ុណ្ណោះវាលើសពីការត្រូវការ។

ក្រាហ្វខាងក្រោមបង្ហាញពី តម្រូវការគ្រូតាម និយាមនិងចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២លើ មុខវិជ្ជាចំនួន១៣ រួមមានគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដី ភូមិវិទ្យា ប្រវត្តិវិទ្យា និងសីលធម៌ពលរដ្ឋ គេហវិទ្យា ព័ត៌មានវិទ្យា សេដ្ឋកិច្ច កសិកម្ម។ តាមរយៈក្រាហ្វនេះបង្ហាញឱ្យឃើញថា មុខវិជ្ជាភាសាបរទេស កីឡា គេហវិទ្យា សេដ្ឋកិច្ច និង ព័ត៌មានវិទ្យា ចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២ មានចំនួនលើសពីតម្រូវការច្រើន។ នេះស្តែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងសាលារៀនទី១នេះនៅមានកម្រិត។




*ក្រាហ្វទី 21៖ គុណវុឌ្ឍិគ្រូបង្រៀន១២+២តាមមុខវិជ្ជាគិតតាមនិយាម និងតាមការជាក់ស្តែង*

តាមរយៈក្រាហ្វខាងលើនេះ បង្ហាញឱ្យឃើញថា គ្រូមានលើសនិយាមប្រើ ។

### ២. បញ្ហាប្រឈមនៃការប្រើប្រាស់គ្រូបង្រៀន




*ក្រាហ្វទី 22៖ ការលើស និងការខ្វះគ្រូ*

### ៣. ដំណោះស្រាយបញ្ហាប្រឈម

គ្រូបង្រៀន មិនបានបង្រៀនគ្រប់ម៉ោងនិយាមនៃច្បាប់បានចែង ដើម្បីឱ្យគ្រូបានបង្រៀនទាំងអស់គ្នា។

## ករណីសាលារៀនទី២

### ១. ការកំណត់តម្រូវការគ្រូបង្រៀន

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងទី២បានបង្ហាញពីស្ថិតិសិស្សសរុបក្នុងសំណាក់ដែលបានជ្រើសរើសចេញពីខណ្ឌពោធិ៍សែនជ័យ នៃរាជធានីភ្នំពេញនៃសាលារៀនទី៣ដែលមានចំនួនសិស្ស៣៧០នាក់ដោយតាមនិយាមសិស្សនៅក្នុងថ្នាក់មានចំនួន៤០នាក់ ដែលកំណត់ដោយច្បាប់ក្នុងនោះចំនួនថ្នាក់នៅក្នុងវិទ្យាល័យទាំងមូលមានចំនួនសរុប០៩ថ្នាក់( ៣៧០ចែក៤០នាក់ )។ តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវមាន៣២ម៉ោងក្នុងមួយសប្តាហ៍ដូចនេះម៉ោងសរុបគឺ២៨៨ម៉ោង( ៩គុណ៣២ ) ហើយត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន ១២+២ ចំនួន១៦នាក់( ២៨៨ចែក១៨ ) សម្រាប់មុខវិជ្ជាឯកទេសទាំងអស់ ( និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោងក្នុងមួយសប្តាហ៍ )។

*តារាងទី 18៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង*

| | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្សសរុប | ៣៧០នាក់ | |
| ថ្នាក់សរុប | ៧ | ៩ |
| គ្រូសរុប | ១៧ | ១៦ |
| ម៉ោង | ២២៤ | ២៨៨ |

## *១.១ ការលើស និងការខ្វះគ្រូបង្រៀន*




*ក្រាហ្វទី 23៖ គុណវុឌ្ឍិគ្រូបង្រៀន១២+២តាមមុខវិជ្ជាគិតតាមនិយាម និងតាមការជាក់ស្តែង*

ប៉ុន្តែបើពិនិត្យឱ្យកាន់តែស៊ីជម្រៅ ទោះបីជាមានការលើសគ្រូ ដែលមានកម្រិតគុណវុឌ្ឍិ១២+២យ៉ាងច្រើនដូចនេះក៏ដោយក៏មិនបញ្ជាក់ថាមិនសូវ លើសគ្រូគ្រប់មុខវិជ្ជានោះដែរ ព្រោះចំនួនគ្រូដែលគិតតាមនិយាម និងចំនួនគ្រូដែលកំពុងមានជាក់ស្តែង គឺមានមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ និងមុខវិជ្ជាខ្លះលើសទៅវិញ។ តួយ៉ាងដូចមានបង្ហាញក្នុងក្រាហ្វ ដែលត្រូវការសម្រាប់សាលារៀនទី២បើគិតតាមនិយាមត្រូវមាន១៦នាក់ ។ ប៉ុន្តែ

ចំនួនគ្រូដែលមានគុណវុឌ្ឍិ១២+២ ហើយកំពុងបម្រើការក្នុង មានចំនួន១៧នាក់ប៉ុណ្ណោះវាលើសពីការត្រូវការ។

ក្រាហ្វខាងក្រោមនេះបានបង្ហាញពី តម្រូវការគ្រូតាម និយាមនិងចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២លើមុខវិជ្ជាចំនួន១៣ រួមមានគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដី ភូមិវិទ្យា ប្រវត្តិវិទ្យា និងសីលធម៌ពលរដ្ឋ គេហវិទ្យា ព័ត៌មានវិទ្យា សេដ្ឋកិច្ច កសិកម្ម។ តាមរយៈក្រាបនេះបង្ហាញឱ្យឃើញថា មុខវិជ្ជាទាំង១៣មុខវិជ្ជាប្រើគ្រប់គ្រាន់តាមនិយាមម៉ោងប្រើ ទោះមានខ្វះខ្លះបន្តិចក៏ដោយ។ នេះស្តែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងសាលារៀនទី១នេះនៅមានកម្រិត។

### ២. បញ្ហាប្រឈមក្នុងការខ្វះគ្រូតិចតួច




*ក្រាហ្វទី 24៖ ការលើស និងការខ្វះគ្រូ*

### ៣. ដំណោះស្រាយបញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀន

ទាំងអស់នេះមិនមែនជាបញ្ហាចោទទេ អាចប្រើប្រាស់បានគ្រាន់តែខ្វះមុខវិជ្ជាឯកទេសបន្តិចបន្តួច។

## ករណីសាលារៀនទី៣

### ១. កំណត់តម្រូវការគ្រូបង្រៀន

លទ្ធផលនៃការស្រាវជ្រាវដូចមានក្នុងតារាងទី២បានបង្ហាញពីស្ថិតិសិស្សសរុបក្នុងសំណាក់ដែលបានជ្រើសរើសចេញពីសាលារៀនទី៣ដែលមានចំនួនសិស្ស៤៣៦នាក់ ដោយតាមនិយាមសិស្សនៅក្នុងថ្នាក់មានចំនួន៤០នាក់ដែលកំណត់ដោយច្បាប់ក្នុងនោះចំនួនថ្នាក់នៅក្នុងវិទ្យាល័យទាំងមូលមានចំនួនសរុប១១ថ្នាក់ (៤៣៦ចែក៤០នាក់)។ តាមនិយាមសិស្សក្នុងមួយថ្នាក់ត្រូវមាន៣២ម៉ោងក្នុងមួយសប្តាហ៍ ដូចនេះម៉ោងសរុបគឺ៣៥២ម៉ោង(១១គុណ៣២)ហើយត្រូវប្រើប្រាស់គ្រូបង្រៀនកម្រិតមូលដ្ឋាន១២+២ចំនួន២២នាក់ (៣៥២ចែក១៨) សម្រាប់គ្រប់មុខវិជ្ជាកទេសទាំងអស់ (និយាមគ្រូបង្រៀននៅអនុវិទ្យាល័យ១៨ម៉ោងក្នុងមួយសប្តាហ៍)។

*តារាងទី 19៖ ស្ថិតិសិស្ស ថ្នាក់ ម៉ោងនិងគ្រូសរុបតាមនិយាម និងតាមជាក់ស្តែង*

| | តាមជាក់ស្តែង | តាមនិយាម |
|---|---|---|
| សិស្សសរុប | ៤៣៦នាក់ | |
| ថ្នាក់សរុប | ១០ | ១១ |
| គ្រូសរុប | ២៥ | ២២ |
| ម៉ោង | ៣២០ | ៣៥២ |

### *១.១ ការលើស និងខ្វះគ្រូបង្រៀន*

ប៉ុន្តែបើពិនិត្យឱ្យកាន់តែស៊ីជម្រៅ ទោះបីការលើសគ្រូ ដែលមានកម្រិតគុណវុឌ្ឍិ១២+២យ៉ាងច្រើនដូចនេះក៏ដោយក៏មិនបញ្ជាក់ថា មានខ្វះគ្រូមុខវិជ្ជាខ្លះ ព្រោះចំនួនគ្រូដែលគិតតាមនិយាម២២នាក់ និងចំនួនគ្រូដែលកំពុងមានជាក់ស្តែង២៥នាក់ មានការលើសបន្តិច គឺមានមុខវិជ្ជាខ្លះខ្វះ មុខវិជ្ជាខ្លះគ្រប់ និងមុខវិជ្ជាខ្លះលើស

ទៅវិញ។ តួយ៉ាងដូចមានបង្ហាញក្នុងក្រាហ្វដែលត្រូវការសម្រាប់វិទ្យាល័យនៃខណ្ឌពោធិ៍សែនជ័យរាជធានីភ្នំពេញ គិតាមនិយាមត្រូវមាន៥៤នាក់ ប៉ុន្តែចំនួនគ្រូដែលមានគុណវុឌ្ឍិ១២+២ហើយកំពុងបម្រើការក្នុងមានចំនួន៥១នាក់ប៉ុណ្ណោះវាលើសពីការត្រូវការ។

ក្រាហ្វខាងក្រោមបង្ហាញពី តម្រូវការគ្រូតាម និយាមនិងចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២លើ មុខវិជ្ជាចំនួន១៣ រួមមានគណិតវិទ្យា អក្សរសាស្ត្រខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដី ភូមិវិទ្យា ប្រវត្តិវិទ្យា និងសីលធម៌ពលរដ្ឋ គេហវិទ្យា ព័ត៌មានវិទ្យា សេដ្ឋកិច្ច កសិកម្ម។ តាមរយៈក្រាហ្វនេះបង្ហាញឱ្យឃើញថា មុខវិជ្ជាចំនួនគ្រូដែលមានគុណវុឌ្ឍិកម្រិត១២+២មានលើសពីតម្រូវការតាមនិយាម។ ដោយឡែកមុខវិជ្ជាមួយចំនួនមានការខ្វះគ្រូ។ នេះស្តែងឱ្យឃើញថាប្រសិទ្ធភាពនៃការបែងចែក និងប្រើប្រាស់គ្រូនៅក្នុងសាលារៀនទី១នេះនៅមានកម្រិត។




*ក្រាហ្វទី 25៖ គុណវុឌ្ឍិគ្រូបង្រៀន១២+២តាមមុខវិជ្ជាគិតតាមនិយាម និងតាមការជាក់ស្តែង*

**២.បញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូបង្រៀន**




*ក្រាហ្វទី 26៖ ការលើសនិងការខ្វះគ្រូ*

គ្រូដែលលើសពីតម្រូវការ មានគ្រូភាសាខ្មែរ គណិតវិទ្យា ភាសាបរទេស រូបវិទ្យា គីមីវិទ្យា និង ខ្វះគ្រូដែលខ្វះមានព័ត៌មានវិទ្យា។

**៣ .ដំណោះស្រាយបញ្ហាប្រឈម**

ចំពោះចំណុចនេះមិនមានជាបញ្ហាចោទទេ មានគ្រូលើស យកទៅជំនួសគ្រូខ្វះ ។

***៤.២.៥ អនុសាសន៍របស់គណៈគ្រប់គ្រងសាលារៀន និង លោកគ្រូ អ្នកគ្រូ***

**ករណីខ្វះគ្រូ**

តាមការសម្ភាសជាមួយនាយកសាលារៀននៃអនុវិទ្យាល័យក្នុងករណីខ្វះគ្រូនៅសាលារៀនដែលមានប្រសិទ្ធដើម្បីដោះស្រាយបញ្ហាការខ្វះគ្រូនៅសាលារៀន សូមកែប្រែប្រព័ន្ធអប់រំដោយរើសគ្រូចេញពីមូលដ្ឋាន ឬសហគមន៍ មិនតែប៉ុណ្ណោះនោះគាត់បានប្រាប់ថាគាត់ចង់បានគ្រូដែលមានគុណវុឌ្ឍិខ្ពស់ចេញពីការបណ្តុះបណ្តាល ដែលមានកម្រិតយ៉ាងតិចណាស់បរិញ្ញបត្រ បូក១ ផ្តល់ឱ្យនៅតាមសំណើរនៃឯកទេសដែលគាត់ចង់បាន ។ នាយករង និងលោកគ្រូ-អ្នកគ្រូគឺចង់បានការផ្តល់ប្រាក់ម៉ោងដល់គ្រូបន្ថែម និងបង្កើនគុណវុឌ្ឍិគ្រូបង្រៀន។

ករណីលើសគ្រូ

សម្រាប់នាយក នាយករង និងលោកគ្រូ-អ្នកគ្រូ សូមឱ្យមានការលើកទឹកចិត្តសម្រាប់លោកគ្រូ-អ្នកគ្រូ ដែលបានស្ម័គ្រចិត្តទៅសាលាខ្វះគ្រូ មានការលើទឹកចិត្តជាប្រាក់ខែ ឬឡើងកាំប្រាក់ម្តងមួយឆ្នាំឬ បង្កើនចំណេះដឹងវិជ្ជាជីវៈបន្ថែមទៀត ផ្អាកការផ្ទេររបស់លោកគ្រូ-អ្នកគ្រូ នឹងចាត់វិធានការសម្រាប់គ្រូអសកម្មដោយពង្រាយគាត់បើរកឃើញពីភាពយកលុយសិស្ស ឬមិនគោរពរដ្ឋបាលថ្នាក់រៀន។

# ជំពូក៥ ៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១. សេចក្តីសន្និដ្ឋាន

ស្នាដៃស្រាវជ្រាវនេះបានបង្ហាញនូវលទ្ធផលបីគឺ (១)ស្ថានភាពប្រើប្រាស់គ្រូមិនស្របទៅតាមការកំណត់នៃច្បាប់បានចែង (២)ដំណោះស្រាយក្នុងការប្រើប្រាស់គ្រូមិនទាន់មានប្រសិទ្ធភាព និង(៣)បញ្ហាប្រឈមក្នុងការកំណត់ការប្រើប្រាស់គ្រូនៅតែជាបញ្ហាចោទនៅឡើយនៅភ្នំពេញ ។

តាមរយៈការធ្វើការស្រាវជ្រាវបានបង្ហាញឱ្យឃើញថាស្ថានភាពគ្រូបង្រៀននាពេលបច្ចុប្បន្នជួបការលំបាកច្រើនណាស់ដល់ការប្រើប្រាស់ឱ្យត្រឹមត្រូវតាមការកំណត់នៃច្បាប់នៃអនុវិទ្យាល័យនាពេលនេះ។ ដោយសារតែការលំបាកក្នុងការមានគ្រូច្រើនលើសពីតម្រូវការតែតាមសាលារៀននីមួយៗ ចំណែកឯចំនួនគ្រូតាមឯកទេសវិញសាលាខ្លះមានការលើស និងសាលាខ្លះមានការខ្វះ ដែលជាហេតុធ្វើឱ្យការប្រើប្រាស់នៅមិនទាន់បានចំទិសដៅនៅឡើយ។ ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយ ការអនុវត្តការងារបង្រៀននៅតែធ្វើបានជានិច្ច គ្រាន់តែប្រើប្រាស់ធនធានមានស្រាប់មិនទាន់បានប្រើឱ្យអស់លទ្ធភាពនៅឡើយ គឺគ្រូធ្វើការបានតិចហើយមិនបានត្រូវតាមឯកទេស ហើយគ្រូចំឯកទេសនៅធ្វើមិនបានគ្រប់ម៉ោង ដោយទុកឱ្យគ្រូឯកទេសដទៃទៀតមានការងារធ្វើ សរុបមកលើសគ្រូតាមសាលារៀនតែបែជា មានការលើស និងខ្វះគ្រូតាមឯកទេសទៅវិញ។

ចំណែកឯការដោះស្រាយក្នុងកាខ្វះគ្រូ លើសគ្រូឯកទេសការរប្រើប្រាស់ក្នុងការយកគ្រូឯកទេសដោយការប្រើថាគ្រូត្រូវបានធ្វើការធ្វើចំណាត់ថ្នាក់គ្រូជាពីរក្រុម គឺគ្រូក្រុមវិទ្យាសាស្ត្រពិត និងក្រុមគ្រូវិទ្យាសាស្ត្រសង្គម ហើយយកគ្រូឯកទេសក្នុងក្រុមតែមួយមកជំនួសគ្នា ហើយមុនធ្វើការជំនួសគ្នានាយកបានសួរលោកគ្រូ-អ្នកគ្រូ តើគាត់មានសមត្ថភាពអាចបង្រៀនខុសឯកទេសបានឬទេ បើគាត់ព្រមទើបបានឱ្យមានការបង្រៀន ហើយលោកនាយកបានប្រើគោលការណ៍មិនបានបង្ខំដោយការគោរពឆន្ទះលោកគ្រូ- អ្នកគ្រូ ។

អ្វីដែលជាការបញ្ហាប្រឈមមិនចេះចប់មិនចេះហើយនោះ គឺនាយកសាលារៀនមិនមានសិទ្ធិក្នុងការបដិសេធការទទួលយកគ្រូថ្មីដែលសាលារៀនរបស់ខ្លួនមិនត្រូវការកំពុងតែមានចំនួនច្រើនហើយថែមមកឱ្យទៀត ទាំងនេះជាហេតុធ្វើឱ្យគ្រូក្នុងសាលារៀនមានអ្នកធ្វើការតិច និងអ្នកធ្វើការច្រើនរបាយម៉ោងធ្វើការមិនស្មើគ្នាក្នុងគ្រូអនុវិទ្យាល័យតែមួយ។

លទ្ធផលដែលបានបង្ហាញខាងលើនេះ ជាទឡ្ហីករណ៍អាចជួយអ្នកសិក្សាស្រាវជ្រាវទាញសេចក្ដីសន្និដ្ឋានបានថា ស្ថានភាព និងបញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូនៅតែជាបញ្ហាចោទនៅឡើយសម្រាប់ក្រសួងនៅមានកម្រិតនៅឡើយ ព្រោះជាការចំណាយថវិកាច្រើនសម្រាប់គ្រូលើសទៅបំពេញការងារមិនគ្រប់ម៉ោងបង្រៀន ហើយនៅតែមានការខ្វះគ្រូនៅតាមសាលារៀនផ្សេងទៀត។

## ៥.២ .សំណូមពរ

បើទោះជាលទ្ធផលដែលបានរកឃើញបង្ហាញថាស្ថានភាព និងបញ្ហាប្រឈមការប្រើប្រាស់បុគ្គលិកនៅអនុវិទ្យាល័យនៅភ្នំពេញពុំទាន់ឆ្លើយតបតាមមាត្រដ្ឋានច្បាប់បានចែងនៅមានកម្រិតនៅឡើយ។ អ្នកស្រាវជ្រាវសូមលើកឡើងនូវសំណូមពរមួយចំនួនទៅភាគីពាក់ព័ន្ធនានាមានដូចជា ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡាក្រុងភ្នំពេញ គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស ត្រូវរួមគ្នាដោះស្រាយបញ្ហាជាប្រព័ន្ធក្នុងការពង្រឹងប្រព័ន្ធអប់រំកម្ពុជាឱ្យមានគុណភាពក្នុងការប្រើប្រាស់គ្រូបង្រៀននាអនុវិទ្យាល័យនៅក្រុងភ្នំពេញ

### ក. ក្រសួងអប់រំ យុវជន និងកីឡា

ចាត់វិធានឱ្យច្បាស់លាស់ក្នុងការពង្រាយគ្រូបង្រៀន ដែលពេលនេះគ្រូមានការលើសចំនួនច្រើនហួសពីតម្រូវការច្រើន។ គួរយកគ្រូដែលបង្រៀនខុសឯកទេសមកអោយបណ្ដុះណ្ដាលអោយត្រូវឯកទេស ដោយបន្ថែមចំណេះពីមុខវិជ្ជាឱ្យតែកាន់ស៊ីជម្រៅមុខវិជ្ជាកំពុងជំនួស ដោយរៀបឱ្យត្រូវម៉ោង១៨ម៉ោងក្នុងមួយសប្ដាហ៍ និងឱ្យត្រូវម៉ោងសិក្សានៃរបាយមុខវិជ្ជានៃឯកទេសនីមួយៗ ប្រើគោលការណ៍ពិនិត្យមើលបណ្ណព័ត៌មានគ្រូ ដើម្បី

សំណូមពរឱ្យគាត់ស្ម័គ្រចិត្តទៅបម្រើការងារនៅសាលារៀនខ្វះគ្រូ សម្រាប់អ្នកគ្រូផ្ទះគាត់ឆ្ងាយពីសាលារៀនកំពុងបង្រៀនស្រាប់។ បង្កើតសកម្មភាពនៅសាលារៀនឱ្យលោកគ្រូ-អ្នកគ្រូអនុវត្តឱ្យបាន១៨ម៉ោងក្នុងមួយសប្តាហ៍ ករណីគ្រូមិនបានទាន់បំពេញការងារគ្រប់ម៉ោង បង្កើតកម្មវិធីការបង្រៀនពង្រឹងសមត្ថភាពសិស្សដោយលើកកម្ពស់គុណភាពអប់រំ សម្រាប់គ្រូណាមិនចង់ចេញពីសាលាកំពុងដោយមូលហេតុផលប្រយោជន៍ផ្ទាល់ខ្លួន បង្កើតគណៈកម្មការវាយតម្លៃការងារគ្រូក្នុងបង្ខំពង្រាយសម្រាប់គ្រូអសកម្ម។

### ខ. មន្ទីរអប់រំ យុវជន និងកីឡា

សូមឱ្យមន្ទីរពិនិត្យមើលសៀវភៅផែនការសាលារៀនក្នុងការខ្វះ លើសគ្រូបង្រៀនតាមសាលារៀននីមួយៗព្យាយាមឱ្យអស់ពីលទ្ធភាពក្នុងការសហការជាមួយនាយកសាលារៀនក្នុងការកំណត់ពីតម្រូវការគ្រូបង្រៀននៅសាលារៀនមូលដ្ឋាន ចូលរួមក្នុងការផ្លាស់ប្តូរយោបល់ជាមួយនាយកសាលារៀនក្នុងខណ្ឌ តើអាចផ្តល់គ្រូជួយតាមឯកទេសខ្វះ ជៀសវាងការយកគ្រូមិនត្រូវឯកទេសមកបង្រៀនដែលធ្វើឱ្យគុណភាពអប់រំធ្លាក់ចុះ

### គ. សាលារៀន (គណៈគ្រប់គ្រងសាលារៀន)

សូមផ្តល់សិទ្ធិឱ្យគណៈនាយកក្នុងការចូលរួមក្នុងរកធ្វើការសហការណ៍ជាមួយមន្ទីរ សាលាគុកោសល្យដូចជាការធ្វើនំ ដើម្បីឱ្យអ្នកធ្វើនំ អ្នកផ្តល់នំ និងអ្នកទទួលនំ មានការតតាំងគ្នា សម្រាប់ការធ្វើដំណើរការទៅយ៉ាងណាឱ្យចំទិសដៅធ្វើការផ្គត់ផ្គង់ឆ្លើយតបទាន់ពេលវេលា និងការផ្តល់មិនត្រូវការមានការមិនទទួលយកនូវអ្វីមិនសមហេតុផល គ្មានការឆ្លើយមិនមានការទទួលខុសត្រូវ ។

### ឃ. ប្រធានក្រុមបច្ចេកទេស

សូមជួយពិនិត្យមើលលើការប្រើប្រាស់គ្រូមានប្រសិទ្ធភាពឬទេ ? គ្រូមានការអនុវត្តការងារត្រឹមត្រូវឬទេ ? គុណភាពគ្រូដល់កម្រិតណា ? ការបំពេញការងារក្នុងការបង្រៀនគ្រប់ម៉ោងឬទេ ?ដើម្បីបង្កើនគុណវុឌ្ឍិគ្រូឱ្យមានគុណភាព។

## ៥.៣. សម្រាប់ការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ផ្តោតតែការប្រើប្រាស់គ្រូបង្រៀននាពេលនេះ បានត្រឹមត្រូវទៅតាមនិយាមម៉ោងនិងរបាយម៉ោងមុខវិជ្ជាឯកទេសផលធៀបសិស្សថ្នាក់  ផលធៀបថ្នាក់គ្រូ បានធ្វើឱ្យដឹងពីគ្រូអនុវត្តការងារ គ្រប់ម៉ោង គោរពតាមឯកទេស និងចំនួនម៉ោងឯកទេសគ្រប់ទៅតាមច្បាប់ និងបញ្ហាប្រឈមក្នុងការប្រើប្រាស់គ្រូនៅអនុវិទ្យាល័យពីថ្នាក់ទី ៧ ដល់ថ្នាក់ទី ៩ តែប៉ុណ្ណោះ។ ហើយសម្រាប់អ្នកស្រាវជ្រាវបន្តទៀតអាចពីចារណាលើចំណុចមួយចំនួនដូចខាងក្រោមនេះ

- អាចធ្វើការសិក្សាស្រាវជ្រាវពីទស្សនះយល់ឃើញរបស់គណៈគ្រប់គ្រង និង គ្រូបង្រៀនលើការពង្រាយគ្រូបង្រៀនកម្រិតមូលដ្ឋាននៅមធ្យមសិក្សាបឋមភូមិឱ្យមានប្រសិទ្ធភាព។

# ឯកសារយោង

ក្រសួងអប់រំ យុវជន និងកីឡា .(២០១៩) *ផ្នែកការគ្រប់គ្រប់គ្រងទូទៅ ការគ្រប់គ្រងតាមសាលារៀន*.ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា.

ក្រសួងអប់រំ យុវជន និងកីឡា .(២០១៩) *សេចក្តីណែនាំ ស្តីពីការគ្រប់គ្រងគ្រូបង្រៀន* .ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា.

ក្រសួងអប់រំ យុវជន និងកីឡា(កុម្ភៈ២០១៩) *ផែនទីបង្ហាញផ្លូវការអប់រំឆ្នាំ២០៣០ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤*.ភ្នំពេញ ក្រសួងអប់រំ យុវជននិងកីឡា

ក្រសួងអប់រំ យុវជន និងកីឡា (មិថុនា២០១៩) *ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣.* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា.

ក្រសួងអប់រំ យុវជន និងកីឡា (ឧសភា២០១៣) *គោលនយោបាយស្តីពីគ្រូបង្រៀន.* ភ្នំពេញ ក្រសួងអប់រំ យុវជន និងកីឡា.

ក្រុមប្រឹក្សាស្រាវជ្រាវអប់រំ(មករា-មិថុនា២០១៩). *កាលិបត្រស្រាវជ្រាវអប់រំកម្ពុជា.* ភ្នំពេញប្រឹក្សាស្រាវជ្រាវអប់រំ

ច្បាប់អប់រំ.(ធ្នូ២០០៧)

យូណេស្កូអាយអាយអ៊ីភី .(២០១៧) *សេចក្តីផ្តើម ស្តីពីការគ្រប់គ្រង និងបែងចែកធនធានអប់រំ*

សម្តេចព្រះសង្ឃរាជ ជួន ណាត ណាត .(១៩៦៨) *.វចនានុក្រមខ្មែរ ភាគទី១ ភាគទី២.*

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ (ក)៖ កម្រងសំណួរ

**កម្រងសំណួរ កម្រិត អនុវិទ្យាល័យ**
**ប្រធានបទ៖ ស្ថានភាព ក្នុងការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យក្នុងរាជធានីភ្នំពេញ**
**កម្រងសំណួរសម្រាប់សម្ភាសន៍នាយកសាលា**

## <u>កម្រងសំណួរ កម្រិត អនុវិទ្យាល័យ</u>

ប្រធានបទ៖ ស្ថានភាព ក្នុងការប្រើប្រាស់គ្រូបង្រៀននៅអនុវិទ្យាល័យក្នុងរាជធានីភ្នំពេញកម្រងសំណួរសម្រាប់សម្ភាសន៍នាយកសាលា

វត្ថុបំណងនៃការស្រាវជ្រាវ៖

1. រកឱ្យឃើញពីស្ថានភាពការប្រើប្រាស់គ្រូបង្រៀននៅតាមអនុវិទ្យាល័យ ក្នុងប្រទេសកម្ពុជា។
2. រកឱ្យឃើញដំណោះស្រាយបញ្ហាប្រឈមការប្រើប្រាស់គ្រូបង្រៀននៅភ្នំពេញឱ្យមានប្រសិទ្ធភាព។

*ការរក្សាការសម្ងាត់*

*ព័ត៌មានដែលទទួលបានពីលោក លោកស្រីសម្រាប់ការវិភាគពីការគ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀននៅកម្ពុជា នឹងត្រូវរក្សាការសម្ងាត់។ អត្តសញ្ញាណរបស់លោក លោកស្រីមិនត្រូវបានបង្ហាញក្នុងការស្រាវជ្រាវនេះទេ។*

- ការកំណត់ពីតម្រូវការ

1. តើសាលាអនុវិទ្យាល័យរបស់លោក-លោកស្រីមានទីតាំងស្ថិតនៅក្នុងខណ្ឌណា?
   - ក្នុងខណ្ឌ..................................................
2. តើសាលាអនុវិទ្យាល័យរបស់លោក-លោកស្រីមានសិស្សសរុបចំនួនប៉ុន្មាននាក់ និងចំនួនថ្នាក់សរុបប៉ុន្មានថ្នាក់?
   - ថ្នាក់ទី៧៖ ចំនួនសិស្ស...........................នាក់ ចំនួនថ្នាក់..............................
   - ថ្នាក់ទី៨៖ ចំនួនសិស្ស...........................នាក់ ចំនួនថ្នាក់..............................
   - ថ្នាក់ទី៩៖ ចំនួនសិស្ស...........................នាក់ ចំនួនថ្នាក់..............................
3. តើចំនួនបន្ទប់រៀនសរុបដែលសាលាមានជាក់ស្តែងប៉ុន្មានបន្ទប់ ?
   - ចំនួនបន្ទប់រៀនសរុប.................................បន្ទប់ប្រើប្រាស់ជាក់ស្តែង...................បន្ទប់
4. តើគ្រូក្របខ័ណ្ឌដែលមានគុណវុឌ្ឍិ បានបណ្តុះបណ្តាលចេញពី សាលាគរុកោសល្យ សរុបចំនួនប៉ុន្មាននាក់?
   - ចំនួនបន្ទប់រៀនសរុប..............................នាក់ ស្រី...................នាក់

5. តើគ្រូកំពុងបង្រៀនជាក់ស្តែង( មិនគិតមន្ត្រីការិយាល័យចំពោះរបបម៉ោង )ចំនួនប៉ុន្មាននាក់និងតាមមុខវិជ្ជានីមួយៗចំនួនសរុបប៉ុន្មាននាក់? ( សូមជួយបំពេញក្នុងតារាងខាងក្រោមដែលបានភ្ជាប់ជូន )
   - ចំនួនគ្រូកំពុងបង្រៀនជាក់ស្តែងសរុប...........................នាក់ ស្រី................នាក់

| លរ. | មុខវិជ្ជាបង្រៀន | ចំនួនគ្រូកំពុងបង្រៀនជាក់ស្តែង | ស្រី |
|---|---|---|---|
| ១ | ភាសាខ្មែរ | | |
| ២ | ភាសាបរទេស | | |
| ៣ | គណិត | | |
| ៤ | រូប | | |
| ៥ | គីមី | | |
| ៦ | ជីវៈ | | |
| ៧ | ផែនដី | | |
| ៨ | ប្រវត្តិ | | |
| ៩ | ភូមិ | | |
| ១០ | សីលធម៌ ពលរដ្ឋ | | |
| ១១ | ICT | | |
| ១២ | អប់រំកាយនិងកីឡា | | |
| ១៣ | អប់រំសិល្បៈ | | |
| ១៤ | អប់រំសុខភាព | | |
| ១៥ | បំណិនជីវិតតាមមូលដ្ឋាន | | |
| សរុបចំនួន | | | |

6. តើក្នុងចំណោមមុខវិជ្ជាទាំងអស់ខាងលើ តើមុខវិជ្ជាណាខ្លះដែលមិនបានអនុវត្តបញ្ជាក់ពីមូលហេតុ។?
   ..............................................................................................................................
   ..............................................................................................................................
7. បើមុខវិជ្ជាមិនបានអនុវត្ត តើម៉ោងមុខវិជ្ជាទាំងនោះយកទៅបញ្ចូលជាមួយមុខវិជ្ជាណា?
   ..............................................................................................................................
   ..............................................................................................................................
8. តើលោក លោកស្រី ដោះស្រាយបញ្ហាលើស ឬខ្វះគ្រូយ៉ាងដូចម្តេច?
   - ករណីលើស ..............................................................................................

..........................................................................................................

- ករណីខ្វះ ..........................................................................................

..........................................................................................................

● ទស្សនៈរបស់នាយកលើការប្រើប្រាស់គ្រូបង្រៀន

1. តើអនុវិទ្យាល័យ របស់លោក-លោកស្រី បានទទួលចំនួនគ្រូបង្រៀនតាមការស្នើសុំដែរ ឬទេរយៈពេល ៥ឆ្នាំចុងក្រោយនេះ?

**ចំនួនគ្រូបង្រៀនទទួលបានតាមការស្នើសុំគឺៈ**

☐ គ្រប់ចំនួន ☐ ទទួលបានខ្លះ ☐ មិនទទួលបាន ☐ ផ្សេងៗ.................

2. តើលោក~លោកស្រី ជួបប្រទះបញ្ហាប្រឈមអ្វីខ្លះ ក្នុងការកំណត់ពីចំនួនគ្រូបង្រៀននៅតាមអនុវិទ្យាល័យ?

..........................................................................................................

..........................................................................................................

3. តើលោក-លោកស្រីផ្តល់អនុសាសន៍ ដូចម្តេចចំពោះក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីលើស និងខ្វះគ្រូ ?

**<u>ករណីខ្វះ</u>**

☐ ផ្តល់គ្រូថ្មីបន្ថែម

☐ ផ្តល់ប្រាក់ម៉ោងបន្ថែម

☐ បង្កើននិយាមម៉ោងបង្រៀន ពី១៨ ម៉ោង ទៅ ២០ម៉ោង

☐ កែប្រែប្រព័ន្ធជ្រើសរើសគ្រូដោយយកចេញពីមូលដ្ឋាន ឬសហគមន៍

☐ បង្កើនគុណវុឌ្ឍិគ្រូបង្រៀនកម្រិតបឋមសិក្សា ទៅជាគ្រូអនុវិទ្យាល័យ

☐ ផ្សេងៗ.........................................................

**<u>ករណីលើស</u>**

☐ ប្រើគោលការណ៍ប្តូរវេនសាលា ក្នុងស្រុក រយៈពេល ៣ឆ្នាំម្តង

☐ ផ្តល់លើកទឹកចិត្តបន្ថែម លើប្រាក់បៀវត្សន៍រៀងរាល់ខែ ចំពោះអ្នកស្ម័គ្រចិត្តពង្រាយ

☐ លើកទឹកចិត្តបង្កើនកាំប្រាក់ មួយឆ្នាំម្តង ចំពោះអ្នកស្ម័គ្រចិត្តពង្រាយ

☐ លើកទឹកចិត្តដោយផ្តល់ឱកាសក្នុងការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ

☐ ផ្សេងៗ...................................................................

*សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោក លោកស្រី ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចូលរួមឆ្លើយសំណួរទាំងនេះ។*

ឧបសម្ព័ន្ធ (ខ) ៖ លិខិតអនុញ្ញាតចុះប្រមូលទិន្នន័យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ: ១៣៦ ជស.វអក

មន្ទីរ អ.យ.ក ខេត្តស្វាយរៀង
ចូល
លេខ ៦៣៧
ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០
ម៉ោង ១០.១០

ថ្ងៃ ពុធ ៩កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០

**ជម្រាបជូន**

**លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ដើម្បីសរសេរនិក្ខេបបទបំពេញលក្ខខណ្ឌសិក្សាតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត។

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៅវិទ្យាស្ថានជាតិអប់រំ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន លោក លោកស្រី ប្រធាន ជ្រាបថា៖ និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ សរុបចំនួន២៩នាក់ ស្រី០៧នាក់ ដែលកំពុងសិក្សានៅវិទ្យាស្ថានជាតិអប់រំត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្តីពី ការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិនៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០តទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី ប្រធាន ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើតាមការគួរ។

សូម លោក លោកស្រី ប្រធាន ទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ។

**នាយកវិទ្យាស្ថានជាតិអប់រំ** នៃ

បណ្ឌិត សៀង សុខណ្ណា

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អយក "ដើម្បីជាព័ត៌មាន"
- មន្ទីរអយក រាជធានី ខេត្ត "ដើម្បីសហការ"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ វិទ្យាស្ថានជាតិអប់រំ

ឧបសម្ព័ន្ធគៈ លិខិតឧទ្ទេសនាមចាត់តាំងចុះប្រមូលទិន្នន័យ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ ១៣៤ វជអ. ឥក

## លិខិតឧទ្ទេសនាម

យោងៈ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០។

និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ នៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោមត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យស្តីពីការប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ នៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ចាប់ពីថ្ងៃទី២៩ ខែមិថុនាឆ្នាំ ២០២០តទៅៈ

| ល.រ | គោត្តនាម-នាម | ភេទ | រាជធានី ខេត្ត |
|---|---|---|---|
| 1 | សុខ ផល្លី | ស | កណ្តាល |
| 2 | ទុន វណ្ណៈ | ប | កណ្តាល |
| 3 | វង់ ប៊ុនថាន | ប | កែប |
| 4 | គុយ សេងលី | ប | កំពង់ចាម |
| 5 | សំរ៉េត ពេជ្រតា | ស | កំពង់ចាម |
| 6 | ឈាង សោភា | ប | កំពង់ធំ |
| 7 | ពេជ្រ ចំរុង | ប | កំពង់ធំ |
| 8 | ប៊ិត សមពីសិទ្ធ | ប | កំពង់ស្ពឺ |
| 9 | លាង លីលី | ប | កំពង់ស្ពឺ |
| 10 | ជិន សុធី | ប | តាកែវ |
| 11 | មាន់ ម៉ៅ | ប | តាកែវ |
| 12 | មៀង ង៉ុន | ប | ត្បូងឃ្មុំ |
| 13 | យាន ពិសិដ្ឋ | ប | ត្បូងឃ្មុំ |
| 14 | ឆាន ឆាត | ប | បន្ទាយមានជ័យ |

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥-២៣) ២១៩/៥៥៤ គេហទំព័រ: www.nie.edu.kh

| | | | |
|---|---|---|---|
| 15 | ឌី សុផល | ប | បន្ទាយមានជ័យ |
| 16 | ជាច់ សន | ប | ប៉ៃលិន |
| 17 | សុត សំអូន | ប | ពោធិ៍សាត់ |
| 18 | ហួន ស៊ីថា | ប | ពោធិ៍សាត់ |
| 19 | ប៊ិន សុផាន់ណាក់ | ប | ព្រៃវែង |
| 20 | សេ សាយ៉ាន | ស | ព្រៃវែង |
| 21 | សូ ស៊ីណា | ប | ព្រះសីហនុ |
| 22 | កើត មាយលក្ខិណា | ស | ភ្នំពេញ |
| 23 | សុន នីណា | ស | ភ្នំពេញ |
| 24 | ម៉ោញ វង្សា | ស | មណ្ឌលគិរី |
| 25 | កែវ សុខជា | ប | ស្ទឹងត្រែង |
| 26 | រួច វី | ប | សៀមរាប |
| 27✓ | ឌូ សុខា | ប | ស្វាយរៀង |
| 28 | អ៊ិក សម្ផស្ស | ស | ស្វាយរៀង |
| 29 | វៃ សុធី | ប | ឧត្តរមានជ័យ |

ថ្ងៃពុធ ៩កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត សៀង សុខវណ្ណា

**កន្លែងចម្លង៖**

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

"ដើម្បីជ្រាបជាព័ត៌មាន"

-អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង អយក

"ដើម្បីជាព័ត៌មាន"

- មន្ទីរអយក រាជធានី ខេត្ត "ដើម្បីសហការ"

- សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

ឧបសម្ព័ន្ធ (ឃ)៖ លិខិតឧទ្ទេសនាមចាត់តាំងជាគ្រូដឹកនាំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ: ២៧៧ វជអ.៩៨

## លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ ឆ្នាំសិក្សា ២០១៩-២០២០។

គណៈគ្រប់គ្រង និងគ្រូឧទ្ទេសនៃវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យដឹកនាំការសរសេរនិក្ខេបបទរបស់និស្សិតឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី៣ស្តីពីការ **"ប្រើប្រាស់គ្រូបង្រៀននៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ"** នៅតាមរាជធានី ខេត្ត៖

| ល.រ | គ្រូដឹកនាំ | និស្សិត | ភេទ | ករណីសិក្សា |
|---|---|---|---|---|
| 1 | លោក លឹម វ៉ាន់ | សុខ ផល្លី | ស | កណ្តាល |
| 2 | លោក លឹម វ៉ាន់ | ទុន វណ្ណៈ | ប | កណ្តាល |
| 3 | លោក ឡុច ចាន់ថន | វង់ ប៊ុនថាន | ប | កែប |
| 4 | លោក ប៉ូ ប៊ុន្នន | គុយ សេងលី | ប | កំពង់ចាម |
| 5 | លោក ប៉ូ ប៊ុន្នន | សំរ៉េត ពេជ្រតា | ស | កំពង់ចាម |
| 6 | លោកបណ្ឌិត អាន វ៉ូប្រាវ | ឈាង សោភា | ប | កំពង់ធំ |
| 7 | លោកបណ្ឌិត អាន វ៉ូប្រាវ | ពេជ្រ ចំរុង | ប | កំពង់ធំ |
| 8 | លោកបណ្ឌិត គួយ សូគាន | ប៊ុត សមពីសិទ្ធ | ប | កំពង់ស្ពឺ |
| 9 | លោកបណ្ឌិត គួយ សូគាន | លាង លីលី | ប | កំពង់ស្ពឺ |
| 10 | លោក ម៉ន មុនិន្ទ | ជិន សុជី | ប | តាកែវ |

1

| | | | | |
|---|---|---|---|---|
| 11 | លោក ម៉ន មុនិន្ទ | មាន់ ម៉ៅ | ប | តាកែវ |
| 12 | លោកស្រី នូ ចន្នី | មៀង ង៉ុន | ប | ត្បូងឃ្មុំ |
| 13 | លោកស្រី នូ ចន្នី | យាន ពិសិដ្ឋ | ប | ត្បូងឃ្មុំ |
| 14 | លោកបណ្ឌិត នី វឌ្ឍា | ឆាន ផាត | ប | បន្ទាយមានជ័យ |
| 15 | លោកបណ្ឌិត នី វឌ្ឍា | ឌី សុផល | ប | បន្ទាយមានជ័យ |
| 16 | លោកបណ្ឌិត នូវ រ៉ាំ | ថាច់ សន | ប | ប៉ៃលិន |
| 17 | លោកស្រី ខែក សំណាង | សុត សំអូន | ប | ពោធិ៍សាត់ |
| 18 | លោក លន លីណា | ហួន ស៊ីថា | ប | ពោធិ៍សាត់ |
| 19 | លោក ចាប រតនា | ប៊ិន សុផាន់ណាក់ | ប | ព្រៃវែង |
| 20 | លោក ចាប រតនា | រស់ សាយ៉ាន | ស | ព្រៃវែង |
| 21 | លោក សៀង វាសនា | សូ ស៊ីណា | ប | ព្រះសីហនុ |
| 22 | លោក ម៉ៅ សារឿន | កើត មាយលក្ខិណា | ស | ភ្នំពេញ |
| 23 | លោក ម៉ៅ សារឿន | សុន ឌីណា | ស | ភ្នំពេញ |
| 24 | លោក សៀង វាសនា | ម៉ៅញ វឌ្ឍា | ស | មណ្ឌលគិរី |
| 25 | លោកបណ្ឌិត នូវ រ៉ាំ | កែវ សុខជា | ប | ស្ទឹងត្រែង |
| 26 | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | វួច វី | ប | សៀមរាប |
| 27 | លោកបណ្ឌិត ឈាង សង្វាត | ខូ សុខា | ប | ស្វាយរៀង |
| 28 | លោកបណ្ឌិត ឈាង សង្វាត | អ៊ុក សម្ផស្ស | ស | ស្វាយរៀង |
| 29 | ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | រីន សុធី | ប | ឧត្តរមានជ័យ |

ថ្ងៃ អង្គារ ១៣រោច ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០

**នាយកវិទ្យាស្ថានជាតិអប់រំ**

**កន្លែងទទួល៖**

-នាយក នាយករង នាយិការងវជអ "ដើម្បីជ្រាបជាព័ត៌មាន"

-ប្រធានដេប៉ាតឺម៉ង់-ការិយាល័យក្រោមឱវាទវជអ "ដើម្បីសហការ"

-សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារះ ដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការវជអ

បណ្ឌិត.សៀង សុវណ្ណា